និទាឃរណកថា
EDITORIAL

# ការគោរព និងការពាររដ្ឋធម្មនុញ្ញគឺជាកាតព្វកិច្ចចម្បង របស់ពលរដ្ឋគ្រប់រូប និងគ្រប់កម្លាំងនយោបាយក្នុងសង្គម

## Respect and Defend Constitution – Chief Obligation of Every Citizen and Political Forces

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុម័តដោយសភាធម្មនុញ្ញដែលកើតចេញពីការបោះឆ្នោតជាតិនីតិកាលទី១និងត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី២៤ខែកញ្ញាឆ្នាំ១៩៩៣ ។ ខ្លឹមសារនៃរដ្ឋធម្មនុញ្ញ បានបញ្ជាក់យ៉ាងច្បាស់ថា ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។ រដ្ឋធម្មនុញ្ញនេះបានឆ្លុះបញ្ចាំងទាំងស្រុងនូវឆន្ទៈ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជាដែលចង់រស់នៅប្រកបដោយសន្តិភាព សេរីភាព សាមគ្គីភាព ការគោរពច្បាប់និងវឌ្ឍនភាពនៅលើទឹកដីនៃមាតុភូមិរបស់ខ្លួនដែលស្ថិតស្ថេរគង់វង្សជានិរន្តរ៍ ក្នុងឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីដ៏ពេញលេញ ។ នេះគឺជាសមិទ្ធផលដ៏ធំមួយក្នុងចំណោមសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រដែលប្រជាជនកម្ពុជាសម្រេចបាននៅក្នុងបុព្វហេតុនៃការរស់ឡើងវិញរបស់ប្រជាជាតិ និងក្នុងការកសាង និងការពារមាតុភូមិរបស់ខ្លួន ហើយនេះក៏ជាសមិទ្ធផលធំបំផុតនៃកិច្ចព្រមព្រៀងទីក្រុងបារីសអំពីបញ្ហាកម្ពុជានាថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ដែលមានគោលដៅស្តារឡើងវិញ និងថែរក្សាសន្តិភាពនៅកម្ពុជា ។

គិតមកដល់ពេលនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានអាយុគម្រប់ ២១ ឆ្នាំហើយ ។ ប្រជាជនកម្ពុជាមានមោទនភាពក្រៃលែងសម្តែងការរីករាយអបអរសាទរខួបទី ២១ នៃថ្ងៃបដិសន្ធិរដ្ឋធម្មនុញ្ញជាមួយនឹងសេចក្តីសង្ឃឹមចំពោះអនាគតរបស់ខ្លួន ។ក្នុងរយៈពេល២១ឆ្នាំកន្លងទៅនេះ ស្ថិតក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយ ប្រជាជនកម្ពុជាបានរួបរួមគ្នាបញ្ចេញអស់កម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញាស្មារតី ពុះពារជម្នះឧបសគ្គ និងការលំបាកទាំងឡាយ ដើម្បីកសាងប្រទេសឱ្យមានការរីកចម្រើនលើគ្រប់វិស័យ ។ ក្នុងអំឡុងពេលនេះដែរ ប្រជាជនកម្ពុជាបានជួបជុំមូលត្រកូលឡើងវិញ ក្នុងថ្លុងមហាសាមគ្គីជាតិ ឯកភាពជាតិ ក្រោមពន្លឺនៃសន្តិភាព និងធ្វើឱ្យកិត្យានុភាពជាតិត្រូវបានលើកកម្ពស់ជាថ្មីលើឆាកអន្តរជាតិ ។

និយាយជារួម រដ្ឋធម្មនុញ្ញនេះបានផ្តល់កាលានុវត្តភាពយ៉ាងសំខាន់ដល់ប្រជាជនកម្ពុជាក្នុងការនាំមាតុភូមិរបស់ខ្លួនឱ្យឈាន

The Constitution of the Kingdom of Cambodia, adopted by the Constitutional Assembly, born out of the first legislative term of the National Assembly elections and official proclaimed on 24 September 1993. Content of the Constitution clearly emphasizes that Cambodia is the Kingdom with a King who shall rule according to the Constitution and to the principles of liberal democracy, pluralism and market economic system, where people are masters of destiny of their nation. The Constitution wholly reflects the sacred will and aspiration of the people of Cambodia who wish to live in peace, freedom, solidarity, rule of law and progress on the motherland to exist always in full independence and territorial integrity.

This is historically great achievement of all that the people of Cambodia have scored in the course of national revival and construction and defense of their motherland. It is also the greatest achievement of the Paris Peace Agreement on Cambodia on 23 October 1991 that aims to restore and maintain peace in the country.

As of the present, the Constitution of the Kingdom of Cambodia is 21 years of age. The people of Cambodia are proud and joyful, with firm hope, in celebrating the 21 anniversary of the birth of the Constitution. In the past 21 years, under the roof of only one Constitution, the people of Cambodia have united and pooled their physical and mental/intellectual forces to overcome obstacles and hardships for the construction of our country in all fields. It is in this same period, the people of Cambodia have stranded into one under the banner of great solidarity, national unity and ray of peace, while national prestige promoted highly in the international arena.

Generally, the Constitution provides important opportunity for the people of Cambodia in moving the motherland quickly forward on the path of peace, national reconciliation, democracy, rule of law and development. However, existence of the Constitution of the Kingdom of Cambodia to the present does not achieve without obstacle, complication or patriotism and sacrifices. The opposition groups and ill-will circles inside as well as outside the country create numerous obstacles for the process of implementing the Constitution and existing laws aimed at placing Cambodia in turmoil and destabilization to achieve their ambitious goals. As always, on the contrary, they seek every pretext to put the blame on the Cambodian People's Party and the Royal Government who in fact

ទៅមុខយ៉ាងឆាប់រហ័សលើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិវឌ្ឍន៍ ។ ប៉ុន្តែភាពស្ថិតស្ថេរគង់វង្សរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារហូតមកដល់ពេលបច្ចុប្បន្ន មិនមែនកើតមានដោយងាយៗ មិនឆ្លងកាត់ឧបសគ្គ ការលំបាកស្មុគស្មាញ និងសកម្មភាពប្រកបដោយទឹកចិត្តស្នេហាជាតិ និងការលះបង់នោះទេ ។ ក្រុមប្រឆាំង និងមជ្ឈដ្ឋានអគតិនៅក្នុងប្រទេស និងក្រៅប្រទេសមួយចំនួន តែងបង្កឧបសគ្គជាច្រើនដល់ដំណើរការអនុវត្តរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាននានា សំដៅធ្វើឱ្យកម្ពុជាធ្លាក់ក្នុងភាពចលាចល អស្ថិរភាព ដើម្បីសម្រេចនូវមហិច្ឆតាដ៏អាក្រក់របស់ពួកគេ ប៉ុន្តែនៅគ្រប់ពេល ពួកគេតែងតែរកលេសចោទប្រកាន់ មួលបង្កាច់លើគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលដែលជាអ្នកការពាររដ្ឋធម្មនុញ្ញទៅវិញ ។ គេអាចកត់សម្គាល់ឃើញថា រៀងរាល់ក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រម្តងៗ ក្រុមប្រឆាំង និងមជ្ឈដ្ឋានអ្នកអគតិទាំងនោះតែងតែបង្កបញ្ហាធ្វើឱ្យរាំងស្ទះនូវដំណើរការរបស់ជាតិ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើឆន្ទៈរបស់ប្រជាជន រដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។ ជាក់ស្តែង ក្រោយការបោះឆ្នោតជាតិ នីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅ ក្រុមប្រឆាំង និងបណ្តាមជ្ឈដ្ឋានអគតិបានធ្វើសកម្មភាពផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ បំពានលើអង្គព្រះមហាក្សត្រ និងមិនគោរពឆន្ទៈរបស់ប្រជាជនជាម្ចាស់ឆ្នោតឡើយ សំដៅធ្វើឱ្យសភាពការណ៍នយោបាយត្រូវក្រឡាប់ចាក់ ដើម្បីឱ្យពួកគេអាចសម្រេចយុទ្ធសាស្ត្រផ្លាស់ប្តូររបស់ខ្លួនបាន ។ សភាពការណ៍ស្មុគស្មាញនេះបានអូសបន្លាយរហូតដល់ ១០ ខែ ទើបអាចដោះស្រាយបាន ។ រាល់សកម្មភាពប្រទូសរ៉ាយរបស់ពួកគេ ត្រូវទទួលបរាជ័យ និងទទួលរងនូវការថ្កោលទោសពីសំណាក់ប្រជាជនកម្ពុជា និងមជ្ឈដ្ឋានស្រឡាញ់សន្តិភាព លទ្ធិប្រជាធិបតេយ្យ និងយុត្តិធម៌ ។ គណបក្សប្រជាជនកម្ពុជាដែលជាស្ថាបនិកដ៏សំខាន់នៃរដ្ឋធម្មនុញ្ញ ជាកម្លាំងស្នូលការពារ និងគោរពរដ្ឋធម្មនុញ្ញ បានពុះពារដោះស្រាយរាល់ឧបសគ្គ និងការលំបាកទាំងឡាយបានដោយជោគជ័យ ស្របតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ក្នុងស្មារតីស្នេហាជាតិ បង្រួបបង្រួមជាតិដ៏ស្មោះសរ ។ នេះជាសក្ខីភាពបញ្ជាក់យ៉ាងច្បាស់ថា គ្មានជនណា ឬក្រុមណាមួយអាចមកបំផ្លាញ ឬបន្ទាបបន្ថោករដ្ឋធម្មនុញ្ញដែលជាមូលដ្ឋានគ្រឹះនៃឯកភាពជាតិយើងបានឡើយ ហើយនៅគ្រប់កាលៈទេសៈ និងគ្រប់ស្ថានភាព គណបក្សប្រជាជនកម្ពុជា គឺជាកម្លាំងស្នូលដើម្បីធានាការស្ថិតស្ថេរ គង់វង្សនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឱកាសរំឭកខួបលើកទី ២១ ថ្ងៃប្រកាសរដ្ឋធម្មនុញ្ញ ប្រជាជនកម្ពុជាប្តេជ្ញារួមសាមគ្គីជាធ្លុងមួយជុំវិញរាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ដើម្បីការពាររដ្ឋធម្មនុញ្ញរបស់ជាតិ មិនអនុញ្ញាតឱ្យមជ្ឈដ្ឋានអគតិណាមួយមកបំផ្លាញដំណើរការនេះបានឡើយ ។ មានតែការការពារឱ្យបាននូវរដ្ឋធម្មនុញ្ញនេះទេ ទើបប្រជាជាតិយើងអាចស្ថិតស្ថេរបានក្នុងឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម ។ នេះជាកាតព្វកិច្ចចម្បងរបស់យើងទាំងអស់គ្នា ។/

**ទស្សនាវដ្តីប្រជាជន**

defends the Constitution.

It is to everyone's remark that after every national election of members of the National Assembly, the opposition and ill-willed circles always caused problems leading to holding still the national march, violating seriously will of the people, Constitution and existing laws. For instance, in the fifth legislative term of the National Assembly's elections held on 28 July 2013, the opposition and ill-willed circles opted to actions in contrary to the Constitution in violation of HM the King and in disrespect of the will of their voters aimed at turning political situation upside down to achieve their utmost strategic aim to change. The situation lasted for ten months before we could resolve it.

Every controversial action they took failed and condemned by the people and peace, democracy and justice loving circles. The Cambodian People's Party, an important architect of the Constitution and the central force that defends and respects it, makes steadfast efforts to resolve successfully obstacles and hardships in conformity with democratic principle and rule of law in a faithful national reconciliation spirit. This has testified clearly that no one or group can tear down or devalue the Constitution, the foundation of our national unity. In all circumstance and situation, the Cambodian People's Party has always been the central force in guaranteeing lasting existence of the Constitution of the Kingdom of Cambodia.

On the 21st anniversary of the Constitution Day, the people of Cambodia are determined to pooling their efforts around the Royal Government led by Prime Minister Samdech Techo Hun Sen to defend the national Constitution from harms being done by ill-will circles. It is only by defending the Constitution we will put our country in stable independence, peace, freedom, democracy, neutrality and social progress. It is the chief aim of us all./

*THE PRACHEACHUN MAGAZINE*

# វិវត្តន៍ជាវិជ្ជមាននៃសភាពការណ៍នយោបាយកំពុងផ្តល់ភាពអនុគ្រោះដល់ជាតិ និងប្រជាជន



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ដឹកនាំអង្គប្រជុំវិសាមញ្ញរដ្ឋសភា ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៤*

អស់រយៈពេលជិត ១ ឆ្នាំបើគិតចាប់តាំងពីក្រោយការបោះឆ្នោតថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ គណបក្សប្រឆាំងដែលចាញ់ឆ្នោតបានបដិសេធមិនទទួលយកលទ្ធផលនៃការបោះឆ្នោតហើយជំរុញសកម្មភាពដ៏គ្រោះថ្នាក់ចំពោះសង្គមជាតិ ដែលផ្ទុយទាំងស្រុងពីឆន្ទៈរបស់ប្រជាជនជាម្ចាស់ឆ្នោត ។ គណបក្សប្រឆាំងបានអុចអាល ញុះញង់បំផុសអ្នកគាំទ្រខ្លួន ចាត់តាំងបង្កជាបាតុកម្មយ៉ាងអនាធិបតេយ្យ រហូតបង្កជាកុប្បកម្មដ៏ហិង្សា ធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ប្រជាជនមានការភ័យព្រួយ និងលំបាកក្នុងការប្រកបរបររកទទួលទាន ។ គោលបំណងរបស់គណបក្សប្រឆាំង គឺប៉ុនប៉ងប្រើប្រាស់របស់ដែលហៅថា អំណាចប្រជាជន ដើម្បីផ្តួលរំលំគណបក្សប្រជាជនកម្ពុជាដែលបានឈ្នះឆ្នោត និងកាន់អំណាចដោយស្របច្បាប់ ។ សកម្មភាពរបស់ពួកគេបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ប្រមាថទៅលើស្ថាប័នជាតិនានា ពិសេសគឺព្រះមហាក្សត្រជាទីគោរពសក្ការៈរបស់ប្រជាជន ។ បញ្ហានយោបាយត្រូវពួកគេអូសបន្លាយដោយគ្មានហេតុផលត្រឹមត្រូវទាល់តែសោះ ទោះបីជាគណបក្សប្រជាជនកម្ពុជាបានខិតខំស្វែងរកដំណោះស្រាយ តាមរយៈការចរចាក្នុងស្មារតីប្រកបដោយភាពស្មោះសរ សុឆន្ទៈ និងបង្រួបបង្រួមជាតិយ៉ាងណាក្តី រហូតដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ទើប ត្រូវបានដោះស្រាយតាមរយៈជំនួបចរចាកំពូលរវាងគណបក្សទាំងពីរ ។

គួរបញ្ជាក់ថា ជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានប្រព្រឹត្តទៅលើក ដំបូងនៅថ្ងៃទី១៦-១៧ ខែកញ្ញា ឆ្នាំ ២០១៣ ជំនួបទីពីរតាមទូរស័ព្ទរវាងសម្តេចតេជោ **ហ៊ុន សែន** និង ឯកឧត្តម សម រង្ស៊ី នៅថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤ ប៉ុន្តែមិនទទួលបានលទ្ធផលល្អប្រសើរឡើយ អាស្រ័យដោយគណបក្សប្រឆាំងមិនមានគោលជំហរច្បាស់លាស់ និងមិនមានសំឡេងឯកភាពគ្នានៅក្នុងបក្សរបស់ខ្លួន ។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ជំនួបកំពូលលើកទី ៣ រវាងគណបក្សទាំង ៣ ទើបសម្រេចបាននូវកិច្ចព្រមព្រៀងមួយស្តីពីដំណោះស្រាយបញ្ហានយោបាយ ។ ជំនួបកំពូលនេះធ្វើ ឡើងផ្អែកលើខ្លឹមសារដែលបានព្រម ព្រៀងគ្នាជាគោលការណ៍រវាងមេដឹកនាំនៃគណបក្សទាំងពីរ កាលពីថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១៤។ ដំណោះស្រាយនយោបាយរវាងគណបក្សទាំង ២ ដែលសម្រេចបាននៅក្នុងជំនួបកំពូលអស់រយៈពេលជិត ៥ ម៉ោង នោះគឺ ទី១-ឯកភាពគ្នាដោះស្រាយបញ្ហារួមដោយចូលប្រជុំនៅក្នុងរដ្ឋសភា ទី២-ឯកភាពគ្នាក្នុងការជ្រើសរើសសមាសភាពស្ថាប័នរៀបចំការបោះឆ្នោត ទី៣-ឯកភាពគ្នាកំណត់កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនាពេលខាងមុខ ទី៤-ឯកភាពគ្នាក្នុងការបែងចែកអំណាចរវាងអំណាចនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ទី៥-ឯកភាពគ្នាពិនិត្យរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា ទី៦-ឯកភាពគ្នាកែទម្រង់ស្ថាប័នជាតិសំខាន់ៗ ជាពិសេសស្ថាប័នឯករាជ្យនានា ឱ្យអាចបំពេញការងារបម្រើជាតិ និងប្រជាពលរដ្ឋស្រប តាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងទី ៧-ឯកភាពគ្នាក្នុងការសិក្សាដើម្បីឈានទៅធ្វើវិសោធនកម្មបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដើម្បីធានាបានការអនុវត្តកិច្ចព្រមព្រៀងនេះ ។

ដំណោះស្រាយនយោបាយនេះ បានទទួលការអបអរសាទរយ៉ាងខ្លាំងពីសំណាក់ប្រជាជនកម្ពុជា និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម ព្រមទាំងពីបណ្តាប្រទេសជាមិត្តរបស់កម្ពុជា ។ លទ្ធផលនៃដំណោះស្រាយបានបង្ហាញយ៉ាងច្បាស់ថា មានតែការចរចាររវាងខ្មែរ និងខ្មែរទេ ទើបអាចដោះស្រាយបញ្ហាខ្មែរបាន ផ្ទុយទៅវិញការធ្វើបាតុកម្មតាមដងផ្លូវ និងស្វែងរកអន្តរាគមន៍ពីខាងក្រៅមិនមែនជាដំណោះស្រាយទេ ។

នៅថ្ងៃទី ២៤ ខែកក្កដា ថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា រួមមាន សម្តេចតេជោ **ហ៊ុន សែន** ឯកឧត្តម **ស ខេង** និងឯកឧត្តម **សាយ ឈុំ** និងថ្នាក់ដឹកនាំនៃគណបក្សសង្គ្រោះជាត រួមមាន ឯកឧត្តម សម រង្ស៊ី ឯកឧត្តម កឹម សុខា និងឯកឧត្តម ប៉ុល ហំម បានចូលក្រាបបង្គំគាល់ ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីទូលថ្វាយព្រះអង្គអំពីលទ្ធផលនៃកិច្ចប្រជុំកំពូលរវាងគណបក្សទាំងពីរ កាលពីថ្ងៃទី២២ ខែកក្កដា ។ ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យគាំទ្រនូវការសម្រេចបានកិច្ចព្រមព្រៀងបញ្ចប់បញ្ហានយោបាយរបស់កម្ពុជានេះ និងបានជូនពរដល់គណបក្សទាំងពីរ ឱ្យទទួលបានជោគជ័យគ្រប់ការងារទាំងអស់ ។ នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ



*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ក្នុងសម័យប្រជុំវិសាមញ្ញរដ្ឋសភាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៤*

២០១៤ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចទទួលស្គាល់ ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ជាបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាមជាផ្លូវការ បន្ទាប់ពីមានការស្នើសុំពីគណបក្សសង្គ្រោះជាតិ ( ថ្ងៃទី ២៤ ខែកក្កដា) ។ ឯកឧត្តម សម រង្ស៊ី ត្រូវជំនួសកន្លែងឯកឧត្តម គួយ ប៊ុនរឿន ដែលគណបក្សសង្គ្រោះជាតិនឹងតម្រូវឱ្យទៅធ្វើជាសមាជិក គ.ជ.ប. នៅថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០១៤ បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិទាំងអស់ចំនួន ៥៥ រូប បានចូលធ្វើសច្ចាប្រណិធាន និងផឹកទឹកសម្បថនៅចំពោះព្រះភ័ក្ត្រអង្គព្រះមហាក្សត្រ ព្រមទាំងសម្ដេចព្រះសង្ឃរាជ ។ ជាបន្តបន្ទាប់ក្រុមការងារនៃគណបក្សទាំងពីរបានធ្វើការជួបប្រជុំពិភាក្សាគ្នាលើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ វិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងការពិភាក្សាអំពីកំណែទម្រង់ការបោះ-ឆ្នោតថ្មី ។

នៅថ្ងៃទី០៨ខែសីហាឆ្នាំ២០១៤សម័យប្រជុំវិសាមញ្ញនៃរដ្ឋសភានីតិកាលទី ៥ បានប្រារព្ធក្រោមអធិបតីភាពសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ដើម្បីអនុម័តសេចក្ដីស្នើវិសោធនកម្មប្រការ ៦ ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ។ នេះជាលើកដំបូងដែលសមាជិករដ្ឋសភានៃគណបក្សសង្គ្រោះជាតិទាំង ៥៥ រូប បានចូលរួមប្រជុំ ។សេចក្ដីស្នើវិសោធនកម្មប្រការ៦ថ្មីនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋ-សភា ត្រូវបានអនុម័ត ដោយសំឡេង ១២២ លើ ១២២ ។ ប្រការគួរឱ្យកត់សម្គាល់គឺឯកឧត្តម សម រង្ស៊ី បានឡើងថ្លែងនៅក្នុងរដ្ឋសភាថា តទៅខាងមុខនឹងមិនមានការអនុវត្តនយោបាយ "ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី" នោះឡើយ ។ សម្ដេចតេជោ **ហ៊ុន សែន** បានសាទរចំពោះការលើកឡើងរបស់ឯកឧត្តម សម រង្ស៊ី ។ សម្ដេចបានបញ្ជាក់ថា សព្វថ្ងៃគណបក្សប្រជាជនកម្ពុជាកាន់អំណាចគណបក្សដទៃក៏អាចរស់នៅជាមួយបាន ហើយសម្ដេចសង្ឃឹមថា គណបក្សដទៃអាចធ្វើដូចគ្នាបែបនេះ ។ សម្ដេចតេជោ **ហ៊ុន សែន** ក៏បានសុំឱ្យព្រះសង្ឃ និងប្រជាជនកត់ត្រាទុកនូវសម្ដីរបស់សម្ដេច និងរបស់ឯកឧត្តម សម រង្ស៊ី ព្រោះថា បញ្ហាជាមូលដ្ឋានរបស់យើងគឺការរួបរួមគ្នា ។

គួរកត់សម្គាល់ថា នៅក្នុងអំឡុងពេលស្វែងរក និងអនុវត្តដំណោះស្រាយនយោបាយរវាងគណបក្សទាំងពីរ តុលាការបានចេញដីកាកោះហៅ និងឃុំខ្លួនសកម្មជនមួយចំនួនរបស់គណបក្សសង្គ្រោះជាតិដែលបានដឹកនាំសកម្មភាពកុប្បកម្មហិង្សា បង្កឱ្យមានរបួសស្នាមធ្ងន់ធ្ងរទៅលើកម្លាំងសន្តិសុខជិត ៤០ នាក់ កាលពីថ្ងៃទី ១៥ ខែកក្កដា នៅស្ពាននាគក្បែរទីលានប្រជាធិបតេយ្យ ។ គណបក្សសង្គ្រោះជាតិ និងអង្គការសង្គមស៊ីវិលខ្លះបានចោទប្រកាន់ថា ការឃុំខ្លួនសកម្មជនរបស់ខ្លួនមានលក្ខណៈនយោបាយ ។ នេះជាការចោទប្រកាន់ដោយមិនត្រឹមត្រូវ ។ តុលាការគឺជាស្ថាប័នឯករាជ្យ ដែលអនុវត្តការងាររបស់ខ្លួន ដោយឈរលើមូលដ្ឋានច្បាប់ ។ ម្យ៉ាងទៀត គោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ចាប់បង្ខំឱ្យមនុស្សគ្រប់រូបត្រូវស្ថិតនៅក្រោមច្បាប់ និងត្រូវគោរពច្បាប់ ។ រាជរដ្ឋាភិបាលកម្ពុជា ដែលប្រសូតចេញពីការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស មានកាតព្វកិច្ចថែរក្សាច្បាប់ រក្សាសន្តិសុខជាតិ និងសេចក្ដីសុខសាន្តរបស់ប្រជាជន ។ ហេតុនេះ ត្រូវប្រកាន់យកវិធានការច្បាប់ដើម្បីការពាររដ្ឋធម្មនុញ្ញ ការពារជាតិ សាសនា ព្រះមហាក្សត្រ ការពារលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ធានាឱ្យបាននូវប្រក្រតីភាពនៃដំណើរការសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន មិនអនុញ្ញាតឱ្យជនណាមកបង្កចលាចលសង្គមបានឡើយ ។

ដំណោះស្រាយនយោបាយនេះ ថ្វីត្បិតតែត្រូវបានរកឃើញដោយចំណាយពេលអស់ជិត ១ ឆ្នាំក្ដី ក៏វាបានបង្ហាញឱ្យឃើញពីជំហានទៅមុខនៃចលនាពង្រឹងធ្លុងសាមគ្គីជាតិ ហើយបង្កើតបាននូវភាពអនុគ្រោះដល់ដំណើរការរបស់រដ្ឋ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងប្រក្រតីភាពនៃជីវភាពរបស់ប្រជាជន ។ ប្រការដ៏សំខាន់តទៅមុខទៀតនោះ គឺគណ-បក្សសង្គ្រោះជាតិត្រូវបង្ហាញនូវភាពស្មោះត្រង់ពិតប្រាកដ និងឈប់អនុវត្តនូវទង្វើប្រទូសរ៉ាយនានាដូចដែលធ្លាប់បានធ្វើនាពេលកន្លងមក ។ មានតែការរួមសាមគ្គីគ្នាក្រោមដំបូលរដ្ឋធម្មនុញ្ញទេ ទើបយើងមានកម្លាំងក្នុងការកសាង និងការពារជាតិយើង ។ ការប្រកួតប្រជែង-គ្នាត្រូវតែស្ថិតក្នុងក្របខណ្ឌនយោបាយ តាមគោលការណ៍ប្រជាធិប-តេយ្យ និងក្នុងបរិបទនីតិរដ្ឋ ។ ប្រវត្តិសាស្ត្របានបន្សល់ទុកនូវមេរៀន និងបទពិសោធន៍ គ្រប់គ្រាន់ហើយសម្រាប់ប្រជាជាតិយើង ។/

# មហាសន្និបាតអាណត្តិទី៦របស់កាកបាទក្រហមកម្ពុជា




*ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*
*យាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃពិធីបើកមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី ៦*





*សមាជិក សមាជិកា និងគណៈអធិបតី អនុម័តខ្លឹមសារសន្និបាតយុវជនលើកទី ៣ នៅថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១៤*
*និងមហាសន្និបាតវិសាមញ្ញ នៅថ្ងៃទី ៦ ខែសីហាឆ្នាំ ២០១៤ នៅទីស្នាក់ការកណ្ដាល*

បន្ទាប់ពីបានប្រារព្ធសន្និបាតយុវជនលើកទី ៣កាលពីថ្ងៃទី ៣ខែសីហា ឆ្នាំ២០១៤ និងបានប្រារព្ធមហាសន្និបាតវិសាមញ្ញកាលពីថ្ងៃទី៦ខែសីហា ឆ្នាំ២០១៤នៅទីស្នាក់ការកណ្ដាលរបស់ខ្លួនរួចមក កាកបាទក្រហមកម្ពុជា បានប្រារព្ធមហាសន្និបាតអាណត្តិទី ៦ នៅរសៀលថ្ងៃទី ៦ និងនៅថ្ងៃទី៧ ខែសីហាឆ្នាំ២០១៤នៅសាលសន្និសីទចតុមុខរាជធានីភ្នំពេញ ដោយមាន **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**ជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃពិធីបើក និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីអញ្ជើញជាអធិបតីក្នុងពិធីបិទ។មហាសន្និបាតអាណត្តិទី៦នេះ មានការអញ្ជើញចូលរួមពីសមាជិក-សមាជិកាពេញសិទ្ធិចំនួន១៦២នាក់និងអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិចំនួន ១០៥ នាក់ ។ សមាជិកសមាជិកាពេញសិទ្ធិគឺជាគណៈកម្មាធិការកណ្ដាលអាណត្តិទី ៥ បេក្ខជនគណៈកម្មាធិការកណ្ដាលអាណត្តិទី៦និងប្រតិភូមកពីសាខារាជធានី-ខេត្តទាំង២៥។ក្នុងសមាសភាពអ្នកសង្កេតការណ៍ជាតិមានឥស្សរជនអញ្ជើញមកពីស្ថាប័ននិតិបញ្ញត្តិ នីតិប្រតិបត្តិ តំណាងក្រសួងមន្ទីរនានាសមាជិក-សមាជិកាកាកបាទក្រហមកម្ពុជា អ្នកស្ម័គ្រចិត្តយុវជនកាកបាទក្រហម-កម្ពុជា។ក្នុងជួរអ្នកសង្កេតការណ៍អន្តរជាតិរួមមានអង្គទូតអង្គការអន្តរជាតិគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម សហព័ន្ធអន្តរជាតិ សមាគមជាតិដៃគូសហប្រតិបត្តិការ ជាពិសេស ប្រតិភូមកពីសមាគមជាតិ កាកបាទ-ក្រហមវៀតណាម ចិននិងមីយ៉ាន់ម៉ា ។

នៅក្នុងសន្ទរកថាស្វាគមន៍សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា បានទូលថ្វាយរបាយការណ៍ព្រះករុណាព្រះមហាក្សត្រជាអម្ចាស់ទ្រង់ព្រះសណ្ដាប់ និងជម្រាបជូនអង្គមហាសន្និបាតបានជ្រាបនូវសមិទ្ធផលសំខាន់ៗ ដែលកាកបាទក្រហមកម្ពុជាសម្រេចបាននៅក្នុងអាណត្តិទី៥(២០១០-២០១៤)ជាអាទិថា"កាកបាទក្រហមកម្ពុជា បានចូលរួមដោះស្រាយនូវទុក្ខលំបាក ភាពខ្វះខាតរបស់ប្រជាជន និងផលប៉ះពាល់ដែលបង្កឡើង ដោយសារការប្រែប្រួលអាកាសធាតុ ការកើតមានជំងឺឆ្លងថ្មីៗ និងបញ្ហាប្រឈមនានា តាមរយៈការអនុវត្ត

នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ កាកបាទក្រហមកម្ពុជាទាំងថ្នាក់កណ្តាល ក៏ដូចជាសាខា អនុសាខា បានចុះជួយសង្គ្រោះផ្ទាល់ដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ មានដូចជាខ្យល់ព្យុះ ខ្យល់កន្ត្រាក់ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ គ្រោះអគ្គីភ័យ និងគ្រោះមហន្តរាយដោយប្រការផ្សេងៗទៀតបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពទៅតាមតម្រូវការជាក់ស្តែង នៃតំបន់រងគ្រោះនីមួយៗ ។ ជាមួយគ្នានេះ កាកបាទក្រហមកម្ពុជា នៅបានរួមចំណែកជួយសង្គ្រោះដល់ប្រជាជននៅ



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងពិធីបិទមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៦*

ទូទាំងប្រទេស មានជាអាទិ៍ ដូចជា ចាស់ជរា ជនគ្មានទីពឹង ស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការកុមារគរ-ថ្លង់ យុវជនញៀនថ្នាំ និង អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ ។ល។ ក្រៅពីការងារ ជួយសង្គ្រោះកាកបាទក្រហមកម្ពុជានៅគ្រប់លំដាប់ថ្នាក់ បានដំណើរការអនុវត្តការងាររបស់ខ្លួនតាមរយៈកម្មវិធី និងគម្រោងនានា មានដូចជាកម្មវិធីគម្រោងទឹកស្អាតនិងអនាម័យ កម្មវិធីអេដស៍ កម្មវិធីគម្រោងប្រាក់កម្ចីខ្នាតតូច ដោយពុំយកការប្រាក់ពីប្រជារាស្ត្រកម្មវិធីសុវត្ថិភាពសហគមន៍ ការអនុវត្តគម្រោងសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ល។"ជាមួយគ្នានោះសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា បានថ្លែងគូសបញ្ជាក់អំពីទិសដៅចម្បងៗរបស់កាកបាទក្រហមកម្ពុជាអាណត្តិទី ៦ (២០១៤-២០២០)ថា"កម្ពុជានៅមានបញ្ហាប្រឈមជាសកលមួយចំនួនទៀតដែលត្រូវដោះស្រាយមានដូចជា អំពើហិង្សា ជំងឺឆ្លង ដែលកើតមានជាបន្តបន្ទាប់នៅពេលថ្មីៗនេះ គ្រោះថ្នាក់ចរាចរណ៍គ្រឿងញៀន គ្រឿងស្រវឹង ល្បែងស៊ីសងគ្រប់ប្រភេទដែលចាំចាច់ កាកបាទក្រហមកម្ពុជា ត្រូវបង្កើនកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធថែមទៀត ជាមួយរាជរដ្ឋាភិបាល ពិសេសក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ក្នុងការអនុវត្តការងាររបស់ខ្លួន នៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានដើម្បីផ្តល់សេវា និងការសម្របសម្រួលឲ្យប្រព្រឹត្តទៅដោយរលូន ក្នុងការជួយសង្គ្រោះ ជនរងគ្រោះ ក៏ដូចជាការចូលរួមឲ្យកាន់តែសកម្ម ក្នុងការដោះស្រាយនូវផលប៉ះពាល់ដែលកើតចេញពីបញ្ហាប្រឈមជាសកល និងគ្រោះថ្នាក់ដែលកើតឡើងជាយថាហេតុ ដើម្បីជាក្តីសង្ឃឹម និងភាពជឿជាក់ដល់ជនរងគ្រោះនៅទូទាំងប្រទេស " ។

អង្គមហាសន្និបាតមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលបានត្រងត្រាប់នូវព្រះរាជសន្ទរកថារបស់ព្រះករុណាព្រះមហាក្សត្រដែលបានថ្លែងកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះសមិទ្ធិផល និងជោគជ័យដែលកាកបាទក្រហមកម្ពុជាសម្រេចបាន និងបានប្រោសព្រះរាជទាន ព្រះរាជតម្រិះដល់អង្គមហាសន្និបាតទាំងមូល ក្នុងការបោះឆ្នោតជ្រើសតាំងគណៈកម្មការកណ្តាល ជាពិសេសជ្រើសរើសប្រធាន ប្រកបដោយគុណសម្បត្តិដឹកនាំសមាគមជាតិឱ្យកាន់តែមានវឌ្ឍនភាព និងសម្រេចបានជោគជ័យធំថែម



*សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** អញ្ជើញជាអធិបតី និងដឹកនាំមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៦*

ទៀត ។ ជាមួយគ្នានោះដែរ អង្គមហាសន្និបាតបានត្រងត្រាប់ខ្លឹមសារព្រះសារលិខិតរបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ដែលប្រោសប្រទានសព្ទសាធុការពរជ័យដល់មហាសន្និបាតទាំងមូល ។ លើសពីនេះទៅទៀត **ព្រះករុណា ព្រះមហាក្សត្រ** ជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ប្រោសព្រះរាជទាន ព្រះរាជទ្រព្យ ចំនួន ៥,០០០ដុល្លារអាមេរិកនិងសម្តេចព្រះវររាជមាតាជាតិខ្មែរចំនួន១០,០០០ដុល្លារអាមេរិក ដែលនេះជាព្រះរាជឧបត្ថម្ភបន្ថែម ជាពិសេសលើព្រះរាជឧបត្ថម្ភជារៀងរាល់ខែ និងជារៀងរាល់ត្រីមាសរបស់ព្រះអង្គទាំងទ្វេ ។

អនុវត្តន៍តាមរបៀបវារៈទី ១ និង ទី ២ អង្គមហាសន្និបាតបានពិនិត្យពិភាក្សា និងអនុម័តរបាយការណ៍បូកសរុបលទ្ធផលការងារ កាកបាទក្រហមកម្ពុជាអាណត្តិទី ៥ និងទិសដៅការងារអាណត្តិបន្ត ដែលរៀបចំឡើងដោយលោកជំទាវ **ពុំ ចន្ទីនី** អគ្គលេខាធិការ និងបានពិនិត្យអនុម័តរបាយការណ៍ហិរញ្ញវត្ថុ៤ឆ្នាំ(២០១០-២០១៣)និងផែនការថវិកាសម្រាប់អាណត្តិបន្ត ដែលរៀបចំដោយលោកជំទាវ **អ៊ុក ម៉ាលី** អគ្គហិរញ្ញិក ។

អនុវត្តរបៀបវារៈទី ៣ អង្គមហាសន្និបាតបានដំណើរការបោះឆ្នោត និងសមាជិក សមាជិកាពេញសិទ្ធិប្រគល់សេចក្តីទុកចិត្តលើសមាសភាពគណៈ-កម្មាធិការកណ្តាលអាណត្តិទី ៦ ដែលមានសរុបចំនួន ២៩ រូប ក្នុងនោះ ២៨ រូប បោះឆ្នោតដោយមហាសន្និបាតអាណត្តិទី ៦ នេះ និង ១ រូបទៀត ត្រូវបានជ្រើសតាំងដោយសន្និបាតយុវជនលើកទី ៣ រួចមកហើយ កាលពីថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១៤ កន្លងទៅ ។

នៅក្នុងពិធីបិទមហាសន្និបាតនៅរសៀលថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០១៤





*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្លែងសុន្ទរកថាក្នុងពិធីបិទមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៦*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានអបអរសាទរ ចំពោះ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដែលត្រូវបានអង្គមហាសន្និបាតផ្តល់នូវជំនឿ និងសេចក្តីទុកចិត្តជាថ្មីជ្រើសតាំងជាប្រធានកាកបាទក្រហមកម្ពុជាសម្រាប់អាណត្តិទី ៦ ទៀត ។ ជាមួយគ្នានោះ សម្តេចតេជោ បានគូសបញ្ជាក់ថា " រាជរដ្ឋាភិបាលនឹងបន្តជួយគាំទ្រ ទាំងផ្នែកគោលនយោបាយច្បាប់ យន្តការគាំទ្រនានា ព្រមទាំងសម្ភារៈ និងថវិកា ក្នុងការជំរុញ និងលើកទឹកចិត្តដល់កាកបាទក្រហមកម្ពុជា ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រ ២០១១-២០២០ របស់ខ្លួន ដើម្បីសម្រេចបានជោគជ័យថ្មីៗថែមទៀត នៅអាណត្តិថ្មីនេះ " ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានថ្លែងជាសំខាន់ថា " ការដាក់ចេញនូវយុទ្ធសាស្ត្រ ២០១១- ២០២០របស់កាកបាទក្រហមកម្ពុជា បានដើរស្របគ្នាទៅនឹងចក្ខុវិស័យយូរអង្វែងរបស់រាជរដ្ឋាភិបាល ដែលតែងតែប្រកាន់ខ្ជាប់លើការប្រមូលផ្តុំកម្លាំងប្រជាជាតិនៅទូទាំងប្រទេស ដើម្បីរួមសាមគ្គីគ្នា កសាង និងការពារមាតុភូមិកម្ពុជា ឱ្យបានសម្បូណ៌រុងរឿង ធានាបាននូវការបែងចែកផ្លែផ្កានៃការរីកចម្រើនប្រកបដោយសមធម៌ និងការកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាជន និងធ្វើឱ្យប្រជាជនបានរស់នៅប្រកបដោយភាពសុខដុម និងមានសុភមង្គល ។"ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ សម្តេចតេជោ មានការជឿជាក់ថា " ខ្ញុំសង្ឃឹម និងជឿជាក់ថា ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់កាកបាទក្រហមកម្ពុជានឹងប្តេជ្ញាចិត្តបន្តពង្រឹងការដឹកនាំកាកបាទក្រហមកម្ពុជាដោយស្មារតីទទួលខុសត្រូវ មានអភិបាលកិច្ចល្អ និងពង្រឹងសាមគ្គីភាពឯកភាពមានកិច្ចសហប្រតិបត្តិការជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ដើម្បីឆ្លើយតបដល់ការងារជួយសង្គ្រោះជីវិតមនុស្សការងារដោះស្រាយបញ្ហាប្រឈមនានា ការលើកតម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ឱ្យស័ក្តិសមជាសមាគមជាតិនាំមុខគេក្នុងវិស័យមនុស្សធម៌នោះ " ។

អង្គមហាសន្និបាត បានបញ្ចប់ដំណើរការរបស់ខ្លួន នៅវេលាម៉ោង ១៧:០០ ប្រកបដោយបរិយាកាសរីករាយកក់ក្តៅក្រៃលែង៕





**សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព**
**សូមចូលមក** Facebook Page : Pracheachun Magazine-**ទស្សនាវដ្តីប្រជាជន**
**ហើយចុច** Like **និង** Share **ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ**

# ទិសដៅ ៤ ចំណុច ដើម្បីអភិវឌ្ឍយុវជន
# សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតែជាគោលដៅចម្បងមួយ
# ប្រព័ន្ធបៀវត្សរ៍ថ្មីនឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០១៥




*សម្តេចអគ្គមហាសេនាបតីតេជោ មានប្រសាសន៍ក្នុងពិធីបិទសន្និសីទអន្តរជាតិលើកទី ៥ ស្តីពីភាពអ្នកដឹកនាំនៃបញ្ញវន្តឆ្នើមឆ្នាំ ២០១៤ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ*

នៅក្នុងខែសីហាឆ្នាំ ២០១៤ កន្លងទៅនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងកម្មវិធីមួយចំនួន ដែលក្នុងនោះបានជួបជាមួយយុវជន សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ។ ក្នុងបណ្តាជំនួបទាំងនេះ សម្តេចក៏បានបញ្ជាក់អំពីអនុសាសន៍មួយចំនួនដែលទាក់ទងនឹងការអប់រំ បៀវត្សរ៍ ដំណោះស្រាយជីវិត ។ល។

* ថ្ងៃទី ៦ ខែសីហា សម្តេចអគ្គមហាសេនាបតីតេជោ អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និសីទអន្តរជាតិលើកទី ៥ ស្តីពីភាពអ្នកដឹកនាំនៃបញ្ញវន្តឆ្នើមឆ្នាំ ២០១៤ ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ ដែលបានប្រារព្ធនៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ ។ មានប្រសាសន៍នាឱកាសនោះសម្តេចបានចាត់ទុកយុវជនគឺជាតួអង្គស្នូលក្នុងការចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដែលទាមទារឱ្យយុវជនគ្រប់រូបត្រូវមានសមត្ថភាពពេញលេញនិងប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់លើជំនាញ ដើម្បីជ្រៀតចូលក្នុងរបត់នយោបាយថ្មីៗ សកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ចដែលមានការប្រកួតប្រជែង និងមានការប្រែប្រួលយ៉ាងលឿននៅក្នុងបរិការណ៍នៃសាកលភាវូបនីយកម្មនាពេលបច្ចុប្បន្ន ។

នាពេលនោះដែរ សម្តេចតេជោបានបញ្ជាក់អំពីមិនមានការអនុវត្តនូវរបៀបបន្តវេនក្នុងការកាន់អំណាចពីឪពុកទៅកូននោះទេ ។ សម្តេចបញ្ជាក់ថា ក្នុងប្រទេសប្រជាធិបតេយ្យមិនអាចផ្ទេរអំណាចពីឪពុកទៅកូនបានទេ លើកលែងតែមានការបោះឆ្នោតគាំទ្រពីប្រជាពលរដ្ឋ ។

ការលើកឡើងរបស់សម្តេចតេជោជាការឆ្លើយតបដោយប្រយោលទៅនឹងកាសែតឌីណេសិនរបស់ថៃ ដែលកាសែតនេះបានសរសេរពាក់ព័ន្ធទៅនឹងកូនប្រុសច្បងរបស់សម្តេច គឺឯកឧត្តម **ហ៊ុន ម៉ាណែត** ដែលបានធ្វើទស្សនកិច្ចទៅកាន់ប្រទេសថៃនាពេលថ្មីៗនេះ ជាមួយឯកឧត្តមនាយឧត្តមសេនីយ៍ឧបនាយករដ្ឋមន្ត្រី **ទៀ បាញ់** រដ្ឋមន្ត្រីក្រសួងការពារជាតិ ថា នេះជាការបង្ហាញកាន់តែច្បាស់ថាឯកឧត្តម **ហ៊ុន ម៉ាណែត** នឹងក្លាយជាអ្នកស្នងតំណែងនាយករដ្ឋមន្ត្រីពីសម្តេចតេជោនោះ ។

សម្តេចតេជោបានលើកជាសំណួរថា ប្រទេសនៅលើពិភពលោកដែលអនុវត្តនូវលទ្ធិប្រជាធិបតេយ្យ តាមរយៈនៃការបោះឆ្នោត តើការផ្ទេរតំណែងបែបណាទៅដល់កូនបាននោះ? ។ ក្នុងប្រទេសប្រជាធិបតេយ្យ មិនអាចផ្ទេរអំណាចពីឪពុកទៅកូនបានទេ លើកលែងតែមានការបោះឆ្នោតគាំទ្រពីប្រជាពលរដ្ឋ។ សម្តេចបន្តក្នុងនាមជានាយករដ្ឋមន្ត្រី សម្តេចអាចដាក់កូនអ្នកនេះ អ្នកនោះទៅក្នុងតំណែងជួររាជរដ្ឋាភិបាលបាន ប៉ុន្តែសម្តេចមានការលំបាកមិនអាចដាក់កូនខ្លួនឯងបាន ព្រោះវានឹងអាចមានការចោទជាសំណួរថាជាការរៀបចំតាមបក្ខពួកនិយម ។

សម្តេចបន្តថា "កាលពីអតីតកាលខ្ញុំមានបងប្រុសម្នាក់ គឺលទ្ធភាពរបស់គាត់ស្មើរតែខ្ពស់ជាងខ្ញុំ ប៉ុន្តែជាអកុសលដោយសារតែកាន់តំណែងជានាយករដ្ឋមន្ត្រីរបស់ខ្ញុំ គឺក្លាយទៅជាឧបសគ្គរាំងបងប្រុសមួយនេះនៅត្រឹមកម្រិតជាអភិបាលខេត្តហើយចូលនិវត្តន៍មិនអាចក្លាយជាសមាជិករាជរដ្ឋាភិបាលបានទេ" ។

សម្តេចបានបន្តថា ឥឡូវនេះសម្តេចមានកូន ៥ នាក់ និងកូនប្រសារ ៥ នាក់ទៀត ដែលសុទ្ធតែរៀននៅឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ក៏ប៉ុន្តែពួកគេពិតជាមានការលំបាក ។ យើងមិនអាចបញ្ចូលពួកគេទៅក្នុងក្របខណ្ឌនៃកិច្ចការរដ្ឋបានទេ ព្រោះវានឹងអាចមានការចោទជាសំណួរថា តើនេះគឺជាការរៀបចំបែបបក្ខពួកនិយម ឬយ៉ាងម៉េច? ។ សម្តេចបញ្ជាក់ថា វាមិនមែនជាបញ្ហាដាច់ដោយឡែករបសគណបក្សនៅក្នុងរាជរដ្ឋាភិបាលនោះទេ ។ ព្រឹកមិញនេះអត្ថបទរបស់កាសែតភ្នំពេញប៉ុស្តិ៍ក៏បានចុះផ្សាយអំពីកូនរបស់មេដឹកនាំគណបក្សប្រឆាំង ដែលនឹងត្រូវរៀបចំខ្លួនចូលទៅកាន់តំណែងជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលគ្រាន់តែឮបែបនេះគឺមានការតិះទៀនដែរ ។

នាពេលនោះដែរ សម្តេចក៏បានផ្តល់នូវអនុសាសន៍ចំនួន ៤ សម្រាប់យុវជន ក្នុងនោះ ទី ១.ត្រូវបង្កើនកាលានុវត្តភាពដល់យុវជនក្នុងការចូលរួមការអភិវឌ្ឍសេដ្ឋកិច្ច ។ សម្តេចរំឭកថា បច្ចុប្បន្នកម្ពុជាគឺជាប្រទេសដែល មានប្រជាពលរដ្ឋវ័យក្មេងច្រើនជាងគេនៅក្នុងតំបន់អាស៊ាន ពោលគឺប្រជាជនប្រមាណ ៥ លាននាក់ ស្មើនឹងប្រមាណ ៣០% នៃប្រជាជនសរុបគឺជាយុវជនមានអាយុចាប់ពី ១៥ ឆ្នាំ ដល់ ២៩ ឆ្នាំ ។ ចំនួននេះនឹងកើនឡើង ដល់ ៤០% នៃប្រជាជនសរុបនៅឆ្នាំ ២០២០ ។ សម្តេចបានស្នើឱ្យក្រសួងស្ថាប័នពាក់ព័ន្ធវិស័យឯកជន អង្គការជាតិ អន្តរជាតិបង្កើនកិច្ចសហប្រតិបត្តិការ និងខិតខំធ្វើឱ្យប្រសើរឡើងនូវបរិយាកាសទីផ្សារការងារ និងសហគ្រិនភាពសម្រាប់យុវជន និងពង្រឹងភាពជាដៃគូជាមួយយុវជនគ្រប់ស្រទាប់វណ្ណៈ ដោយផ្តល់នូវការអប់រំ និងការបណ្តុះបណ្តាលផ្តល់បទពិសោធន៍ដល់យុវជនដើម្បីងាយស្រួលឈានទៅរកទីផ្សារការងារឱ្យកាន់តែទូលំទូលាយ និងពង្រឹងការចូលរួមរបស់យុវជន ។ សម្តេចស្នើឱ្យមានការរៀបចំចលនាមួយដោយប្រមូលផ្តុំឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងវិស័យសាធារណៈ វិស័យឯកជន សហគមន៍

មូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ រួមគ្នាលើកទឹកចិត្តឱ្យមានកម្មវិធីអភិវឌ្ឍន៍យុវជនក្នុងអង្គភាពរបស់ខ្លួន សំដៅផ្តល់ការតម្រង់ទិសវិជ្ជាជីវៈដល់យុវជនឱ្យចាប់យកកាលានុវត្តភាពទីផ្សារឱ្យកាន់តែស៊ីជម្រៅ ។ ជំរុញយុវជនចូលរួមក្នុងការងារ សង្គមឱ្យកាន់តែសកម្ម ។ ពង្រឹងតួនាទី និងការចូលរួមរបស់យុវជននៅក្នុងសេវាសាធារណៈផ្តល់កាលានុវត្តភាព និងគាំទ្រសហគ្រិនភាពរបស់យុវជនវ័យក្មេង ។

ចំណុចទី ២.ពង្រឹងការអប់រំ និងការអភិវឌ្ឍជំនាញដល់យុវជន ជារួមរាជរដ្ឋាភិបាលកម្ពុជាបានកំពុងយកចិត្តទុកដាក់លើការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែមានភាពរីកចម្រើន និងភាពប្រកួតប្រជែងខ្ពស់ ជាមួយបណ្តាប្រទេសក្នុងតំបន់ និងផ្តល់ឱកាសការងារដល់គ្រប់ស្រទាប់យុវជន ។ ទី៣. ជំរុញឱ្យយុវជនក្លាយជាអ្នកជំនាញវិជ្ជាជីវៈមួយដ៏ពិតប្រាកដ ។សម្តេចបានលើកទឹកចិត្តដល់វិស័យឯកជនឱ្យផ្តល់ឱកាសកាន់តែច្រើនដល់ សិស្ស និស្សិត ដែលកំពុងសិក្សានៅតាមបណ្តាសាកលវិទ្យាល័យ ឬវិទ្យាស្ថានអប់រំបច្ចេកវិទ្យានានាទទួលបាននូវវគ្គកម្មសិក្សាមួយមុននឹងបញ្ចប់ការសិក្សារបស់ខ្លួន ដើម្បីឱ្យសិស្ស និស្សិត ដែលជាយុវជនអាចទទួលបាន មិនត្រឹមតែចំណេះដឹង និងជំនាញខាងទ្រឹស្តីប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងអាចទទួលបាននូវកាលានុវត្តភាពថ្មី តាមរយៈការចូលរួម និងអនុវត្តផ្ទាល់ក្នុងមជ្ឈដ្ឋានការងារជាក់ស្តែង និងទី ៤.ជំរុញការចូលរួមរបស់យុវជនក្នុងសេវាសាធារណៈ និងសង្គមក្នុងបរិការណ៍សាកលភាវូបនីយកម្ម ។ សម្តេចពន្យល់ថា ការវិវត្តនៃរបបសង្គម និងការអភិវឌ្ឍឥតឈប់ឈរបានទាមទារឱ្យមានការគិតគូរឈរលើគោលការណ៍ចីរភាពបរិស្ថាន ។ ការចូលរួមរបស់យុវជនតាមរយៈចំណេះដឹង និងជំនាញរបស់ខ្លួន បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យបរិស្ថាន និងបេតិកភណ្ឌ ។

សូមបញ្ជាក់ថា សន្និសីទខាងលើនេះមានយុវជនជាសិស្ស និស្សិតប្រមាណ ៦២៩ នាក់ ពីសាលារៀនល្បីៗ មកពី ៤២ ប្រទេសក្នុងពិភពលោកចូលរួម ។ ក្នុងនោះតំបន់អាស៊ីមានចំនួន ២០ ប្រទេស អាមេរិក អឺរ៉ុប ១០ ប្រទេស អូសេអានី ៣ ប្រទេសនិងអាហ្វ្រិក៣ប្រទេស ។ក្នុងចំណោមនេះយុវជនកម្ពុជាមានចំនួន៦០នាក់ និងមានវាគ្មិនជាតិ និងអន្តរជាតិចំនួន ១២ រូប ។ សន្និសីទអន្តរជាតិនេះ ត្រូវបានធ្វើជារៀងរាល់ឆ្នាំចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ៧ ខែសីហា នៅបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងបានប្រារព្ធចំនួន ៤ លើករួចមកហើយ គឺឆ្នាំ ២០១០ នៅប្រទេសម៉ាឡេស៊ី ឆ្នាំ២០១១ នៅប្រទេសថៃ ឆ្នាំ២០១២ នៅប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០១៣ នៅប្រទេសហ្វីលីពីន ។ដោយឡែកសម្រាប់ឆ្នាំ២០១៤នេះ ក្រសួងទេសចរណ៍សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួងបរិស្ថាន ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការយូមែននីថេរៀន អាហ្វ៊ែរ យូខេ បានរៀបចំសន្និសីទអន្តរជាតិលើកទី ៥ នេះឡើង ក្រោមប្រធានបទ "រៀនគិត,រៀបផែនការ, អនុវត្ត " ។

✵ ព្រឹកថ្ងៃទី ១១ ខែសីហា សម្តេចតេជោបានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់សញ្ញាប័ត្រជូនដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យន័រតុនចំនួន ២ ៥០១ នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ។

ក្នុងឱកាសនោះ សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ថាចុងខែកក្កដា និងដើមខែសីហានេះ ដំណើរប្រក្រតីកម្មនៃស្ថាប័នរដ្ឋ និងប្រក្រតីភាពនៃជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជនកាន់តែត្រូវបានពង្រឹងតាមរយៈបណ្តាបក្សនយោបាយនៅក្នុងសភា ។សម្តេចបានបន្តថា សម្តេចបានប្រកាសចេញនូវយុទ្ធសាស្ត្រអំពីប្រក្រតីភាពនៃស្ថាប័នរដ្ឋទាំងនីតិបញ្ញត្តិ ទាំងនីតិប្រតិបត្តិ និងតុលាការ ។ ការអនុវត្តនូវការស្តាបនាជាតិ ការការពារសន្តិសុខសណ្តាប់ធ្នាប់សង្គម គឺដំណើរការជាធម្មតា ហើយវាកាន់តែល្អជាង ស្រួលជាងនៅពេលដែលការស្រុះស្រួលខាងនយោបាយមួយត្រូវបានរកឃើញ ។

សម្តេចតេជោបន្តថា សម្តេចបាននិយាយនៅក្នុងសភាថា បើស្មារតីនេះបានចាប់កំណើតពីមួយឆ្នាំមុន ឬ ១០ ខែមុននោះ វាគ្មានរឿងអ្វីកើតឡើងនោះទេ ។ បានន័យថា អ្វីដែលយើងបានធ្វើក្នុងរយៈពេលកន្លងទៅនោះ គឺត្រឹមត្រូវទាំងអស់ ។ ព្រះមហាក្សត្រចូលបើកកិច្ចប្រជុំសភាលើកដំបូងក៏ត្រឹមត្រូវ បង្កើតរាជរដ្ឋាភិបាលក៏ត្រឹមត្រូវ គឺត្រឹមត្រូវទាំងអស់ ហើយឥឡូវវាកាន់តែស្រួលទៀត ។ ព្រោះការពិតវាដដែលអត់មានលើស អត់មានខ្វះអ្វីទាំងអស់ ។

សម្តេចបន្តថា សកម្មភាពប្រក្រតីកម្មស្ថាប័នរដ្ឋ និងប្រក្រតីភាពនៃជីវភាពសេដ្ឋកិច្ច សង្គម របស់ប្រជាជនយើងក៏កាន់តែជំរុញឱ្យខ្លាំង ដំណើរការកំណែទម្រង់រដ្ឋលើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅនៅតែបន្តទៅមុខ ។យើងត្រូវមានការអត់ធ្មត់ ហើយយើងក៏មានមោទនភាពចំពោះជាតិយើងផងដែរ ពិតមែនតែមានរឿងនេះរឿងនោះកើតឡើងឥតឈប់ឈរ តែសារបានស្រុកខ្មែរឱ្យតែពេលបោះឆ្នោតម្តងគឺមានរឿងម្តង ។ ឆ្នាំ ១៩៩៨ ឆ្នាំ ២០០៣ ក៏មានរឿង ។ ឆ្នាំ ២០០៣ បង្កើតរដ្ឋាភិបាលអត់បានរយៈពេល ១ ឆ្នាំ ពិបាកជាងឥឡូវទៅទៀត ។ ដូចនេះយើងត្រូវរកកំណែទម្រង់មួយសម្រាប់ក្មេងជាន់ក្រោយ ដើម្បីកុំឱ្យវាមានបញ្ហាតទៅទៀត ។ យើងចេះរកការស្រុះស្រួលរវាងខ្មែរ និងខ្មែរដោយមិនចាំបាច់មានអន្តរាគមន៍ពីបរទេសឡើយ ។ ព្រោះរឿងអន្តរាគមន៍ពីបរទេសសម្តេចមិនត្រូវការទេ ។ សម្តេចត្រូវការការស្រុះស្រួលរវាងខ្មែរនិងខ្មែរ ។សម្តេចត្រូវការព្រះមហាក្សត្រខ្មែរ ព្រោះអ្នកប្រថាប់ត្រាធំជាងគេនៅស្រុកខ្មែរ គឺព្រះមហាក្សត្រខ្មែរ មិនមែនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ មិនមែនស្ថានទូតបរទេស ឬប្រធានាធិបតីបរទេសនោះទេ ។ គឺព្រះមហាក្សត្រខ្មែរ ។ សម្តេចយកស្មារតីនេះដាច់ខាត ។ ដូចនេះជាការអត់ប្រយោជន៍ទេដែលដើរទៅរកអន្តរាគមន៍ពីបរទេស ដើម្បីដោះស្រាយបញ្ហាផ្ទៃក្នុងនោះ ។

សម្តេចតេជោក៏បានលើកឡើងផងដែរ ពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋកម្ពុជាមួយចំនួនដែលត្រូវបានធ្លាក់ខ្លួនស្ថិតក្រោមបន្ទាប់ភាពក្រីក្រ ក៏ដោយសារថាពួកគេចាញ់បោកអ្នកនយោបាយ ។ ដោយសារតែការសន្យាទទួលតំណែងអ្វីមួយនៅពេលឈ្នះឆ្នោត ។ដូចនេះអ្នកខ្លះត្រូវអស់គោអស់ដី ។សមាជិកបក្សខ្លះត្រូវបានគណបក្សសន្យាផ្តល់តំណែង ។ ដូច្នេះអ្នកខ្លះលក់គោ ដើម្បីបានថវិកាជួយបក្ស ។ ក្រដោយសារលក់គោជួយបក្ស តែមកស្តីបន្ទោសនាយករដ្ឋមន្ត្រី បន្ទោសរដ្ឋាភិបាលថាមិនបានយកចិត្តទុកដាក់ ។ អ្នកនយោបាយទីបំផុតគឺជាអ្នកនយោបាយ ។

សម្តេចបានបន្តថា អ្នកនយោបាយប្រៀបបាននឹងទូកខ្លីដែលងាយនឹងបត់បែនណាស់ ។ មុននេះគេថាឆន្ទៈរបស់រាស្ត្រមិនឱ្យចូលសភា ដល់ឥឡូវគេថា ដើម្បីដោះស្រាយបញ្ហាឆន្ទៈរបស់រាស្ត្របានគឺត្រូវតែចូលរួមប្រជុំសភា ។ សម្តេចក៏បានដាស់តឿនប្រជាពលរដ្ឋថាកុំឱ្យមានការជ្រុលនិយមពេក ។ សម្តេចបានអំពាវនាវផងដែរថាការបោះឆ្នោតមួយមិនត្រូវឱ្យក្លាយជាការបែកបាក់ជាតិនោះទេ ។

✵ ព្រឹកថ្ងៃទី ១៨ ខែសីហា សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមបើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ នៅវិមានសន្តិភាព ។ ក្នុងពេលនោះ ប្រមុខរាជរដ្ឋាភិបាលព្រមានជាថ្មីទៀតចំពោះមន្ត្រីថ្នាក់ក្រោមអំពីបញ្ហាដីធ្លី ។

សម្តេចបានបញ្ជាក់ និងណែនាំដល់មន្ត្រីអាជ្ញាធរអំពីការអនុវត្តយុទ្ធសាស្ត្រស្បែកខ្លា ដោយអះអាងថា ទោះជាយ៉ាងណាគឺត្រូវតែឈរនៅខាងប្រជាជនក្នុងរឿងទំនាស់ដីធ្លីនេះ ។ សម្តេចបញ្ជាក់ថា រឿងនេះជារឿងច្រំដែលពេក ។ ភាពច្រំដែលនេះហើយដែលសម្តេចត្រូវតែនិយាយសារជាថ្មី ។ បើឃើញថា ដីហ្នឹងរវាងអ្នកវិនិយោគជាមួយនឹងដីប្រជាពលរដ្ឋមានការជាន់គ្នាក្នុងភាពមិនច្បាស់លាស់ ត្រូវផ្តល់អាទិភាពឱ្យទៅប្រជាពលរដ្ឋមុន មិនមែនផ្តល់អាទិភាពទៅឱ្យក្រុមហ៊ុនមុន

ទេ។ នៅក្នុងការបែងចែកដីធ្លីកន្លងមក ពេលខ្លះអាជ្ញាធរមូលដ្ឋានបានឃុបឃិតគ្នាដោយមានអន្តរាគមន៍ពីថ្នាក់លើផងនោះ បានកាត់ដីប្រជាពលរដ្ឋទៅឱ្យក្រុមហ៊ុនឯកជនទៀតផង។ សម្តេចបន្តថា យើងត្រូវនិយាយគ្នាម្តងដើម្បីឱ្យដឹងរឿងយូរៗទៅស្អីបន្តិចថាក្រោមការដឹកនាំរបស់លោក **ហ៊ុន សែន** ។ ឥឡូវសម្តេចត្រូវតែតាមដានមើល ហើយនិងតាមរករឿងទៀត។បើលោកឯងមិនធ្វើទេ ហើយថាការងារនោះ(ដីធ្លី) ធ្ងន់សម្រាប់ពួកអស់លោក។ លោកលាលែងចុះ។ សម្តេចជូនតាមសំណើ។ សម្តេចបានលើកជាសំណួរបើធ្វើរដ្ឋមន្ត្រី ធ្វើប្រធានស្ថាប័នមិនព្រមដោះស្រាយបញ្ហាជូនពលរដ្ឋកាន់តួនាទីធ្វើអី? ។

សម្តេចបានបញ្ជាក់ថា ពិតហើយមិនមែនរឿងណាសុទ្ធតែប្រជាពលរដ្ឋត្រូវទាំងអស់នោះទេ ព្រោះយុទ្ធសាស្ត្រឈ្នះបានដីចាញ់បានលុយវាមានច្រើនមិនតិចទេ។ ប្រជាពលរដ្ឋមិនដែលទៅនៅកន្លែងហ្នឹងទេ ប៉ុន្តែកន្លែងខ្លះ រយៈពេលត្រឹមតែ ២ យប់ ជួនកាលមួយកន្លែងធ្វើបាន ២០០ ផ្ទះ រួចហើយលើករូបថតនាយករដ្ឋមន្ត្រី ប្រពន្ធនាយករដ្ឋមន្ត្រី រហូតដល់ព្រះឆាយាលក្ខណ៍ព្រះមហាក្សត្រទៀតផង ដែលនេះជាយុទ្ធសាស្ត្រឈ្នះបានដីចាញ់បានលុយ។ សម្តេចតេជោបញ្ជាក់ថា ខ្ញុំអត់ចង់ឱ្យអាជ្ញាធរដែនដីដោះស្រាយបញ្ហាក្រុមអាធុនហ្នឹងទេ បើអីចឹងយកដីខ្ទេចហើយ ។ ក្រុមនេះបើចង់បានដីយើងមានដីធ្លីសម្រាប់ផ្តល់ជាសម្បទានសង្គមកិច្ចវិញ" ។

សម្តេចតេជោបានបន្តថា កន្លងមករឿងអស់នេះមកពីអស់លោកអភិបាលខេត្តមិនព្រមធ្វើរឿងស្ថានភាព ស្បែកខ្លានេះព្រោះក្នុងសេចក្តីជូនដំណឹងបានចែងថា នៅពេលដែលមានការវិនិយោគប៉ះពាល់ដល់ដីប្រជាជន គឺត្រូវផ្អាក។ ប៉ុន្តែអស់លោកមិនព្រមអនុវត្ត ។ វាមានកត្តាសត្យានុម័តរបស់វាដោយសារតែប្រជាពលរដ្ឋគាត់ទៅកាន់កាប់ដីធ្លីនៅកន្លែងហ្នឹងមិនមែនជាការកាន់កាប់ស្របច្បាប់ទេ ។ គាត់ទៅកាប់ទន្រ្ទានក្នុងពេលដែលយើងគិតថា ផែនទីដីធ្លីជាគម្របព្រៃឈើ ហើយគម្របព្រៃឈើយើងអត់ឱ្យប្រជាជនយើងទេ បែរជាយើងឱ្យទៅអ្នកវិនិយោគវិញ ។ ចំណុចអយុត្តិធម៌វានៅកន្លែងហ្នឹង។ ឥឡូវយើងពិនិត្យមើលថា កន្លែងនោះជាគម្របព្រៃឈើ ព្រៃរេចរិលប្រជាជនទៅតាំងទីលំនៅ ៤ ឬ ៥ ឆ្នាំហើយអត់ឱ្យគាត់បានទេប៉ុន្តែដល់អ្នកវិនិយោគស៊ីវិនិយោគបែរជាឱ្យបាន។ដូច្នេះបើគាត់តាំងទីលំនៅនៅទីនោះទៅហើយគឺឱ្យគាត់តែម្តងទៅ។

ក្នុងឱកាសនោះ សម្តេចតេជោបានលើកឡើងផងដែរ ទាក់ទងនឹងសន្តិសុខស្បៀង។ សម្តេចបញ្ជាក់ថា បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតែជាគោលដៅដ៏ចម្បងបំផុតមួយរបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាល កម្ពុជាទទួលស្គាល់ថាកម្ពុជានៅមានផ្លូវដ៏វែងឆ្ងាយសម្រាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសម្រេចបាននូវវឌ្ឍនភាព និងវិបុលភាពសម្រាប់ប្រជាជាតិរបស់ខ្លួន។ ក្នុងនោះ ការបន្តខិតខំដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលត្រូវដើរទន្ទឹមគ្នាជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

សម្តេចមានប្រសាសន៍ថា ជារួមកម្ពុជាបានឈរលើមូលដ្ឋានគ្រឹះកាន់តែរឹងមាំទោះបីស្ថានភាពកន្លងមកនេះ កម្ពុជាត្រូវប្រឈមដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ផលប៉ះពាល់ដោយសារឥទ្ធិពលនៃការប្រែប្រួលធាតុអាកាសទឹកជំនន់ និងការរាំងស្ងួតយ៉ាងណាក៏ដោយ ក៏កម្ពុជាបានធ្វើឱ្យសម្រេចជោគជ័យមានការរីកចម្រើនគ្រប់វិស័យ ទាំងខាងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងការបរទេស នៅក្នុងដំណើរការអភិវឌ្ឍន៍របស់ខ្លួន។ ជាក់ស្តែងកំណើនសេដ្ឋកិច្ចកម្ពុជាសម្រាប់ចន្លោះឆ្នាំ ២០០៨-២០១២ សម្រេចបានជាមធ្យម ៦,៨%។ នៅឆ្នាំ ២០១៣ កំណើនសេដ្ឋកិច្ចបានកើនដល់ ៧,៤% ក្នុងនោះផលិតផលសរុបក្នុងស្រុក "ផសស" សម្រាប់ប្រជាជនម្នាក់ៗបានកើនឡើងពី ៧៦០ ដុល្លារអាមេរិក នៅឆ្នាំ ២០០៨ ទៅដល់ចំនួន ១០៤៣ ដុល្លារ នៅឆ្នាំ ២០១៣ ហើយអាចកើនដល់ ១ ១៣០ ដុល្លារ នៅឆ្នាំ២០១៤ នេះ។ ដោយឡែក អត្រានៃភាពក្រីក្របានធ្លាក់មកនៅត្រឹម ១៩% នៅឆ្នាំ ២០១៣។ ប្រការទាំងនេះបានធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី ៥ ក្នុងចំណោមក្រុមប្រទេសកំពុងអភិវឌ្ឍន៍ ដែលនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មុនឆ្នាំ ២០១៥ ព្រមទាំងជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី ១ នៅអាស៊ីប៉ាស៊ីហ្វិកដែលសម្រេចបាននូវល្បឿនក្នុងការកែលម្អស្ទូចនាការផ្នែកសង្គមកិច្ច។ សម្តេចបានបន្តថា ទោះបីជាសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើន ហើយអត្រាកាត់បន្ថយភាពក្រីក្របានធ្លាក់ចុះដ៏គួរឱ្យកត់សម្គាល់ និងលទ្ធភាពក្នុងគ្រួសារដែលទទួលបានស្បៀង អាហារ និងការបរិភោគអាហារបានល្អប្រសើរឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏ប្រជាពលរដ្ឋកម្ពុជានៅតែប្រឈមមុខទៅនឹងឧបសគ្គជាច្រើន ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើសន្តិសុខស្បៀងរបស់គ្រួសារដោយសារផលិតភាព និងពិពិធកម្មកសិកម្មកម្ពុជានៅមានកម្រិតទាប។ការទទួលបាន និងការប្រើប្រាស់ធនធានជលផលនៅមានកម្រិត កង្វះការងារ និងឱកាសទទួលបានប្រាក់ចំណូលខ្ពស់ ជាពិសេសនៅជនបទ។ ការផ្គត់ផ្គង់ស្បៀងអាហារសម្រាប់ជនក្រីក្រ និងជនដែលរស់នៅក្បែរខ្សែបន្ទាត់ភាពក្រីក្រ ដែលងាយទទួលរងនូវវិបត្តិផ្ទាល់ខ្លួន និងវិបត្តិពីខាងក្រៅដោយសារកត្តាសង្គមសេដ្ឋកិច្ច និងគ្រោះធម្មជាតិ។

សម្តេចបញ្ជាក់ថា ឈរលើស្មារតីនេះ រាជរដ្ឋាភិបាលយល់ច្បាស់ពីភាពចាំបាច់នៃការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយចាត់ទុកកិច្ចការនេះថាជាលក្ខខណ្ឌមួយដ៏សំខាន់សម្រាប់ធានាការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចភាពចម្រុងចម្រើននៃសង្គមជាតិនិងសមធម៌សម្រាប់ពលរដ្ឋកម្ពុជាគ្រប់ៗរូប។ដូច្នេះយើងទាំងអស់គ្នាត្រូវខិតខំអនុវត្តសម្រេចឱ្យបាននូវចក្ខុវិស័យរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះ ដោយបន្តពង្រឹងកិច្ចខិតខំប្រឹងប្រែង និងអន្តរាគមន៍រួមគ្នា ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តយុទ្ធសាស្ត្រនេះ។

សម្តេចបានបន្ថែមថាជារួមបញ្ហាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនេះ មិនមែនជាបញ្ហានៃវិស័យសុខាភិបាល ឬកសិកម្មនោះទេ ប៉ុន្តែបញ្ហានេះជាប់ពាក់ព័ន្ធតួអង្គជាច្រើន ដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងរួមគ្នា ក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងអស់។ ក្នុងស្មារតីនេះ និងក្នុងគោលបំណងរួមចំណែកបន្ថែមទៅលើការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនេះឱ្យកាន់តែសកម្ម មានប្រសិទ្ធភាពខ្ពស់ ធានាបានជោគជ័យ សម្តេចនាយករដ្ឋមន្ត្រីបានសូមឱ្យក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្តោតការយកចិត្តទុកដាក់លើកិច្ចការសំខាន់ៗមួយចំនួនទៀត ក្នុងនោះ ទី១.ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវសម្របសម្រួលការដឹកនាំអនុវត្តគម្រោង និងកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើអាទិភាពនានាដែលបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងធានាលើកកម្ពស់សុខដុមនីយកម្មទៅនឹងកម្មវិធីផ្សេងៗទៀត និងពង្រឹងកិច្ចគាំទ្ររបស់ដៃគូអភិវឌ្ឍន៍នានាក្នុងវិស័យនេះឱ្យបានជាអតិបរមា។ ទី២.ក្រសួងស្ថាប័នពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវរៀបចំបង្កើតផែនការសកម្មភាពមួយច្បាស់លាស់ ដើម្បីធានាអនុវត្តបណ្តាសកម្មភាពជាអាទិភាពនានាដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រជាតិនេះ។ ទី៣.ត្រូវរៀបចំបង្កើតកម្មវិធី តាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងយន្តការផ្តល់របាយការណ៍មួយសមស្របដើម្បីធានាឱ្យការអនុវត្តយុទ្ធសាស្ត្រជាតិនេះទទួលបាននូវ

ប្រសិទ្ធភាព និងដើម្បីពិនិត្យបន្តកែលម្អគោលនយោបាយកម្មវិធី ក្នុងគោលបំណងអនុវត្តសកម្មភាពនិងអន្តរាគមន៍ឱ្យរិតតែមានប្រសិទ្ធភាពថែមទៀត ។ទី៤.ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍សង្គមស៊ីវិល និងវិស័យឯកជនត្រូវបន្តនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាលើយុទ្ធនាការផ្លាស់ប្តូរទម្លាប់ និងឥរិយាបថរបស់ប្រជាជន ដើម្បីឱ្យបានយល់ជ្រួតជ្រាបថា ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ គឺជាជម្រើសដ៏ល្អ និងប្រកបដោយសុខុមាលភាពជាជាងការបំបៅកូនដោយទឹកដោះសិប្បនិម្មិត និងត្រូវបង្កើតឱ្យមានសហគមន៍ និងមន្ទីរពេទ្យស្រឡាញ់ទារកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ទី៥.ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ត្រូវសហការគ្នាជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំទិវាជាតិអាហារូបត្ថម្ភ ដែលនឹងត្រូវប្រារព្ធធ្វើជារៀងរាល់ឆ្នាំ នាថ្ងៃទី ៦ ខែវិច្ឆិកា ដើម្បីលើកកម្ពស់ការយល់ដឹងពីអាហារូបត្ថម្ភនៅទូទាំងប្រទេស ស្របគ្នាជាមួយនឹងទិវាយល់ដឹងអាហារូបត្ថម្ភពិភពលោក ។ទី៦.គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចដែលបាននិងកំពុងធ្វើការលើសុវត្ថិភាពចំណីអាហារ ត្រូវបង្កើនកិច្ចសហការគ្នាឱ្យបានល្អប្រសើរ ដើម្បីធានាថា ទាំងស្បៀងអាហារនាំចូល និងស្បៀងអាហារផលិតនៅក្នុងប្រទេសកម្ពុជាត្រូវតែមានសុវត្ថិភាពខ្ពស់ និងគុណភាពល្អ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋ និងជាពិសេសដើម្បីការពារកុមារឱ្យចៀសផុតពីជំងឺផ្សេងៗនិងបញ្ហាកង្វះអាហារូបត្ថម្ភ ។ទី៧.ត្រូវជំរុញការផ្គត់ផ្គង់ទឹកស្អាតនៅជនបទការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យនៅតាមសាលារៀន មណ្ឌលសុខភាពផ្សារ និងសួនកំសាន្តនានា និងការលើកកម្ពស់អនាម័យដោយការលាងសម្អាតដៃជាមួយនឹងសាប៊ូដើម្បីកាត់បន្ថយជំងឺនានាដែលបណ្តាលមកពីការប្រើប្រាស់ទឹកកខ្វក់ និងការរស់នៅគ្មានអនាម័យ ដែលនឹងរួមចំណែកសំខាន់ផងដែរដល់ការផ្តល់អាហារូបត្ថម្ភកុមារនិងមាតា ។ទី៨.ត្រូវបង្កើតឱ្យមានគោលនយោបាយជាតិគោលការណ៍ណែនាំបច្ចេកទេសនិងលិខិតបទដ្ឋានគតិយុត្តិចាំបាច់នានាក្នុងការលើកកម្ពស់គុណភាពចំណីអាហារឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ។ ក្នុងនោះ ការពង្រីកការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារដែលសមស្រប មានដូចជា ការបញ្ចូលជីវជាតិអាទៅក្នុងប្រេងឆា ការបញ្ចូលមីក្រូសារជាតិចម្រុះទៅក្នុងអង្ករ ការបញ្ចូលអ៊ីយ៉ូដទៅក្នុងអំបិល ការបញ្ចូលជាតិដែកទៅក្នុងទឹកត្រី ទឹកស៊ីអ៊ីវជាដើម ដែលការដាក់បញ្ចូលកម្រិត ឬបរិមាណមីក្រូសារជាតិនីមួយៗ ត្រូវស្របតាមស្តង់ដារជាតិ និងជំរុញឱ្យមានការផ្សព្វផ្សាយពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិឱ្យបានទូលំទូលាយនៅទូទាំងប្រទេស ។

សម្តេចតេជោក៏បានអំពាវនាវចំពោះក្រសួងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូនិងភ្នាក់ងារអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ វិស័យឯកជន សហគមន៍ និងប្រជាពលរដ្ឋកម្ពុជាគ្រប់រូប សូមបន្តចូលរួមតាមគ្រប់រូបភាពក្នុងការជួយគាំទ្រ និងលើកកម្ពស់ការងារផ្តល់អាហារូបត្ថម្ភដល់កុមារ និងមាតា ព្រមទាំងលុបបំបាត់បញ្ហាអសន្តិសុខស្បៀង ដូចដែលរាជរដ្ឋាភិបាលតែងបានយកចិត្តទុកដាក់អនុវត្តជាប្រចាំនោះគឺ "មិនទុកឱ្យប្រជាជនណាម្នាក់ស្លាប់ដោយអត់បាយដោយយើងមិនបានដឹងនោះទេ" ។

❋ ព្រឹកថ្ងៃទី ២១ ខែសីហា សម្តេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់សញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ នៅវិទ្យាស្ថានជាតិអប់រំ ។ នាពេលនោះ សម្តេចបានមានប្រសាសន៍ ទាក់ទងនឹងការរៀបចំប្រព័ន្ធបៀវត្សរ៍មន្ត្រីរាជការមួយដែលត្រូវដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០១៥ ។

សម្តេចបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងកសាងប្រព័ន្ធបៀវត្សរ៍មួយ ។ បច្ចុប្បន្ន យើងមិនទាន់មានប្រព័ន្ធបៀវត្សរ៍ត្រឹមត្រូវនោះទេ គឺនៅដាច់ដោយឡែកៗពីគ្នា ហើយប្រព័ន្ធបៀវត្សរ៍មួយជាក់លាក់នឹងចាប់ផ្តើមអនុវត្តន៍នៅឆ្នាំ ២០១៥ ខាងមុខ បន្ទាប់ពីការធ្វើកំណែទម្រង់ប្រព័ន្ធបៀវត្សរ៍ឡើងវិញ ។

សម្តេចបញ្ជាក់ថា អាណត្តិទី ៤ កន្លងទៅ ក្របខណ្ឌបៀវត្សរបស់មន្ត្រីរាជការមាន ៤ ក្របខណ្ឌ គឺក្របខណ្ឌ "ក" ក្របខណ្ឌ "ខ" ក្របខណ្ឌ "គ" និងក្របខណ្ឌ "ឃ" ដោយក្នុងមួយក្របខណ្ឌមាន ៣០ ថ្នាក់ ដែលតម្រូវឱ្យ ធ្វើការ ៦០ ឆ្នាំទើបឆ្លងផុតមួយក្របខណ្ឌ ព្រោះ ២ ឆ្នាំ ត្រូវឡើងមួយកាំ ។ នៅក្នុងកំណែទម្រង់ថ្មី រាជរដ្ឋាភិបាលបានលុបចោលក្របខណ្ឌ "ឃ" ដោយបញ្ចូលក្របខណ្ឌ "ឃ" ដែលមានមនុស្សជាង ១០ ០០០ នាក់ ឱ្យមកនៅក្នុងក្របខណ្ឌ "គ" ។ ក្របខណ្ឌ "គ" ដែលមុននេះមាន ៣០ ថ្នាក់ ឱ្យមកនៅត្រឹមតែ ១០ ថ្នាក់ ។ ក្របខណ្ឌ "ខ" ដែលមុននេះមាន ៣០ ថ្នាក់ កាត់ឱ្យមកនៅត្រឹម ១៤ ថ្នាក់ ។ ក្របខណ្ឌ "ក" ដែលពីមុនមាន ៣០ ថ្នាក់ កាត់ឱ្យមកនៅត្រឹម ១៤ ថ្នាក់ ដែលនេះជាកំណែទម្រង់ថ្មីដើម្បីរៀបចំប្រព័ន្ធបៀវត្សរ៍សម្រាប់អនុវត្តនៅឆ្នាំ ២០១៥ ។

សម្តេចបន្ថែមថា ឥឡូវនេះយើងពុំទាន់មានប្រព័ន្ធបៀវត្សរ៍មួយពិតប្រាកដទេ ដូច្នេះប្រព័ន្ធបៀវត្សរ៍មួយត្រូវបានរៀបចំឡើងដោយធ្វើកំណែទម្រង់ ។

ពាក់ព័ន្ធការតម្លើងប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀន និងគ្រូពេទ្យ សម្តេចតេជោបានថ្លែងថា យោងតាមការអនុវត្តផែនការថវិកាពាក់កណ្តាលឆ្នាំ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើក្រសួងអប់រំ និងក្រសួងសុខាភិបាល ។ គឺជាក្រសួងអាទិភាពក្នុងការតម្លើងបៀវត្សមុនគេ ដោយសារថានៅក្នុងក្របខណ្ឌមន្ត្រីរាជការជាង ១៨ ម៉ឺននាក់ ក្នុងនោះគ្រាន់តែក្របខណ្ឌគ្រូបង្រៀនមួយ មានចំនួនជាង ១១ ម៉ឺននាក់ និងគ្រូពេទ្យមានជិត ៣ ម៉ឺននាក់ ។

សម្តេចបញ្ជាក់ថា សម្រាប់ក្របខណ្ឌគ្រូបង្រៀនដែលមានប្រាក់ខែច្រើនហើយពុំបានដំឡើងទៀតទេ តែដំឡើងសម្រាប់ក្របខណ្ឌគ្រូដែលមានប្រាក់ខែទាប ក្នុងនោះក្របខណ្ឌមន្ត្រីការិយាល័យនៅតាមសាលាគឺទាប បំផុត ៤២៤០០០ រៀល នោះនៅក្នុងខែកញ្ញាខាងមុខនឹងឡើងដល់ ៥០៥ ០០០ រៀល ។ ចាប់ពីខែមករាដល់ខែមីនាឆ្នាំ២០១៥នឹងឡើងដល់៥០៧.៨០០រៀល ហើយចាប់ពីខែមេសាទៅឡើងដល់ ៥៥២ ៨០០ រៀល ។ ចំណែកក្របខណ្ឌគ្រូបឋមសិក្សា ដែលមានរហូតដល់ទៅ ៥១ ៦១៥ នាក់ ដែលមានប្រាក់ខែទាបបំផុត ៤៨២ ៨០០ រៀលនោះ ចាប់ពីខែកញ្ញាទៅនឹងឡើងដល់ ៥៥០ ០០០ រៀល ។ ចាប់ពីខែមករាដល់ខែមីនា ឆ្នាំ ២០១៥ នឹងឡើងដល់ ៥៦៦ ៤៨០ រៀល ហើយចាប់ពីខែមេសាទៅនឹងឡើងដល់ ៦៤៦ ៤៨០ រៀល ។ អ្នកដែលទៅបង្រៀននៅតំបន់ដាច់ស្រយាលត្រូវបានបន្ថែមចំនួន ៨០ ០០០ រៀលទៀត ។ ចំណែកគ្រូមធ្យមសិក្សាបឋមភូមិ មានចំនួន ៣៣ ៨០៣ នាក់ ប្រាក់ខែទាបបំផុត ៥១៨ ០១០ រៀល ចាប់ពីខែកញ្ញាទៅឡើងដល់ ៥៩៤ ៤០០ រៀល និងចាប់ពីខែមករាដល់ខែមីនា ឆ្នាំ ២០១៥ ឡើងដល់ ៦៣៦ ០០០ រៀល និងចាប់ពីខែមេសាទៅនឹងឡើងដល់ ៦៦៦ ០០០ រៀល ។ ចំណែកគ្រូនៅវិទ្យាល័យមានចំនួន ៨ ៥២៥ នាក់ ប្រាក់ខែទទួលបច្ចុប្បន្នចំនួន ៦៦៩ ១៨០ រៀល ខែកញ្ញានឹងឡើងដល់ ៧៧៨ ៨០០ រៀល ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០១៥ ឡើងដល់ ៧៨៤ ៤០០ រៀល ។ ចំណែកគ្រូ នៅឧត្តមសិក្សាមានចំនួន ៧២៩ នាក់ ប្រាក់ខែបច្ចុប្បន្ន ៧២៦ ៩៣០រៀល ខែកញ្ញានឹងឡើងដល់ ៨៧៥ ៨០០ រៀល ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០១៥ ឡើងដល់ ៨៨១ ៤០០ រៀល ។ ករណីគ្រូគ្រប់កម្រិតទៅបង្រៀននៅតំបន់ដាច់ស្រយាលបន្ថែម៨០០០០រៀលក្នុង១ខែ ។ប្រាក់ខែខ្ពស់បំផុតនៅក្នុងក្រសួងអប់រំគឺ ១ ៦៧៦ ០០០ រៀល ពុំត្រូវបានតម្លើងទៀតទេ ។

សម្តេចតេជោបានបន្តថា ការតម្លើងប្រាក់ខែសម្រាប់គ្រូបង្រៀននេះ មួយឆ្នាំឡើងពីរដង ហើយឆ្នាំក្រោយនឹងឡើង ២ ដងទៀត ហើយបន្ទាប់មកនៅឆ្នាំក្រោយនៅពេលដែលប្រព័ន្ធបៀវត្សរ៍ត្រូវបានរៀបចំរួចហើយនោះ នឹងឡើងៗទាំងអស់គ្នាទាំងមន្ត្រីរាជការស៊ីវិល និងទាហានប៉ូលិស ។/

# សម្តេចចក្រី ហេង សំរិន បំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជួបសវនាការ និងសម្តែងការគួរសមជាមួយឯកឧត្តម **ង្វៀន ស៊ីងហ៊ុង***

នៅរសៀលថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១៤ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានធ្វើមាតុភូមិនិវត្តពីប្រទេសវៀតណាមវិញប្រកបដោយសុវត្ថិភាព បន្ទាប់ពីបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាមរយៈពេល ៣ ថ្ងៃ ប្រកបដោយជោគជ័យ តបតាមការអញ្ជើញរបស់ឯកឧត្តម **ង្វៀន ស៊ីងហ៊ុង** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

អញ្ជើញទៅទទួលសម្តេចប្រធានរដ្ឋសភាដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ រួមមាន ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី ១ រដ្ឋសភា ព្រមទាំងសមាជិក សមាជិកា រដ្ឋសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភាជាច្រើននាក់ ។ ដោយឡែកមន្ត្រីស្ថានទូតវៀតណាមប្រចាំកម្ពុជាក៏មានវត្តមានទទួលសម្តេចប្រធានរដ្ឋសភាដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញផងដែរ ។

នៅក្នុងសន្និសីទសារព័ត៌មាននៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភាដែលបានអមដំណើរសម្តេចប្រធានរដ្ឋសភាបានថ្លែងឱ្យដឹងថា នៅក្នុងដំណើរទស្សនកិច្ចរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ សីហា គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានជួបសវនាការ និងសម្តែងការគួរសមជាមួយ ឯកឧត្តម **ង្វៀន ហ៊្វូត្រុង** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ។ បន្ទាប់មក គណៈប្រតិភូបានជួបសវនាការសម្តែងការគួរសមជាមួយ ឯកឧត្តម **ទ្រឿង តិនសាង** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងសម្តែងការគួរសមជាមួយ ឯកឧត្តម **ង្វៀន តិនយុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាបានជួបសវនាការទ្វេភាគី និងសម្តែងការគួរសមជាមួយ ឯកឧត្តម **ង្វៀន ស៊ីងហ៊ុង** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ព្រមទាំងបានអញ្ជើញទៅទស្សនាកន្លែងប្រវត្តិសាស្ត្រសំខាន់ៗនៅរដ្ឋធានីហាណូយនៃប្រទេសវៀតណាម និងបានអញ្ជើញគោរពវិញ្ញាណក្ខន្ធវីរបុរសរបស់ប្រជាជនវៀតណាម ។

ឯកឧត្តម **ឈាង វុន** មានប្រសាសន៍បញ្ជាក់ថា សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានពិភាក្សាទ្វេភាគីជាមួយប្រធានរដ្ឋសភាវៀតណាម ក្នុងនាមប្រទេសជិតខាង និងជាសមាជិកអាស៊ានដូចគ្នា ។ នៅ ក្នុងជំនួបពិភាក្សាទ្វេភាគី បានបង្ហាញឱ្យឃើញពីជំហររបស់ប្រទេសទាំងពីរមានការយល់ស្របគ្នាថានឹងបន្តពង្រឹង និងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកើនដល់ទំហំ ៥ ០០០ លានដុល្លារអាមេរិកនៅឆ្នាំ ២០១៥ ដែលបច្ចុប្បន្ននេះទំហំពាណិជ្ជកម្មទើបតែមានត្រឹម ៣ ៥០០ លានដុល្លារអាមេរិកប៉ុណ្ណោះ ។ ភាគីទាំងពីរក៏បានឯកភាពគ្នាថាបន្តជំរុញឱ្យមានការបោះបង្គោលព្រំដែនរវាងប្រទេស ទាំងពីរឱ្យបានឆាប់ចប់សព្វគ្រប់ ដើម្បីប្រែក្លាយតំបន់ព្រំដែនទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ ក្នុងសហគមន៍តំបន់អាស៊ាន ស្របតាមសសរស្តម្ភទាំងបីរបស់អាស៊ាននៅឆ្នាំ ២០១៥ ។

ជាមួយនេះភាគីទាំងពីរក៏បានពិភាក្សាអំពីការផ្លាស់ប្តូរវប្បធម៌ទេសចរណ៍ ក៏ដូចជាការជំរុញថែមទៀតនូវកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នរដ្ឋសភាប្រទេសទាំងពីរ កម្ពុជា-វៀតណាម ដើម្បីធ្វើយ៉ាងណាឱ្យកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរដែលបានចុះហត្ថលេខាកន្លងមកមានដំណើរការកាន់តែល្អ ក្នុងនោះរួមមានទាំងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណផងដែរ ។ ភាគីវៀតណាមក៏បានសំណូមពរដល់កម្ពុជាយកចិត្តទុកដាក់ជួយជ្រោមជ្រែងចំពោះវិនិយោគិនវៀតណាមនៅកម្ពុជា ដូចជាវិនិយោគដំណាំកៅស៊ូជាដើម ធ្វើយ៉ាងណាឱ្យការវិនិយោគនេះដំណើរការទៅមុខបានល្អ ។

ឯកឧត្តម **ឈាង វុន** ក៏បានឱ្យដឹងដែរថា នៅក្នុងជំនួបពិភាក្សាជាមួយឯកឧត្តម **ង្វៀន តិនយុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ឯកឧត្តមនាយករដ្ឋមន្ត្រីបានជម្រាបសម្តេចប្រធានរដ្ឋសភា ស្នើឱ្យមានវិធានការផ្លូវច្បាប់ចំពោះមនុស្សមួយចំនួនជាខ្មែរកម្ពុជាក្រោម ដែលបានធ្វើបាតុកម្មនៅមុខស្ថានទូតវៀតណាម ហើយបានដុតទង់ជាតិវៀតណាម ។ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានជម្រាបទៅឯកឧត្តម **ង្វៀន តិនយុង** ថា "សម្តេចមានការសោកស្តាយចំពោះបញ្ហានេះ ហើយប្រទេសកម្ពុជាប្រកាន់គោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស គោរពនីតិរដ្ឋ ពុំអាចហាមឃាត់ការធ្វើបាតុកម្ម សម្តែងមតិបានទេ ប៉ុន្តែបើមានអំពើហិង្សាក៏ពុំអាចទទួលយកបានដែរ" ។

ឆ្លងតាមដំណើរទស្សនកិច្ចនៃគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានៅសាធារណរដ្ឋសង្គមនិយមវៀតណាមនាឱកាសនេះបានពង្រឹងឱ្យកាន់តែរឹងមាំថែមទៀតនូវចំណងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាលើគ្រប់វិស័យរវាងប្រទេសទាំងពីរ ដើម្បីផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា និងប្រជាជនវៀតណាម ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស




ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១៤ នៅទីស្នាក់ការគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តកំពង់ធំ ឯកឧត្តមបណ្ឌិត **ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ អនុប្រធានទី ១ រដ្ឋសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយគណៈអចិន្ត្រៃយ៍គណបក្សខេត្ត ប្រធានអនុប្រធានគណបក្សស្រុក-ក្រុងទាំង ៨ និងប្រធានអនុប្រធានគណបក្សមន្ទីជុំវិញខេត្តកំពង់ធំ ។ ខ្លឹមសារសំខាន់នៃកិច្ចប្រជុំ គឺដើម្បីត្រួតពិនិត្យ និងសម្របសម្រួលសេចក្តីព្រាងសេចក្តីសម្រេចសមាសភាពក្រុមការងាររបស់ស្រុកក្រុងចុះជួយឃុំ-សង្កាត់ទូទាំងខេត្ត និងផ្សព្វផ្សាយសភាពការណ៍នយោបាយចុងក្រោយចាប់ពីមានកិច្ចព្រមព្រៀងថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤។



*ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **គាត ឈន់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រីប្រចាំការ បានអញ្ជើញពិនិត្យសកម្មភាពវារីអគ្គិសនីកំចាយស្ថិតនៅខេត្តកំពត ។ វារីអគ្គិសនីនេះក្រោមការវិនិយោគរបស់សាជីវកម្មស៊ីណូហាយដ្រូនៃប្រទេសចិន ។*



ថ្ងៃទី ២ ខែសីហា ឆ្នាំ ២០១៤ លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋ-មន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ ក្នុងឱកាសដែលគ្រូពេទ្យស្ម័គ្រចិត្តនៃមន្ទីរពេទ្យ ២៦៤ ពេទ្យយោធាវរៈព្រំដែនខេត្តឡុងអានប្រទេសវៀតណាម ដឹកនាំដោយវរសេនីយ៍ឯក លឿង ត្រុងវូ ប្រធានគណៈប្រតិភូ កំពុងពិនិត្យជំងឺជូនប្រជាពលរដ្ឋចំនួន ៣០០ នាក់ នៅឃុំអង្គតាសូ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ក្នុងឱកាសនោះ លោកជំទាវ **ម៉ែន សំអន** បានផ្តល់អំណោយជូនប្រជាពលរដ្ឋទាំង ៣០០ នាក់ ដោយក្នុងម្នាក់ៗទទួលបានប្រេងឆា ១ ដប នំប៉័ង ១ ដើម ស្ករស ១ គ.ក្រ និងមី ១០ កញ្ចប់ ផងដែរ ។



*ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសាភិបាលធនាគារជាតិនៃកម្ពុជា ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយស្រុកសន្ទុក បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាជននៅស្រុកស្ទោង ខេត្តកំពង់ធំ និងពិនិត្យសំណង់អគារសិក្សានៅវិទ្យាល័យរស្មីសោភណ្ឌ និងអនុវិទ្យាល័យសំព្រោចក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



*ថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយផ្ដល់ជូនកុមារកំព្រានៅបូរីកុមារមិត្តភាព កម្ពុជា-បារាំង-ហុងគ្រី និងកុមារកំព្រាមកពីមជ្ឈមណ្ឌលគៀនឃ្លាំង នៅក្នុងភូមិបារគូ ឃុំបារគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។*





ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម បានអញ្ជើញចុះពិនិត្យស្ថានភាពធារាសាស្ត្រនៅតាមបណ្ដាស្រុកមួយចំនួនរបស់ខេត្តពោធិសាត់ ។



ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលនៃគណៈអភិបាលខេត្តតាកែវបានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខប្រជាជននៅរមណីយដ្ឋានទន្លេបាទីខេត្តតាកែវ ដែលក្នុងឱកាសនោះ ឯកឧត្តមក៏បានប្រកាសដីកាបញ្ចប់កិច្ចសន្យាស្ដីពីការបន្តជួលដី និងទីតាំងដើម្បីអភិវឌ្ឍន៍រមណីយដ្ឋានទន្លេបាទីរបស់ក្រុមហ៊ុនលោកស្រី សុខ សារឿន និងបានប្រគល់ឱ្យប្រជាពលរដ្ឋសហគមន៍ជាអ្នកលក់ដូរនៅទីនោះកាន់កាប់វិញ ។

*ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៤ ឯកឧត្តម **ច័ន្ទ សុផល** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង បានអញ្ជើញចូលរួមជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ៨ គីឡូម៉ែត្រ នៅក្នុងឃុំតាពូង និងឃុំតាម៉ឺន នៃស្រុកថ្មគោល ខេត្តបាត់ដំបង ។*

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

## ចំណូលពន្ធដារក្នុងខែកក្កដា និងរយៈពេល ៧ ខែ :

អគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ថា នៅក្នុងខែកក្កដា ឆ្នាំ២០១៤ នេះ ពន្ធដាររកបានចំណូលពន្ធប្រមាណ ៣៦៤,១៨ ពាន់លានរៀល ឬប្រមាណ ៩១,១ លានដុល្លារអាមេរិក។ ចំណូលខែកក្កដានេះ បើប្រៀបធៀបនឹងចំណូលខែកក្កដា ឆ្នាំ ២០១៣ គឺមានកំណើនដល់ទៅ ៣៣,៧% ដែលក្នុងនោះថវិការដ្ឋមានកំណើនស្មើនឹង ១៥,២%។

ដោយឡែកក្នុងរយៈពេល ៧ ខែនៃឆ្នាំ ២០១៤ នេះដែរ ពន្ធដាររកចំណូលបានសរុបស្មើនឹង៦២,៧% នៃគោលដៅកំណត់ក្នុងច្បាប់ថវិកា ក្នុងនោះថវិការដ្ឋសម្រេចបាន ៦៥,៣% និងថវិកាថ្នាក់ក្រោមជាតិសម្រេចបាន ៤៦,៩៧%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា (៧ខែ) នៃឆ្នាំ ២០១៣ ចំណូល ៧ ខែនៃឆ្នាំ ២០១៤ មានកំណើនស្មើនឹង ១៦,១%។

បើតាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះ ប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ៣១,៧% ពន្ធលើប្រាក់ចំណេញកើនឡើង ២៥,៥% អាករលើតម្លៃបន្ថែមកើនឡើង ១៦,៥% និងអាករពិសេសកើនឡើង ៨,១%។ បើប្រៀបធៀបទៅនឹងរយៈពេល ៧ ខែដូចគ្នានៃឆ្នាំ ២០១៣ ឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០,៤៦%។ ផ្នែកស្ថាបត្យកម្ម និងសំណង់កើនឡើង ៦៥,៩៥%។ ផលិតភេសជ្ជៈកើនឡើង ២១,២%។ ផ្នែកផលិតសម្លៀកបំពាក់កើនឡើង ៤៦,៣៥%។ ផ្នែកសណ្ឋាគារ ផ្ទះសំណាក់ កើនឡើង ៤០,២%។ ផ្នែកផលិតថ្នាំជក់កើនឡើង ១៣,៤៥%។ លក់ភេសជ្ជៈកើនឡើង ២៧,៤៨%។ ផលិតម្ហូបអាហារកើនឡើង ៨១,៩៥%។ ផ្នែកលក់សម្ភារៈការិយាល័យ កើនឡើង ៤០,៦%។ ផ្នែកលក់គ្រឿងយន្ត កើនឡើង ៦៤,៤៥% និងផ្នែកលក់គ្រឿងសំណង់ក៏កើនខ្លាំងដែរ គឺ ២ ៥៨៣,៧%។

ចំពោះមុខដើម្បីគ្រប់គ្រងចំណូលពន្ធដារឱ្យមានស្ថិរភាពលើវិស័យមួយចំនួនដែលមានសក្តានុពលចំណូលច្រើននោះ អគ្គនាយកដ្ឋានពន្ធដារមានគោលការណ៍ និងទិសដៅសំខាន់ៗមួយចំនួន ក្នុងនោះ មានបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ប្រកបដោយប្រសិទ្ធភាពខ្ពស់នូវសារាចរណែនាំលេខ ០០១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០១៤ ដោយទទួលបានការឯកភាពពីសម្តេចតេជោ **ហ៊ុន សែន** ។ បន្តជំរុញអនុវត្តគោលការណ៍ និងផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារឱ្យដូចភ្លៀងរលឹម ជាពិសេស យុទ្ធនាការនៃការចាត់បញ្ជូនទៅរបបស្វ័យប្រកាសនូវអាជីវកម្មបង់ពន្ធតាមរបបម៉ៅការដែលមានផលរបរខ្ពស់។ ពង្រឹងការអនុវត្តប្រកាសស្តីពីការទូទាត់ចំណូលពន្ធដើម្បីពង្រឹងការប្រមូលបំណុល។បន្តជំរុញល្បឿនការងាររៀបចំកម្មវិធីចរចារបស់គណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំការចរចាកិច្ច ព្រមព្រៀងយកពន្ធត្រួតគ្នា។ បន្តកែលម្អការគ្រប់គ្រង និងទិន្នន័យរបស់អ្នកជាប់ពន្ធឱ្យបានប្រសើរជាងមុនប្រកបដោយតម្លាភាព និងគណនេយ្យភាព។ បន្តរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍ និងសារព័ត៌មាន។ បន្តរៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារនៅកម្ពុជា ។ ជំរុញបញ្ចប់ជាស្ថាពរនូវការបង្កើតមជ្ឈមណ្ឌលរក្សាទុកទិន្នន័យ។ បន្តអប់រំណែនាំមន្ត្រីគ្រប់លំដាប់ថ្នាក់ឱ្យធ្វើការផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិត ការផ្តល់សេវាជូនអ្នកជាប់ពន្ធ។

## ការនាំចេញអង្ករ រយៈពេល៧ខែ :

យោងតាមតួលេខពីលេខាធិការដ្ឋាននៃច្រកចេញចូលតែមួយសម្រាប់សម្របសម្រួលការនាំចេញអង្ករកម្ពុជា បានឱ្យដឹងថា រយៈពេលពីខែមករា ដល់ខែកក្កដា ការនាំចេញអង្កររបស់កម្ពុជាគឺមានចំនួន ២០៤ ០០០ តោន ។ ជាមួយនឹងតួលេខនេះ បើធៀបនឹងតួលេខនៃការនាំចេញរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ គឺមានការធ្លាក់ចុះ ១,៦%។ រយៈ៧ខែនៃឆ្នាំ២០១៣ ការនាំចេញអង្ករមានចំនួន២០៧ ៣៧០ តោន។ ប៉ុន្តែនៅពេលនេះ អង្ករកម្ពុជាត្រូវបានពង្រីកការនាំចេញទៅរហូតដល់ទៅ ៥៤ ប្រទេសនៅក្នុងពិភពលោក។

ប្រធានក្រុមហ៊ុននាំចេញអង្ករមួយរូបនៅក្នុងចំណោមក្រុមហ៊ុននាំចេញធំៗចំនួន ៦ ដែលកំពុងតែនាំអង្ករ ចេញទៅកាន់ទីផ្សារអន្តរជាតិបានឱ្យដឹងថា ការធ្លាក់ចុះនេះគឺដោយសារតែការប្រកួតប្រជែងពីប្រទេសនាំចេញអង្ករដទៃទៀត ជាពិសេស គឺថៃ និងឥណ្ឌា។ តម្លៃនៃអង្កររបស់កម្ពុជា គឺមិនអាចលក់ថោកជាងអង្កររបស់ប្រទេសថៃ និងឥណ្ឌា ព្រមទាំងប្រទេសវៀតណាមបានទេដោយសារតែខ្សែសង្វាក់ផលិតកម្មអង្ករ ពោលគឺថ្លៃដើមកិនអង្ករ និងការដឹកជញ្ជូនរបស់កម្ពុជាគឺខ្ពស់ជាងប្រទេសទាំងនោះ។

ដោយឡែកនៅក្នុងរយៈពេលនេះដែរ បណ្តាប្រទេសនៅអឺរ៉ុបដែលធ្លាប់ជាម៉ូយបញ្ជាទិញអង្ករពីកម្ពុជា ក៏ហាក់ដូចជាថយចុះដែរ ដោយសារតែការប្រកួតប្រជែងពីប្រទេសនាំចេញអង្ករធំៗទាំងនេះ។

នៅក្នុងរយៈពេល៧ខែនៃឆ្នាំ២០១៤នេះ ប្រទេសដែលទិញអង្ករពីកម្ពុជាច្រើនជាងគេគឺប៉ូឡូញ បារាំង ហូឡង់ ម៉ាឡេស៊ី បែលហ្ស៊ិក ឆែក និងចិន។

## ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា_អាមេរិក កម្ពុជា_ជប៉ុន ឆមាស_ទីមួយ :

នៅឆមាសទីមួយឆ្នាំ២០១៤នេះ កម្ពុជានាំចេញទៅកាន់អាមេរិកមានតម្លៃប្រមាណ ១ ៤០២ លានដុល្លារ ។ រីឯទំហំនៃការនាំចេញរបស់អាមេរិកចូលមកកាន់ទីផ្សារនៅក្នុងប្រទេសកម្ពុជាវិញ គឺមានតម្លៃ ១៥៧ លានដុល្លារ។

សកម្មភាពនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារនៅអាមេរិក គឺមានការកើនឡើងប្រមាណ ៥,៨% រីឯទំហំ ទំនិញដែលកម្ពុជានាំចូលពីអាមេរិកមកវិញ គឺមានកំណើនប្រមាណ ២៦%។

គួររំឭកថា កាលពីឆមាសទីមួយឆ្នាំ២០១៣ តម្លៃទំនិញសរុបដែលកម្ពុជានាំចេញទៅកាន់ទីផ្សារនៅអាមេរិក គឺមានតម្លៃ ១ ៣២៤លានដុល្លារ តែប៉ុណ្ណោះ។ រីឯទំនិញដែលអាមេរិកនាំចូលមកកាន់ប្រទេសកម្ពុជាវិញនោះ គឺមានតម្លៃប្រមាណ ១២៤,៦លានដុល្លារ។

ទំនិញដែលកម្ពុជានាំចេញទៅកាន់អាមេរិក គឺមានផលិតផលពីរោងចក្រកាត់ដេរ មានសម្លៀកបំពាក់ និង ស្បែកជើង។ ផលិតផលកសិកម្មមួយចំនួន ដូចជា អង្ករ និងនាំចូលមកវិញ មានរថយន្ត ថ្នាំ និងគ្រឿងបរិក្ខា ពេទ្យជាដើម។

ដោយឡែក យោងទៅតាមតួលេខដែលផ្សព្វផ្សាយដោយអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុនបាន ឱ្យដឹងថា ក្នុងរយៈពេល៦ខែឆ្នាំ ២០១៤ នេះ កម្ពុជានាំចេញទៅជប៉ុនមានតម្លៃប្រមាណ ៣៤៥ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៤៣,៥%។ ចំណែកកម្ពុជានាំចូលទំនិញពីជប៉ុនមកវិញមានតម្លៃប្រមាណ ១១០ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៣%។

## វិស័យធានារ៉ាប់រងឆមាសទីមួយ :

ឆមាសទីមួយឆ្នាំ ២០១៤ វិស័យសេវាកម្មធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា

តទៅទំព័រទី ២២

# កម្ពុជា និង ការអភិវឌ្ឍ ដំណាំកៅស៊ូ







*ដំណាំកៅស៊ូដែលកំពុងពេញប្រមូលផលជ័រកៅស៊ូ*

ដំណាំកៅស៊ូមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់សេដ្ឋកិច្ចជាតិ ព្រោះដំណាំនេះផ្ដល់នូវវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកៅស៊ូក្នុងស្រុក និងនាំចេញ ហើយផ្ដល់ការងារដល់ប្រជាជនយើងបានមួយចំនួនធំ ។

ដំណាំកៅស៊ូមានប្រភពដើមនៅប្រទេសប្រេស៊ីល ហើយនាំចូលមកប្រទេសកម្ពុជាដោយក្រុមហ៊ុនបារាំងកាលពីឆ្នាំ ១៩២០ ។ កាលនោះដំណាំកៅស៊ូមានដាំភាគច្រើននៅតំបន់ដីក្រហមក្នុងខេត្តកំពង់ចាម ក្រចេះ រតនគិរី និងក្រុងព្រះសីហនុ ។ មុនឆ្នាំ ១៩៧០ ចម្ការកៅស៊ូកម្ពុជាមាន ៦៧ ០០០ ហ.ត ឱ្យផល ៥២០០០ តោន ក្នុងមួយឆ្នាំ ។ ក្នុងឆ្នាំ ១៩៩៩ ផ្ទៃដីដំណាំកៅស៊ូដែលអាចចៀរជ័របានមានត្រឹម៣៩៧១៨ហិកតាផ្ដល់ផលជ័រស្ងួតបាន៤៥២០៣តោន ហើយបញ្ចេញលក់ជ័រស្ងួតបាន៤៤ ៣៧៦ តោន ។ ប្រទេសកម្ពុជាមានលទ្ធភាពច្រើនណាស់ក្នុងការពង្រីកដំណាំកៅស៊ូ ព្រោះនៅកម្ពុជាគ្រាន់តែដីក្រហមដែលផ្ដល់ភាពអនុគ្រោះបំផុតដល់ដំណាំកៅស៊ូមានរហូតដល់ទៅ ៧១៦ ០០០ ហ.ត ។

តាមរបាយការណ៍របស់ក្រសួងកសិកម្មបានឱ្យដឹងថា គិតចាប់ពីឆ្នាំ ១៩៩៦ មកទល់នឹងបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់ដីសម្បទានសេដ្ឋកិច្ចទៅដល់ក្រុមហ៊ុនសរុបចំនួន ១១៧ ក្រុមហ៊ុន ស្មើនឹងផ្ទៃដីសរុបជាង ១ លាន ៥ សែន ហ.ត ក្នុងនោះមានជិតមួយលានហិកតាដែលអាចដាំដុះកៅស៊ូបាន ។ ផ្ទៃដីទាំងនោះត្រូវបានកាន់កាប់ដោយក្រុមហ៊ុនក្នុងស្រុកចំនួន ៣៩ ក្រុមហ៊ុន នៅលើផ្ទៃដី៥៩៣ ០០០ ហ.ត ។ ក្រុមហ៊ុនវៀតណាមមាន ៣១ ក្រុមហ៊ុន លើផ្ទៃដី ២៣១ ០០០ ហ.ត ។ ក្រុមហ៊ុនចិន ២៥ ក្រុមហ៊ុន លើផ្ទៃដី ១៩៣ ០០០ ហ.ត ។ ក្រុមហ៊ុនកូរ៉េ ( កូរ៉េខាងត្បូង) មានចំនួន ៥ ក្រុមហ៊ុន នៅលើផ្ទៃដី ៣៧ ០០០ ហ.ត ។ ក្រុមហ៊ុនថៃចំនួន ៥ ក្រុមហ៊ុន លើផ្ទៃដី៣៨០០០ ហ.ត ។ ក្រុមហ៊ុនអាមេរិកចំនួន២ ក្រុមហ៊ុន នៅលើផ្ទៃដី ១៩ ០០០ ហ.ត ។ ក្រុមហ៊ុន ឥណ្ឌាចំនួន ៣ ក្រុមហ៊ុន លើផ្ទៃដី ១៧ ០០០ ហ.ត ។ ក្រុមហ៊ុនម៉ាឡេស៊ី មានចំនួន ៣ ក្រុមហ៊ុន លើផ្ទៃដី ២៣ ០០០ ហ.ត ។ ក្រុមហ៊ុនអូស្ត្រាលីមាន ១ ក្រុមហ៊ុន នៅលើផ្ទៃដី ៨ ៩៧៧ ហ.ត ។ ក្រុមហ៊ុនស៊ុយអ៊ែតមានចំនួន ១ ក្រុមហ៊ុន ។ ក្រុមហ៊ុនសិង្ហបុរីមានចំនួន ១ ក្រុមហ៊ុន និងក្រុមហ៊ុនអ៊ីស្រាអែល មានចំនួន ១ ក្រុមហ៊ុន ។ ក្រុមហ៊ុនទាំងនោះបានវិនិយោគទៅលើដំណាំកសិឧស្សាហកម្ម ដែលភាគច្រើនជាដំណាំកៅស៊ូ និងអំពៅ ។

សម្ព័ន្ធឧស្សាហកម្មកៅស៊ូរបស់ប្រទេសវៀតណាម ដែលបានទទួលសិទ្ធិដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា គ្រោងបោះទុនវិនិយោគក្នុងទំហំទឹកប្រាក់១០០០លានដុល្លារអាមេរិក ដើម្បីធ្វើការដាំដំណាំកៅស៊ូនៅក្នុងខេត្តចំនួន ៧ នៃប្រទេសកម្ពុជារួមមាន : រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ធំ ព្រះវិហារ សៀមរាប និងស្ទឹងត្រែង ដោយសម្រេចការដាំដុះបានចំនួន ៨៥ ០០០ ហ.ត គិតមកដល់ដំណាច់ឆ្នាំ ២០១៣ ហើយគ្រោងនឹងបន្តដាំឱ្យសម្រេចបាន ១០ ម៉ឺនហ.ត នៅឆ្នាំ ២០១៥ ។

តាមរបាយការណ៍ពីខេត្តមណ្ឌលគិរីបានឱ្យដឹងថា ការវិនិយោគលើដំណាំកៅស៊ូក្នុងខេត្តនេះក៏កំពុងមានការកើនឡើងជាលំដាប់ ។ ជាក់ស្ដែង



*កម្មករចម្ការកៅស៊ូកំពុងប្រមូលផលជ័រកៅស៊ូ*



*ម៉ាស៊ីនកែច្នៃជ័រកៅស៊ូ*

គិតមកទល់នឹងបច្ចុប្បន្ននេះផ្ទៃដីដាំកៅស៊ូរាប់បញ្ចូលទាំងក្រុមហ៊ុន និងលក្ខណៈគ្រួសារបានកើនឡើងដល់ប្រមាណជាង ៣២ ០០០ ហ.ត ។

ក្នុងរបាយការណ៍ពីខេត្តកំពង់ធំក៏បានឱ្យដឹងដែរថា នៅខេត្តមួយនេះមានផ្ទៃដីដាំកៅស៊ូដែលបានមកពីការ ផ្ដល់ដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ១ សែន ហ.ត ហើយក្នុងចំណោមផ្ទៃដីទាំងនេះគឺមានក្រុមហ៊ុនបរទេសចំនួន ៨ កំពុងធ្វើការវិនិយោគដាំកៅស៊ូសុទ្ធសាធ ។

ចំណែកឯក្នុងរបាយការណ៍ពីខេត្តព្រះវិហារវិញបានបញ្ជាក់ឱ្យដឹងថា គិតមកទល់នឹងបច្ចុប្បន្ន នៅក្នុងខេត្តព្រះវិហារមានក្រុមហ៊ុនកំពុងវិនិយោគលើដីសម្បទានសេដ្ឋកិច្ចចំនួន៣៣ក្រុមហ៊ុនហើយក្នុងចំណោមក្រុមហ៊ុនទាំងនេះ គឺមានក្រុមហ៊ុនចំនួន ៥ ដែលធ្វើការវិនិយោគលើដំណាំអំពៅ ក្រៅពីនេះគឺដំណាំកៅស៊ូ ។ ទន្ទឹមនេះ ក្នុងពេលបច្ចុប្បន្ននេះក៏មានក្រុមហ៊ុនរបស់ប្រទេសចិនមួយឈ្មោះ CHINA GREAT CAUSE (CAMBODIA) INVESTMENT Co., Ltd បាននឹងកំពុងដាំដំណាំកៅស៊ូលើដីសម្បទានសេដ្ឋកិច្ចលើផ្ទៃដីចំនួន ៥ ៩៨០ ហ.ត បន្ថែមទៀត ។ តាមរបាយការណ៍នោះបានឱ្យដឹងបន្ថែមថា យ៉ាងយូរបំផុតនៅឆ្នាំ ២០១៨ ក្នុងខេត្តនេះនឹងមានរោងចក្រសម្ងួតកៅស៊ូដើម្បីធ្វើការនាំចេញ ។

គួរកត់សម្គាល់ថា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះការនាំចេញជ័រកៅស៊ូធម្មជាតិរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិបានកើនឡើងជាលំដាប់ ។ បើតាមរបាយការណ៍ពីក្រសួងពាណិជ្ជកម្មបានឱ្យដឹងថានៅក្នុងឆ្នាំ២០១៣កន្លងទៅ កម្ពុជាបានធ្វើការនាំចេញកៅស៊ូក្រែបក្នុងបរិមាណ ៧៤ ១៩៨ តោន គឺកើនឡើងប្រមាណជា ៣៤% បើធៀបនឹងឆ្នាំ ២០១២ ដែលមានបរិមាណតែ ៥៥ ៣៨៤ តោន ។ ការនាំចេញកៅស៊ូក្រែបក្នុងឆ្នាំ ២០១៣ កន្លងទៅនេះ គឺមានតម្លៃជាទឹកប្រាក់ប្រមាណ ១៧០ លានដុល្លារអាមេរិក កើនឡើងចំនួន ៦% ធៀបនឹងឆ្នាំ ២០១២ ដែលមានតម្លៃត្រឹមតែប្រមាណ ១៦០ លានដុល្លារអាមេរិក ប៉ុណ្ណោះ ។ ដោយឡែកការនាំចេញកៅស៊ូធម្មជាតិសរុបក្នុងត្រីមាសទី ១ ឆ្នាំ ២០១៤ នេះ កើន ២៦% ពី ១៥ ០១៨ តោន ដល់ ១៩ ០៤១ តោន ធៀបនឹង រយៈពេលដូចគ្នាកាលពីឆ្នាំ២០១៣ ។ ប៉ុន្តែចំណូលបានពីការនាំចេញបានធ្លាក់ចុះ ២៨% ។ អគ្គលេខាធិការនៃសមាគមសម្រាប់ការអភិវឌ្ឍកៅស៊ូរបស់កម្ពុជាបានឱ្យដឹងថា មូលហេតុដែលតម្លៃកៅស៊ូរបស់កម្ពុជាធ្លាក់ចុះនៅដើមឆ្នាំ ២០១៤ នេះ ដោយសារឥទ្ធិពលពីផែនការរបស់ប្រទេសថៃ ដែលគ្រោងនឹងលក់ចេញកៅស៊ូពីស្តុករបស់ខ្លួនក្នុងបរិមាណដ៏ច្រើន ។

ការអភិវឌ្ឍដំណាំកៅស៊ូមានសន្ទុះកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ នៅតាមបណ្ដាខេត្តនានា ។ បច្ចុប្បន្នមានផ្ទៃដីដាំដុះដំណាំកៅស៊ូសរុបបានកើនដល់ ៣២៨ ០០០ ហ.ត ដែលភាគច្រើនជាកៅស៊ូក្មេង មិនទាន់អាចចៀរយកជ័របាន ក្នុងនោះសមាមាត្រនៃផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន ៤២% ចម្ការកៅស៊ូសម្បទានសេដ្ឋកិច្ចមានចំនួន៤១%និងចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានចំនួន ១៧% ជាមួយនឹងផ្ទៃដីចៀរជ័រកៅស៊ូជាង ៧៨ ០០០ ហ.ត ដែលមានបរិមាណផលិតគិតជាជ័រស្ងួតជិត ៩ ម៉ឺនតោន (ឆ្នាំ ២០១៣) សម្រាប់នាំចេញទៅបរទេស ។ បរិមាណនេះបើប្រៀបធៀបនឹងឆ្នាំ ២០១២ គឺកើនលើសជាង ៣២% ។

នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៥ នេះ ក៏បានបញ្ជាក់ដែរថា រាជរដ្ឋាភិបាលនឹងបន្តផ្ដោតការយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍដំណាំកៅស៊ូឱ្យរីកចម្រើនទាំងបរិមាណ និងគុណភាព ឱ្យក្លាយជាវិស័យដ៏មានសក្ដានុពល និងភាពប្រកួតប្រជែង តាមរយៈការពង្រីកការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់ ដោយបន្តអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ឆ្នាំ២០១១-២០២០ ។ ក្នុងគោលនយោបាយនោះផងដែរ រាជរដ្ឋាភិបាលនឹងធ្វើឱ្យផ្ទៃដីដាំកៅស៊ូកើនឡើងដល់ជាង ៤៥ ម៉ឺនហិកតា ដែលអាចនឹង ផ្ដល់ជ័រកៅស៊ូបានប្រមាណពី ៤០ ម៉ឺន តោន ទៅ ៥០ម៉ឺនតោន នៅឆ្នាំ ២០២០ ។ មានប្រសាសន៍កាលពីថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០១៣ នៅក្នុងពិធីសម្ពោធបើកឱ្យដំណើរការរោងចក្រកែច្នៃជ័រកៅស៊ូនៅខេត្តស្ទឹងត្រែង តម្លៃ ៧ លានដុល្លារអាមេរិក សម្រាប់កែច្នៃជ័រកៅស៊ូដែលដាំលើដីចំនួន ៣ ៨០០ ហ.ត នៅតំបន់មានរោងចក្រនោះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានវាយតម្លៃថា ដំណាំកៅស៊ូកំពុងតែចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ហើយអនាគតដីដាំកៅស៊ូនៅប្រទេសកម្ពុជាមានកាន់តែច្រើនជាងមុន គឺអាចលើសប្រទេសវៀតណាមទៅទៀត ដោយសារតែវៀតណាមអស់ផ្ទៃដីសម្រាប់ពង្រីកទៀតហើយ ។/



*រោងចក្រផលិតជ័រកៅស៊ូក្រែប*

# អនុត្តរភាពទឹក : ការដ្ឋានចំនួន ២៦ បាននិងកំពុងដំណើរការ

*ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញពីបំណងអនុត្តរភាពទឹកទន្ទឹមនឹងមហិច្ឆតាក្នុងការនាំអង្ករចេញឱ្យបានមួយលានតោននៅឆ្នាំ ២០១៥ ខាងមុខ ។ ផ្តើមពីគោលបំណងទាំងពីរនេះ រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៤ និងទី ៥ ដោយមានក្រសួងធនធានទឹក និងឧតុនិយមជាសេនាធិការ បាននិងកំពុងដំណើរការយ៉ាងសកម្ម ដើម្បីបង្កើននូវសមត្ថភាពផ្គត់ផ្គង់ទឹកសម្រាប់ការបង្កើនលទ្ធភាពផលិតផលកសិកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ពិសេសនៅតំបន់ជនបទ ។*



*ការដ្ឋានស្តារប្រឡាយភូមិពោធិ៍ ស្ថិតក្នុងស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់*

នៅក្នុងឆ្នាំ ២០១៤ នេះ ក្រសួងធនធានទឹក និងឧតុនិយមបានអនុវត្តគម្រោងការងារសាងសង់ជួសជុលនិងស្តារប្រព័ន្ធធារាសាស្ត្រនៅក្នុងក្របខណ្ឌទូទាំងប្រទេសចំនួន ២៦ ការដ្ឋាន។ ក្នុងចំណោមការដ្ឋានទាំង ២៦ នេះ មានការដ្ឋានដែលអនុវត្តបន្តពីឆ្នាំ ២០១៣ មានចំនួន ៩ ការដ្ឋាន និងការដ្ឋានត្រូវអនុវត្តក្នុងឆ្នាំ ២០១៤ មានចំនួន ១៧ ការដ្ឋាន ។

ដោយឡែក គិតត្រឹមដំណាច់ខែឧសភាកន្លងទៅ ការដ្ឋានចំនួន ១៧ ដែលត្រូវអនុវត្តនៅក្នុងឆ្នាំ ២០១៤ នេះ សម្រេចបាននូវលទ្ធផលមួយចំនួន។ បណ្តាការដ្ឋានទាំងនោះមាន :



*ការដ្ឋានជួសជុលទំនប់អាងទឹកស្បាតផ្ទោល ស្ថិតក្នុងឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល*

### ១-ការដ្ឋានជួសជុលទំនប់សណ្តរការពារទឹកជំនន់តាមាស

ការដ្ឋាននេះស្ថិតនៅឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល ។ ការដ្ឋាននេះគឺត្រូវជួសជុលទំនប់សណ្តរការពារទឹកជំនន់តាមាសដែលមានប្រវែង ២ ៤០០ ម៉ែត្រ សាងសង់សំណង់ទ្វារទឹកលើទំនប់ ( ទ្វារ ៤) ចំនួន ១ កន្លែង និងសាងសង់សំណង់លូជ្រុងលើទំនប់ចំនួន ១ កន្លែង ។ អត្ថប្រយោជន៍នៃគម្រោងគឺអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងបានចំនួន ១៦១ ហ.ត ដំណាំរួមផ្សំចំនួន ៣០ ហ.ត និងការពារផ្ទៃដីលំនៅស្ថានបានចំនួន ១៥០ ហ.ត ។ ប្រជាពលរដ្ឋទទួលផលពីគម្រោងនេះមានចំនួន២០៧ គ្រួសារ ស្មើនឹង ១ ២០៨នាក់ ។ ជាលទ្ធផលការងារ គឺសម្រេចបានប្រមាណ ៦៥% ។

### ២-ការដ្ឋានជួសជុលទំនប់អាងទឹកត្រពាំងឈូក

ការដ្ឋាននេះស្ថិតនៅក្នុងឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ។ ការដ្ឋាននេះ ត្រូវជួសជុលទំនប់អាង ដែលមានប្រវែង ៣ ៩៦០ ម៉ែត្រ និងសាងសង់សំណង់លូបញ្ចេញទឹកលើទំនប់ ( ១០០ ស.ម) ចំនួន ៤ កន្លែង ។ ទំនប់នេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងចំនួន ៦៥០ ហ.ត និងដំណាំរួមផ្សំចំនួន ១០ ហ.ត ។ ប្រជាពលរដ្ឋទទួលផលពីគម្រោងនេះមានចំនួន ៣១៩ គ្រួសារ ស្មើនឹង ១ ២៤២ នាក់ ។ ការដ្ឋាននេះ សម្រេចបានប្រមាណ ៦៥% ។

### ៣-ការដ្ឋានស្តារប្រព័ន្ធប្រឡាយស្រោចស្រព ២០ ឧសភា

ការដ្ឋាននេះស្ថិតនៅក្នុងស្រុកបរិបូណ៌ និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ទំហំការងារគឺស្តារប្រឡាយរង ខ្សែទី ១ ប្រវែង ១ ៦០០ ម៉ែត្រ ស្តារប្រឡាយរងខ្សែទី ២ ប្រវែង ២ ១០០ ម៉ែត្រ ស្តារប្រឡាយរងខ្សែទី ៣ ប្រវែង ២ ២០០ ម៉ែត្រ ស្តារប្រឡាយរងខ្សែទី ៤ ប្រវែង ២ ០០០ ម៉ែត្រ ស្តារប្រឡាយរងខ្សែទី ៥ ប្រវែង ២ ៣០០ ម៉ែត្រ ចាក់បេតុងជើងទេរប្រឡាយរងខ្សែទី ១ និងខ្សែទី ២ ប្រវែង ៣០ ម៉ែត្រ សាងសង់សំណង់លូ ស្ទាក់ទឹក ២ ជួរ ( ១០០ ស.ម) ចំនួន ១០ កន្លែង សាងសង់សំណង់លូដោះទឹក ( ៨០ ស.ម) ចំនួន ៦ កន្លែង សាងសង់សំណង់លូយកទឹក ២ ជួរ ( ១០០ ស.ម) ចំនួន ២ កន្លែង ។ ការដ្ឋានមួយនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងបានចំនួន ១ ៩៩៦ ហ.ត និងដំណាំរួមផ្សំចំនួន ២៥ ហ.ត ។ ប្រជាពលរដ្ឋចំនួន ៤០៣ គ្រួសារ ស្មើនឹង ២ ១៩១ នាក់នឹងទទួលផលអំពីគម្រោងនេះ ។ ជាលទ្ធផលការដ្ឋាននេះសម្រេចបានប្រមាណ ៧០% ។

### ៤-ការដ្ឋានស្តារប្រឡាយមេលេខ ១ និងសាងសង់សំណង់សិល្បការ

ការដ្ឋាននេះស្ថិតនៅឃុំរូងជ្រៃ និងឃុំបន្សាយត្រែង ស្រុកថ្មគោល ខេត្តបាត់ដំបង ។ ការដ្ឋាននេះត្រូវស្តារប្រឡាយមេលេខ ១ ប្រវែង ៨០០ ម៉ែត្រ សាងសង់សំណង់ស្ទាក់ទឹក( ទ្វារ ២) លើប្រឡាយមេចំនួន ១ កន្លែង សាងសង់សំណង់ស្ទាក់ទឹក ( ទ្វារ២) លើប្រឡាយមេចំនួន ២ កន្លែង សាងសង់សំណង់លូជ្រុងលើប្រឡាយមេចំនួន ២ កន្លែង សាងសង់សំណង់លូយកទឹក ( ១០០ ស.ម)



ការដ្ឋានជួសជុលទំនប់អាងទឹកបឹងផ្ទោល ស្ថិតក្នុងឃុំរកា និងឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង

ចំនួន ៨ កន្លែង សាងសង់សំណង់លូដោះទឹក (៨០ ស.ម) ចំនួន ៦ កន្លែង ។ គម្រោងគឺអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ១ ០៦៧ ហ.ត ស្រូវរដូវប្រាំងបានចំនួន ២ ៧៨៥ ហ.ត និងដំណាំរួមផ្សំបានចំនួន ១០ ហ.ត ។ ប្រជាពលរដ្ឋចំនួន ១ ៣៤៣ គ្រួសារ ស្មើនឹង ៥ ១៩៨ នាក់ នឹងទទួលផលពីគម្រោងនេះ ។ ជាលទ្ធផលការងារគឺសម្រេចបានប្រមាណ ៧០% ។

### ៥_ការដ្ឋានស្តារប្រព័ន្ធប្រឡាយស្រោចស្រពស្វាយដូច

ការដ្ឋាននេះស្ថិតនៅឃុំជ័យធំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ការដ្ឋាននេះត្រូវស្តារប្រឡាយរងស្វាយដូច ប្រវែង ១ ៨៥០ ម៉ែត្រ ស្តារប្រឡាយរងត្រពាំងត្រកួនប្រវែង ១ ៥៥០ ម៉ែត្រ ស្តារប្រឡាយរង ដើមពោធិ៍ ប្រវែង ៩៥០ ម៉ែត្រ សាងសង់សំណង់លូយកទឹក (១០០ ចម) ចំនួន ៩ កន្លែង សាងសង់សំណង់លូដោះទឹក (៤០ ស.ម) ចំនួន ១០ កន្លែង សាងសង់សំណង់លូយកទឹក (១០០ ស.ម) ចំនួន ១ កន្លែង ។ ការដ្ឋានមួយនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងបានចំនួន ៣១៥ ហ.ត និងដំណាំរួមផ្សំបានចំនួន ១០ ហ.ត ។ ប្រជាពលរដ្ឋចំនួន ៤១៥ គ្រួសារ ស្មើនឹង ១ ៦៨៤ នាក់ នឹងទទួលផលពីគម្រោងនេះ ។ ជាលទ្ធផលការងារគឺសម្រេចបានប្រមាណ ៧០% ។

### ៦_ការដ្ឋានជួសជុលទំនប់អាងទឹកស្បាតផ្តោល

ការដ្ឋាននេះស្ថិតនៅឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ។ តាមគម្រោងគឺត្រូវជួសជុលទំនប់ប្រវែង ២ ៩៩៥ ម៉ែត្រ សាងសង់សំណង់លូបញ្ចេញទឹកលើទំនប់ (១០០ស.ម) ចំនួន ៤ កន្លែង ។ ការដ្ឋាននេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងបានចំនួន ១៥៦ ហ.ត និងដំណាំរួមផ្សំចំនួន ១០ ហ.ត ។ ប្រជាពលរដ្ឋចំនួន ១២៥ គ្រួសារ ស្មើនឹង ៥៥០នាក់ ។ ជាលទ្ធផលសម្រេចបានប្រមាណ ៧០% ។

### ៧_ការដ្ឋានស្តារប្រឡាយមេត្នោតពោន

ការដ្ឋាននេះស្ថិតនៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ការដ្ឋានមួយនេះត្រូវស្តារប្រឡាយមេ ដែលមានប្រវែង ៣ ៦៣៧ ម៉ែត្រ សាងសង់សំណង់ទ្វារទឹកទ្វារ ២ លើប្រឡាយចំនួន ១ កន្លែង សាងសង់សំណង់ស្ពានបេតុងលើប្រឡាយចំនួន ១ កន្លែង សាងសង់សំណង់លូ ៨០ ស.ម លើប្រឡាយចំនួន ១ កន្លែង សាងសង់សំណង់ទ្វារទឹក (ទ្វារ ១) លើប្រឡាយចំនួន ១ កន្លែង ។ ការដ្ឋាននេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ៤៧២ ហ.ត ស្រូវរដូវប្រាំងចំនួន ១៦៣ ហ.ត និងដំណាំរួមផ្សំចំនួន ២៤ ហ.ត ។ ប្រជាពលរដ្ឋចំនួន ២០៨ គ្រួសារ ស្មើនឹង ១ ១០១ នាក់ នឹងទទួលផលពីគម្រោងនេះ ។ ជាលទ្ធផលសម្រេចបានប្រមាណ ៦០% ។

### ៨_ការដ្ឋានស្តារប្រឡាយលេខ ៣

ការដ្ឋាននេះស្ថិតនៅក្នុងឃុំបូរីជលសារ ស្រុកបូរីជលសារ ខេត្តតាកែវ ។ ការដ្ឋាននេះត្រូវស្តារប្រឡាយប្រវែង ៧ ២០០ ម៉ែត្រ សាងសង់សំណង់លូដោះទឹក ៨០ ស.ម លើប្រឡាយចំនួន ១០ កន្លែង ។ ក្រោយបញ្ចប់ ការដ្ឋានអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ១៥ ០៤០ ហ.ត ។ ប្រជាពលរដ្ឋទទួលផលពីគម្រោងនេះមានចំនួន ២ ០៨០ គ្រួសារ ស្មើនឹង ៩ ៥៦៩ នាក់ ។ ការងារនេះសម្រេចបានប្រមាណ ៦០% ។

### ៩_ការដ្ឋានជួសជុលប្រព័ន្ធស្រោចស្រពទួលព្រះឃ្លាំង

ការដ្ឋាននេះ ស្ថិតនៅក្នុងឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ ការដ្ឋាននេះត្រូវជួសជុលទំនប់អាងទឹកប្រវែង ៣ ១០០ ម៉ែត្រ ស្តារប្រឡាយប្រវែង ១ ០០០ ម៉ែត្រ សាងសង់សំណង់លូជ្រុងយកទឹកទ្វារ ១ លើអូរចំនួន ២ កន្លែង ជួសជុលសំណង់លូជ្រុងយកទឹកទ្វារ ១ លើទំនប់ចំនួន ១ កន្លែង ជួសជុលសំណង់ទ្វារទឹក ទ្វារ ៣ លើទំនប់ចំនួន ១ កន្លែង ។ គម្រោងនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ១០០ ហ.ត ស្រូវរដូវប្រាំងចំនួន ២ ៩២០ ហ.ត និងដំណាំរួមផ្សំចំនួន ២៥ ហ.ត ។ ប្រជាពលរដ្ឋទទួលផលពីគម្រោងនេះមានចំនួន ៣ ៥៩៦ គ្រួសារ ស្មើនឹង ១៥ ៩៩៤ នាក់ ។ ជាលទ្ធផលគឺសម្រេចបានប្រមាណ ៦០% ។

### ១០_ការដ្ឋានជួសជុលប្រព័ន្ធស្រោចស្រពសិដា

ការដ្ឋាននេះស្ថិតនៅក្នុងឃុំបូសលាវ ស្រុកចិត្របូរី ខេត្តក្រចេះ ។ ការដ្ឋានមួយនេះត្រូវជួសជុលទំនប់អាងទឹកប្រវែង ២ ៣០០ ម៉ែត្រ ស្តារប្រឡាយសិដាខ្សែទី ១ ប្រវែង ១ ០០០ ម៉ែត្រ ស្តារប្រឡាយសិដាខ្សែទី ២ ប្រវែង ១ ០០០ ម៉ែត្រ សាងសង់សំណង់បង្ហៀរប្រវែង ២០ ម៉ែត្រ សង់ទ្វារ ២ លើទំនប់ចំនួន ១ កន្លែង សាងសង់សំណង់បង្ហៀរប្រវែង ២០ ម៉ែត្រ លើទំនប់ចំនួន ១ កន្លែង ជួសជុលសំណង់ទ្វារទឹក ទ្វារ ២ លើទំនប់ចំនួន ២ កន្លែង ជួសជុលសំណង់លូជ្រុងទ្វារ ១ លើទំនប់ចំនួន ២ កន្លែង ។ គម្រោងមួយនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវប្រាំងចំនួន ៧៨៦ ហ.ត និងដំណាំរួមផ្សំចំនួន ២៥ ហ.ត ។ ប្រជាពលរដ្ឋចំនួន ៦៨១ គ្រួសារ ស្មើនឹង ៣ ៣០៩ នាក់ នឹងទទួលផលពីគម្រោងនេះ ។ ជាលទ្ធផលការងារ គឺសម្រេចបានប្រមាណ ៦០% ។

### ១១_ការដ្ឋានសាងសង់សំណង់បង្ហៀរទំនប់ធារាំង

ការដ្ឋាននេះស្ថិតនៅក្នុងឃុំផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ កា



ការដ្ឋានស្តារប្រឡាយមេ និងសាងសង់សំណង់សិល្បការ លើប្រឡាយមេ ១ ស្ថិតនៅក្នុង ឃុំសូយោង និងឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

រដ្ឋាននេះត្រូវសាងសង់សំណង់បង្ហៀរប្រវែង ៧៤ ម៉ែត្រ ចំនួន ១ កន្លែង ។ ទំនប់នេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ៣៧៤ ហ.ត ស្រូវរដូវប្រាំងចំនួន ២ ១៤៦ ហ.ត និងដំណាំរួមផ្សំចំនួន ៣០៦ ហ.ត ។ ប្រជាពលរដ្ឋចំនួន ១ ៤០៤ គ្រួសារ ស្មើនឹង ៦ ៦០២ នាក់ នឹងទទួលផលពីគម្រោងនេះ ។ ជាលទ្ធផលសម្រេចបានប្រមាណ ៦០% ។

### ១២_ការដ្ឋានស្ដារប្រឡាយមេគំនោរ

ការដ្ឋាននេះស្ថិតនៅក្នុងឃុំព្រះនេតព្រះ ស្រុកព្រះនេតព្រះ ខេត្តបន្ទាយ-មានជ័យ ។ តាមគម្រោងត្រូវជួសជុលភ្លឺប្រឡាយប្រវែង ៤០០ ម៉ែត្រ ស្តារប្រឡាយប្រវែង ៧ ៦០០ ម៉ែត្រ សាងសង់សំណង់ទ្វារទឹកទ្វារ ១០ លើប្រឡាយចំនួន ១ កន្លែង សាងសង់សំណង់លូជ្រុងទ្វារ ១ លើប្រឡាយចំនួន ៣ កន្លែង សាងសង់សំណង់ស្នាក់ទឹកទ្វារ២លើប្រឡាយចំនួន២កន្លែងសាងសង់សំណង់លូ ៨០ ស.ម លើប្រឡាយចំនួន ៨ កន្លែង ។ គម្រោងនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ៩ ៨១២ ហ.ត ស្រូវរដូវប្រាំងបានចំនួន ២ ០១៨ ហ.ត ។ ប្រជាពលរដ្ឋទទួលផលពីគម្រោងនេះចំនួន ៤ ៦៧០ គ្រួសារ ស្មើនឹង ២១ ៦០៦ នាក់ ។ ជាលទ្ធផលសម្រេចបានប្រមាណ ៦៥% ។

### ១៣_ការដ្ឋានជួសជុលប្រព័ន្ធស្រោចស្រពអន្លង់រុត

ការដ្ឋាននេះស្ថិតនៅក្នុងឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមាន-ជ័យ ។ តាមគម្រោងនឹងត្រូវជួសជុលទំនប់អាងប្រវែង ២ ៦៨០ ម៉ែត្រ ស្តារប្រឡាយមេខ្សែទី ៣ ប្រវែង ១ ៤០០ ម៉ែត្រ សាងសង់សំណង់ទ្វារទឹក ទ្វារ ១០ លើទំនប់ចំនួន ១ កន្លែង សាងសង់សំណង់លូជ្រុងទ្វារ ១ លើទំនប់ចំនួន ១ កន្លែង សាងសង់សំណង់លូ ជ្រុងទ្វារ ១ លើក្បាលប្រឡាយទី ១ ចំនួន ១ កន្លែង សាងសង់សំណង់លូជ្រុងទ្វារ១ លើក្បាលប្រឡាយទី ២ ចំនួន ១ កន្លែង សាងសង់សំណង់លូជ្រុងទ្វារ១លើក្បាលប្រឡាយទី៣ចំនួន១កន្លែងសាងសង់សំណង់លូជ្រុងស្នាក់ទឹកទ្វារ ១ លើប្រឡាយទី ៣ ចំនួន ១ កន្លែង សាងសង់សំណង់ទ្វារទឹកទ្វារ ៣ លើប្រឡាយទី ៣ ចំនួន ១ កន្លែង សាងសង់សំណង់លូ ៨០ ស.ម ប្រវែង ៦ ម៉ែត្រ លើប្រឡាយទី ៣ ចំនួន ២ កន្លែង ។ គម្រោងអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ១ ៥៦៧ ហ.ត ស្រូវរដូវប្រាំង និងដំណាំរួមផ្សំចំនួន ២៤២ ហ.ត ប្រជាពលរដ្ឋចំនួន ៧៤៨ គ្រួសារ ស្មើនឹង២៦៤២នាក់នឹងទទួលផលពីគម្រោងនេះ ។ជាលទ្ធផលការងារសម្រេចបានប្រមាណ ៦៥% ។



ការដ្ឋានជួសជុលប្រព័ន្ធស្រោចស្រពអន្លង់រុត ស្ថិតក្នុងឃុំស្វាយចេក ខេត្តបន្ទាយមានជ័យ

### ១៤_ការដ្ឋានស្ដារប្រឡាយរងក្រាំងលាវ

ការដ្ឋាននេះស្ថិតនៅក្នុងឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ។ ការដ្ឋាននេះនឹងត្រូវស្តារប្រឡាយរងក្រាំងលាវខ្សែទី ១ ប្រវែង ១ ៧៣៥ ម៉ែត្រ សាងសង់សំណង់ស្នាក់ទឹកទ្វារ ២ លើប្រឡាយចំនួន ១ កន្លែង ។ ក្រោយស្តាបនារួចប្រឡាយនេះអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ៤៥៤ ហ.ត និងស្រូវរដូវប្រាំងបានចំនួន ៣៣២ ហ.ត ហើយប្រជាពល-រដ្ឋចំនួន ៦៥៥ គ្រួសារស្មើនឹង ៣ ១៣៣ នាក់ នឹងទទួលបានប្រយោជន៍ពីប្រឡាយនេះ ។ គិតត្រឹមខែឧសភាការដ្ឋាននេះសម្រេចបានប្រមាណ ៦០% ហើយ ។

### ១៥_ការដ្ឋានជួសជុលទំនប់អាងទឹកសែនពារាម

ការដ្ឋាននេះស្ថិតនៅក្នុងឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ការ-ដ្ឋានមួយនេះ ត្រូវជួសជុលទំនប់ អាងទឹកដែលមានប្រវែង ១ ៥០០ ម៉ែត្រ សាងសង់សំណង់បង្ហៀរលើទំនប់ចំនួន ១ កន្លែង សាងសង់សំណង់លូជ្រុងទ្វារ ១ លើទំនប់ ចំនួន ១ កន្លែង ។ នៅពេលបញ្ចប់នឹងអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ១៥០ ហ.ត និងស្រូវរដូវប្រាំងចំនួន ២៣១ ហ.ត ហើយប្រជាពលរដ្ឋចំនួន ៣៦៥ គ្រួសារ ស្មើនឹង ២ ៣៩២ នាក់ នឹងទទួលបានផលពីទំនប់នេះ ។ ជាលទ្ធផលការងារគឺសម្រេចបានប្រមាណ ៦៥% ។

### ១៦_ការដ្ឋានជួសជុលទំនប់អាងទឹកត្រពាំងវែង

ការដ្ឋាននេះស្ថិតនៅសង្កាត់កូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។ ការដ្ឋាននេះត្រូវជួសជុលទំនប់ អាងទឹកដែលប្រវែង ១ ៨៥០ ម៉ែត្រ សាងសង់សំណង់ស្នាក់ទឹក ទ្វារ៤ លើទំនប់ចំនួន ១ កន្លែង ។គម្រោងអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ៦០០ ហ.ត ស្រូវរដូវប្រាំងបានចំនួន ៣១០ ហ.ត និងដំណាំរួមផ្សំបានចំនួន ២៥ ហ.ត ។ ប្រជាពលរដ្ឋចំនួន ៧៣៤ គ្រួសារ ស្មើនឹង ៣ ១៣៨ នាក់ នឹងទទួលបានផលពីគម្រោងនេះ ។ ជាលទ្ធផលការងារគឺសម្រេចបានប្រមាណ ៦០% ហើយ ។

### ១៧_ការដ្ឋានស្ដារប្រឡាយរងភូមិថ្មី

ការដ្ឋាននេះស្ថិតនៅឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ការដ្ឋាននេះត្រូវស្តារប្រឡាយរងប្រវែង ២ ៥៥០ ម៉ែត្រ សាងសង់សំណង់ស្នាក់ទឹកទ្វារ ១ លើប្រឡាយចំនួន ១ កន្លែង សាងសង់សំណង់លូ ៨០ ស.ម លើប្រឡាយចំនួន ២ កន្លែង ។ គម្រោងអាចផ្តល់ទឹកសម្រាប់ការស្រោចស្រពផ្ទៃដីស្រូវរដូវវស្សាបានចំនួន ២៧០ ហ.ត ស្រូវរដូវប្រាំងចំនួន ១៤០ ហ.ត ហើយប្រជាពលរដ្ឋចំនួន ២៧៩គ្រួសារ ស្មើនឹង ១ ២៨៨នាក់ នឹងទទួលបានផលប្រយោជន៍ពីគម្រោងនេះ ។ ជាលទ្ធផលការងារគឺសម្រេចបានប្រមាណ ៦៥% ហើយ ។

ពិតណាស់ ដោយមិននិយាយអំពីការដ្ឋានចំនួន ៩ ដែលកំពុងអនុវត្តបន្តពីគម្រោងនៃឆ្នាំ ២០១៣ នោះ និយាយដោយឡែកតែគម្រោងការដ្ឋានចំនួន ១៧ សម្រាប់ឆ្នាំ ២០១៤ នេះ គឺគម្រោងទាំងនេះនៅពេលបញ្ចប់ នឹងផ្តល់ផលប្រយោជន៍ដល់ការស្រោចស្រពស្រូវរដូវវស្សា ស្រូវប្រាំង ដំណាំរួមផ្សំ និងប្រជាជនយ៉ាងច្រើនអនេក គឺអាចធានាដល់ការស្រោចស្រពស្រូវវស្សាចំនួន ២៩ ៩០៦ ហ.ត ស្រូវប្រាំងចំនួន ១៤ ៧០៩ ហ.ត ដំណាំរួមផ្សំ ៧៤២ហ.ត ។ ប្រជាជនចំនួន ១៨ ២៣២ គ្រួសារ ស្មើនឹង ៦១ ៦៤២ នាក់ នឹងទទួលបានផលប្រយោជន៍ពីគម្រោងនេះ ។/

# ចាត់គ្រប់វិធានការ និងប្រើគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់ការខាតបង់ធ្ងន់ធ្ងរ ដោយគ្រោះទឹកជំនន់នៅឆ្នាំ ២០១៤ នេះ





*កាកបាទក្រហមកម្ពុជា និងសាខា ព្រមទាំងសប្បុរសជននានា ចុះផ្តល់អំណោយសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ នៅខេត្តស្ទឹងត្រែង ខេត្តត្បូងឃ្មុំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តកំពង់ធំ ខេត្តរតនគិរី*

គ្រោះទឹកជំនន់ឆ្នាំនេះ ថ្វីបើមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរខ្លាំងដូចគ្រោះទឹកជំនន់មុនៗដល់ផលដំណាំ លំនៅ ស្ថានភូមិស្រុករបស់ប្រជាជន និងហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែចំនួនមនុស្សស្លាប់គិតត្រឹមថ្ងៃទី ១៩ ខែសីហា មាន ៤៥ នាក់ និងប៉ះពាល់ដល់ខេត្តចំនួន ១២ ។ រាជរដ្ឋាភិបាលកម្ពុជា កាកបាទក្រហមកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន និងសប្បុរសជននានាបានយកចិត្តទុកដាក់ក្នុងការជួយសង្គ្រោះ និងការឧបត្ថម្ភជាបន្ទាន់ដល់អ្នករងគ្រោះ ដោយសារទឹកជំនន់បានទាន់ពេលវេលា។

គួរបញ្ជាក់ថា ចាប់ពីសប្តាហ៍ទី ៣ ខែកក្កដា មក ប្រព័ន្ធសម្ពាធទាបមួយបានកើតឡើងបង្កឱ្យមានភ្លៀងធ្លាក់ជោកជាំនៅតំបន់អាងទន្លេ មេគង្គរួមមានប្រទេសឡាវ ថៃ និងកម្ពុជា ហើយស្ថានភាពនេះ បណ្តាលឱ្យទឹកទន្លេមេគង្គជន់ឡើងជាលើកទី ១ ដែលកម្រិតកម្ពស់ទឹកនៅស្ថានីយខេត្តក្រចេះមានរហូតដល់ ១៩,២៨ ម៉ែត្រ នៅ ថ្ងៃទី ២៦ខែកក្កដា។ នៅដំណាច់ខែកក្កដា សម្ពាធទាបមួយទៀតបានកើតមានឡើងនៅក្នុងប្រទេសឡាវ និងវៀតណាមភាគកណ្តាល រួមជាមួយនឹងជ្រលងសម្ពាធទាបដែលកំពុងគ្របដណ្តប់លើកម្ពុជា បានបង្កឱ្យមានភ្លៀងធ្លាក់បន្ថែមទៀតនៅអាងទន្លេមេគង្គតំបន់ខ្ពង់រាបនិងតំបន់ឆ្នេរសមុទ្រកម្ពុជា ហើយតំបន់ទំនាបកណ្តាលមានភ្លៀងធ្លាក់ក្នុងកម្រិតមធ្យម។ ស្ថានភាពនេះ បានធ្វើឱ្យបណ្តាខេត្តតាមដងទន្លេមេគង្គ និងតំបន់ខ្ពង់រាបមួយ ចំនួនក្នុងប្រទេសកម្ពុជាទទួលរងគ្រោះដោយទឹកជំនន់។ បណ្តាខេត្ត ដែលទទួលរងគ្រោះដោយទឹកជំនន់ គឺខេត្តព្រះសីហនុ កំពត ព្រះវិហារ កំពង់ធំ រតនគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម ព្រៃវែង កណ្តាល កំពង់ឆ្នាំង និងត្បូងឃ្មុំ។ ស្ថានភាពទឹកជំនន់លើកនេះ នៅតាមបណ្តាខេត្ត តំបន់មេគង្គលើ (ស្ទឹងត្រែង ក្រចេះ និងកំពង់ចាម) សុទ្ធតែឡើងដល់កម្រិតប្រុងប្រយ័ត្ន ឬលើសកម្រិតប្រុងប្រយ័ត្ន ។

អាស្រ័យដោយមានការផ្សព្វផ្សាយព័ត៌មានដល់ប្រជាជនបានទាន់ពេលវេលា ទើបប្រជាជនយើង ដោយមានការជួយពីសមត្ថកិច្ច ក៏បាន ធ្វើការជម្លៀសទៅទីទួលសុវត្ថិភាព ក្នុងពេលដែលស្ថានភាពទឹកមានការលិចលង់ខ្លាំង។ មន្ទីរជំនាញជុំវិញខេត្តនានា និងអង្គភាពកម្លាំងឈរជើងនៅមូលដ្ឋាន បានឋិតក្នុងលក្ខណៈត្រៀមអន្តរាគមន៍ ទាំងកម្លាំង និងមធ្យោបាយ ក្នុងការជួយសង្គ្រោះប្រជាជនរងគ្រោះគ្រប់ពេលវេលា។ ជាក់ស្តែងកម្លាំងនគរបាលខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំបាន ចូលរួមជាមួយអាជ្ញាធរមូលដ្ឋានក្នុងការជួយរុះរើលំនៅស្ថាន បញ្ចៀស ពីការបាក់ធ្លាក់ចូលទន្លេ ដោយការបាក់ច្រាំងនៅក្នុងខេត្តកំពង់ចាម ៦ ករណី ត្បូងឃ្មុំ ២ ករណី និងកណ្តាល ២ ករណី។ ក្រសួងការពារជាតិ បានបញ្ជូនកម្លាំងកងយោធពលខេមរភូមិន្ទចុះប្រចាំការត្រៀមលក្ខណៈ ក្នុងការអន្តរាគមន៍ជួយសង្គ្រោះប្រជាជននៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ចាម។ ក្នុងនោះអាជ្ញាធរខេត្តព្រះវិហារ បានសហការជា មួយកងពលធំអន្តរាគមន៍លេខ ៣ ចុះជួយសង្គ្រោះប្រជាជន និងជួយជួសជុលបន្ទាន់តាមកំណាត់ផ្លូវដែលទឹកហូរកាត់ផ្តាច់។ ក្នុងខេត្តក្រចេះ និងកំពង់ចាមអាជ្ញាធរបានប្រើប្រាស់ម៉ាស៊ីនបូមទឹកបញ្ចេញនៅពេល ដែលលូបង្ហូរទឹកចេញត្រូវបានបិទជៀសវាងការជន់លិច នៅពេលដែលកម្ពស់ទឹកទន្លេបានឡើងដល់កម្រិតប្រុងប្រយ័ត្ន។ ក្រសួងធនធានទឹក និងឧតុនិយម ត្រៀមគ្រឿងចក្រធុនធ្ងន់ប្រមាណ ២០០ គ្រឿង នៅតំបន់ចំនួន ៥ មានខេត្តតាកែវ ស្វាយរៀង ឧត្តរមានជ័យ បាត់ដំបង និង ភ្នំពេញដើម្បីត្រៀមលក្ខណៈក្នុងការជួសជុល និងបង្វែរផ្លូវទឹកដែលជន់ លិចលង់ ដើម្បីកាត់បន្ថយការខូចខាត និងបាត់បង់ដោយសារទឹកជំនន់។ អង្គការការីតាស់កម្ពុជា តាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានផ្តល់ទូកម៉ាស៊ីន

ចំនួន ១២ គ្រឿង ដែលបំពាក់ដោយអាវ ពោងដល់ខេត្តតាកែវ ព្រៃវែង រតនគិរី កំពង់ស្ពឺ ពោធិ៍សាត់ ស្ទឹងត្រែង ត្បូងឃ្មុំ និងបាត់ដំបង សម្រាប់បម្រើការងារជួយសង្គ្រោះប្រជាជន។

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា ប្រជាជនរងគ្រោះដោយទឹកជំនន់បានទទួលការជួយសង្គ្រោះបន្ទាន់ និងការផ្គត់ផ្គង់ស្បៀង ក៏ដូចជាប្រេងឥន្ធនៈបានទាន់ពេលវេលា។ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានផ្តល់ជូននូវស្បៀង និងប្រេងឥន្ធនៈសម្រាប់បម្រើការងារជួយសង្គ្រោះដល់ខេត្តចំនួន ៦ គឺ ខេត្តស្ទឹងត្រែងអង្ករ ២០ តោន ប្រេងឥន្ធនៈ ៣០០០ លីត្រ ខេត្តក្រចេះ អង្ករ ៥០ តោន ប្រេងឥន្ធនៈ ១០០០០ លីត្រ ខេត្តកំពង់ចាម អង្ករ ១០០ តោន ប្រេងឥន្ធនៈ ២០០០០ លីត្រ ខេត្តត្បូងឃ្មុំ អង្ករ ១០០ តោន ប្រេងឥន្ធនៈ ២០០០០ លីត្រ ខេត្ត កណ្តាល អង្ករ ៥០ តោន ប្រេងឥន្ធនៈ ១៥០០០ លីត្រ និងខេត្តព្រៃវែង អង្ករ ៥០ តោន ប្រេងឥន្ធនៈ ១៥០០០ លីត្រ។

កាកបាទក្រហមកម្ពុជា និងសាខាបានផ្តល់អំណោយសង្គ្រោះបន្ទាន់រួមមានខេត្តស្ទឹងត្រែង ២៧០០ គ្រួសារ ក្នុងស្រុកសៀមបូកសៀមប៉ាងសេសាននិងក្រុងស្ទឹងត្រែង ខេត្តត្បូងឃ្មុំ ១៤៨០ គ្រួសារ ក្នុងស្រុកត្បូង-ឃ្មុំ ខេត្តព្រះវិហារ ១២៥ គ្រួសារ ក្នុងក្រុងព្រះវិហារ ខេត្តក្រចេះ ៤៤៩០ គ្រួសារ ក្នុងស្រុក-ក្រុងចំនួន ៥ ខេត្តកំពង់ធំ ១០០ គ្រួសារ ក្នុងស្រុកប្រាសាទសម្បូរ ខេត្តរតនគិរី ១៦០ គ្រួសារ ក្នុងស្រុកលំផាត់។ ក្រៅពីនេះ ក៏មានការផ្តល់អំណោយពីសំណាក់ក្រុមការងារថ្នាក់ស្រុក-ថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធនានានិងសប្បុរសជនទាំងឡាយទៀតផង។

គ្រោះមហន្តរាយទឹកជំនន់ដែលបណ្តាលមកពីចរន្តទឹកភ្លៀងហូរចូលទន្លេមេគង្គ បង្កឱ្យមានការជន់ឡើង ប៉ះពាល់ដល់ខេត្តតាមដងទន្លេ និងតំបន់ឆ្នេរសមុទ្រចំនួន ១២ ខេត្ត ច្រើនជាងជំនន់ទឹកភ្លៀងក្នុងឆ្នាំ ២០១៣ ដែលទទួលរងគ្រោះតែ ៥ ខេត្ត។ ទោះយ៉ាងណារាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ត្រៀមលក្ខណៈតាំងពីដើមទី ដោយចាត់វិធានការសព្វបែបយ៉ាងទាំងអស់ធ្វើយ៉ាងណាកាត់បន្ថយគ្រោះថ្នាក់ និងការខាតបង់ដោយសារទឹកជំនន់ឱ្យនៅតិចបំផុត។/




*គ្រោះទឹកជំនន់ដែលបានធ្វើឱ្យលិចលង់ផលដំណាំ ផ្ទះសម្បែងប្រជាពលរដ្ឋ និងខូចខាតហេដ្ឋារចនាសម្ព័ន្ធ នៅតាមបណ្តាខេត្ត-ក្រុង ចំនួន ១២*

តមកពីទំព័រទី ១៥

បានរកប្រាក់ចំណូលពីការទិញសេវាកម្មធានារ៉ាប់រងផ្សេងៗមានតម្លៃសរុបចំនួន ២៧ លានដុល្លារ ពោលគឺកើនឡើងប្រមាណ ២១% បើធៀប នឹងរយៈពេល ដដែលកាលពីឆ្នាំ ២០១៣។

យោងទៅតាមតួលេខដែលបានផ្សព្វផ្សាយដោយសមាគមធានារ៉ាប់រងកម្ពុជាបានឱ្យដឹងថា ទំហំទឹកប្រាក់ដែលទទួលបានពីការទិញសេវាកម្មធានារ៉ាប់រងនេះ គឺភាគច្រើនបានមកពីការទិញសេវាកម្មធានារ៉ាប់រងអគ្គិភ័យ បន្ទាប់មកគឺផ្នែកយាន-យន្ត សុខភាព និងវិស្វកម្មជាដើម។

សេវាកម្មធានារ៉ាប់រងលើផ្នែកអគ្គិភ័យប្រមូលបានប្រមាណជិត ៩ លានដុល្លារ កើនឡើង ២៥%។ ផ្នែកយានយន្តមានជាង ៤ លានដុល្លារ កើនឡើង ៨%។ វិស្វកម្មមានជាង ៣ លានដុល្លារ។ ផ្នែកសុខភាពជាង ២ លានដុល្លារកើន ១០%។

សេវាកម្មធានារ៉ាប់រងនៅកម្ពុជានៅក្នុងពេលបច្ចុប្បន្នត្រូវបានអ្នកវិភាគអះ-អាងថា គឺជាវិស័យមួយដែលកំពុងតែមានស្ថានភាពប្រសើរ ដោយសារតែកម្ពុជាគឺជាប្រទេសដែលកំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃការលូតលាស់សេដ្ឋកិច្ច។

បច្ចុប្បន្នក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជាមានចំនួន ១០ ក្នុងនោះ ក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន ៧ និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមាន ៣។ ប៉ុន្តែក្រុម-ហ៊ុនធានារ៉ាប់រងមួយចំនួនទៀតក៏កំពុងតែចាប់អារម្មណ៍នឹងកម្ពុជាដែរ ជាពិសេសគឺក្រុមហ៊ុនធានារ៉ាប់រងទូទៅ។

**ការវិនិយោគវិស័យសំណង់រយៈពេល ៥ ខែដើមឆ្នាំ ៖**

ក្នុងរយៈពេល ៥ ខែដើមឆ្នាំ ២០១៤ នេះ ការវិនិយោគវិស័យសំណង់នៅកម្ពុជាមានចំនួន ៧២៨ គម្រោង ដែលមានតម្លៃ ១ ៥៣៧ លានដុល្លារ កើនឡើង ២១០% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៣។

គួររំឭកថា នៅឆ្នាំ ២០១៣ ការសាងសង់មាន ១ ៦៤១ គម្រោង មានតម្លៃប្រមាណ ២ ៧៧៣ លានដុល្លារ អាមេរិកកើន ៣១,៤៥% ធៀបនឹងឆ្នាំ ២០១២។ ឆ្នាំ២០១២ មាន ១ ៦៩៤ គម្រោង មានតម្លៃប្រមាណ ២១០៩ លានដុល្លារអាមេ-រិក កើន ៧១,៧% ធៀបនឹងឆ្នាំ ២០១១។ ចំណែកឆ្នាំ ២០១១ មាន ២ ១២៥ គម្រោង មានតម្លៃប្រមាណ ១ ២១៦ លានដុល្លារអាមេរិក។

សូមបញ្ជាក់ថា ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់គិតត្រឹមឆ្នាំ ២០១៣ មាន ១ ៣២៧ ក្រុមហ៊ុន និងឆមាសទី ១ ឆ្នាំ ២០១៤ មាន ១៤២២ ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនដែលនៅមានសុពលភាពមានចំនួន ៥៥៩ ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនបរទេសចំនួន ១៦៥។/

# ឈ្វេងយល់អំពីវិស័យតូរ្យតន្ត្រីខ្មែរ នាសម័យមុនប្រវត្តិសាស្ត្រ

*ឧបសគ្គដែលធ្វើឱ្យគេមិននឹកស្មានថា ដូនតាខ្មែរបានស្គាល់ និងនិយមឧបករណ៍ភ្លេង គឺបណ្តាលមកពីការកែប្រែភូមិសាស្ត្រជាប្រវត្តិសាស្ត្ររបស់អម្បូរមន-ខ្មែរ និងខ្មែរ ចាប់តាំងពីចុង ស.វ ទី ១៣ រហូតដល់សព្វថ្ងៃ ដែលធ្វើឱ្យតំបន់ធំមួយចំនួនត្រូវបានផ្តាច់ចេញពីព្រះរាជាណាចក្រកម្ពុជានាសម័យនគរភ្នំ ចេនឡា និងនាសម័យក្រោយអង្គរ ។ ផលវិបាកមួយទៀតមកដល់ ស.វ ទី ២១ អ្នកស្រាវជ្រាវជាច្រើននៅតែភ្លេចថា ជនជាតិខ្មែរសព្វថ្ងៃ គឺជាជនជាតិដើមរួមឈាមជ័រអម្បូរមន-ខ្មែរ ជាមួយកុលសម្ព័ន្ធព្នង ដែលបានកាន់កាប់ឧបទ្វីបឥណ្ឌូចិន-ទាំង មូល មុនការបង្កើតរដ្ឋ ឬព្រះរាជាណាចក្រនានា ។*



*រូបភាព ១-៣" ថ្មភ្លេង មន-ខ្មែរ ម៉្មុងហ្គារ សម័យថ្មរំលីង នៅនឌុត លៀងគ្រាក់ វៀតណាមខាងត្បូងបច្ចុប្បន្ន សារមន្ទីរជាតិពិន្ទុវិទ្យា ប៉ារីស រនាតថ្មខេត្តនគរស្រីធម្មរាជ ( ឯកសារនាយកដ្ឋានវិចិត្រសិល្បៈថៃ) និងថ្មភ្លេង មកពីលពបុរី ឬ ស្រីទេព សារមន្ទីរជាតិបាងកក់ ( ម.ត ១៩៩០)*

បើនិយាយម្យ៉ាងទៀត ដោយសារតែមូលហេតុទាំងអស់នេះហើយ ទើបទាំងអ្នកស្រាវ-ជ្រាវខ្មែរ ឬក៏ជនជាតិខ្មែរអឺរ៉ុបនិយមភ្លេចថា បុព្វការីជននាសម័យដើម បានមានឧបករណ៍ភ្លេងរួចមកហើយ ។និយាយឱ្យខ្លីទៅ លក្ខណៈវប្បធម៌ដ៏គួរឱ្យយកចិត្តទុកដាក់ក្នុងប្រវត្តិ-សាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា គឺថាជនជាតិខ្មែរនៅតាមបណ្តាខេត្តនានានៃទឹកដីនៃព្រះ-រាជាណាចក្រថៃបច្ចុប្បន្ន ដូចនៅប្រទេសថៃ លាវ ជាដើម ដែលជាមែកធាងនៃអម្បូរមន-ខ្មែរបានផ្តាច់ពីកុលសម្ព័ន្ធ ដោយសារតែឥទ្ធិ-ពលឥណ្ឌាជាអ្នកស្នងមរតកវប្បធម៌បុរេប្រវត្តិសាស្ត្រទាំងអស់នោះ ។ ហើយគឺក្នុងបរិបទនេះហើយ ដែលមានការនិយមរនាត និងកញ្ចែ ឬកណ្តឹងគ្រប់ប្រភេទរហូត ដល់សព្វថ្ងៃ ទោះបីជាពួកគេបានខ្ចីឧបករណ៍ភ្លេងមួយចំនួនមកពីឥណ្ឌា ឬចិនក៏ដោយ ។

ឧបករណ៍ខ្លះៗរបស់សហគមន៍មន-ខ្មែរ និងខ្មែរបច្ចុប្បន្ន យើងអាចឃើញនូវលក្ខណៈស្រដៀងគ្នា គឺដោយសារតែលក្ខណៈនេះហើយដែលជំរុញយើងឱ្យសន្និដ្ឋានបានថាក្រៅពីការកំណត់អាយុកាលដ៏ច្បាស់ប្រភពរួមនៃឧបករណ៍ភ្លេងមួយចំនួនដែលបានកើតឡើងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដែនដីគោក ។ នៅទីនេះយើងចង់និយាយដល់ឧបករណ៍រនាតខ្មែរបច្ចុប្បន្ន ដែលមានលក្ខណៈដូចរនាតថ្មនាសម័យយុគថ្មរំលីង ឬលោហធាតុដែលពួកម្ចាស់អ្នកស្រុកដើម ឬមន-ខ្មែរ បានប្រើ-ប្រាស់នៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។

ក្នុងន័យសាមញ្ញ បើយើងពិនិត្យមើលត្រឡប់ក្រោយមកវិញ ពោលគឺសម័យកាលមុនការលេចធ្លោឡើងនៃរដ្ឋ ឬប្រទេសក្នុងតំបន់ រឿងដែលយើងគួរកត់សម្គាល់នោះគឺអ្នកស្រុកអាយ ដែលជាបុព្វការីជនខ្មែរអ្វីដែលទើបលើកអាចជាកំហុសមួយដែលអ្នកស្រាវ-ជ្រាវខាងនាដសាស្ត្រឬតូរ្យតន្ត្រីរមែងតែមើលរំលង ព្រោះពួកគេមិនបានលើកមកនិយាយ ឬបកស្រាយក្នុងអត្ថបទរបស់គេហាក់ដូចជាអ្វីៗទាំងអស់មកពីឥណ្ឌា ឬក៏មិនមែនជាសមិទ្ធកម្មរបស់អ្នកស្រុកអាយ ។ ចំពោះយើងទស្សនៈរបស់គេមិនត្រឹមត្រូវ និងសមស្របតាមប្រវត្តិសាស្ត្រទេ ។

ដោយសារតែមានឧបករណ៍ភ្លេងទាំងនោះផលិតឡើងជាច្រើនសម័យកាលបន្តបន្ទាប់គ្នានាសម័យមុនប្រវត្តិសាស្ត្រ យើងមិនអាចបដិសេធក្នុងវត្តមានរបស់វិស័យតូរ្យតន្ត្រីមុនឥទ្ធិពលឥណ្ឌា និងចិនបានឡើយ ។ ព្រោះថា គេច្រើនភ្លេចថា ជនជាតិខ្មែរជាជនជាតិចាស់ ។

ម្យ៉ាងវិញទៀត យើងក៏ដឹងដែរថាឧបករណ៍ខ្លះ ជនជាតិដែលស្ថិតក្នុងអម្បូរមន-ខ្មែរ នៅតែពេញនិយមនៅឡើយដើម្បីពិធីកម្មសាស-នា ក៏ដើម្បីធ្វើឱ្យជីវិតរីករាយសប្បាយក្នុងឱកាសសម្រាកកាយ ឬបុណ្យទានសាសនាម្តងៗ ។

សម័យវប្បធម៌ថ្មរំលីង (៥០០០-១៥០០ មុនគ.ស) ថ្វីត្បិតតែមានសម័យមាសនៃវិស័យតូរ្យតន្ត្រីមន-ខ្មែរក្តី ក៏ប៉ុន្តែមានការបដិវត្តផ្នែកវប្បធម៌គ្រប់វិស័យទៅហើយ ។ ក្នុងសមិទ្ធផលសង្គមសំខាន់ៗ យើងឃើញមានបច្ចេកទេសរំលីងអាវុធថ្ម ការសាងសង់ភូមិស្រុកដូចករណីក្រុងមូល ឬពងក្រពើ ការធ្វើស្រែចំការ និងការផ្សាំងសត្វ ។ នៅពេលដដែលនេះដែរ ទោះបីមិនទាន់ស្គាល់លោហ-ធាតុក្តី ខ្មែរបុរាណបានចេះផលិតឧបករណ៍ភ្លេងធ្វើអំពីថ្ម ដើម្បីប្រើប្រាស់តាមសេចក្តីត្រូវការ ជាពិសេសសម្រាប់ជំនឿ វិស័យសាសនា ។

នៅពេលដែលយើងពិនិត្យលក្ខណៈនៃ



*រូបភាព ១-៥ : (១-៤) -ជួង, កណ្ដឹង ភូមិស្នាយ និងស្គរមហោរធឹក មកពីចិន សារមន្ទីរជាតិភ្នំពេញ (ម.ត ២០០៦ និង ២០០០)*

ឧបករណ៍ភ្លេងទាំងនោះ រួមមាន ថ្មភ្លេងនៅមេមត់ ក៏ដូចនៅកម្ពុជាក្រោម ហើយប្រៀប-ធៀបទៅនឹងឧបករណ៍ភ្លេងនាសម័យលោហធាតុ ការរកឃើញនិងការប្រើប្រាស់នូវធាតុរ៉ែសំរឹទ្ធ ហើយដែកនេះគឺជាផ្នែកមួយនៃវឌ្ឍន-ភាពសង្គមវប្បធម៌ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងនៅប្រទេសឥណ្ឌូណេស៊ី។ ចាប់តាំងពីនោះមក រវាង ១៥០០ ឆ្នាំមុន គ.ស រហូតដល់ ស.វទី ៣-៤ គ.ស។ ការនិយមលោហធាតុសម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ក្នុងសង្គម ដូចជា អាវុធគ្រឿងអលង្ការគ្រប់ប្រភេទ បានជួយពង្រីកយ៉ាងឆាប់រហ័សនូវវិស័យកសិកម្ម និងអត្រារបស់ប្រជាជន។ យ៉ាងណាមិញឧត្តមភាពខាងវិស័យវិចិត្រសិល្បៈជាទូទៅ ហើយវិស័យដូរតន្ត្រីដោយឡែកក៏ដូច្នោះដែរ។

ខុសពីសម័យមុនៗ បើទោះជាមានការនាំចូលនូវស្គរមហោរធឹកក្នុងតំបន់ក៏ដោយ ក៏ពឹងផ្អែកលើរបកគំហើញខាងបុរាណវិទ្យា យើងអាចនិយាយយ៉ាងត្រឹមត្រូវថា ភ្លេងបានដើរតួនាទីយ៉ាងសំខាន់ស្ទើរតែគ្រប់ទិដ្ឋភាពនៃសង្គមទាំងអស់ ហើយម្យ៉ាងវិញទៀត វិស័យតូរ្យ-តន្ត្រីនេះខុសពីតំបន់នានានៃភូមិភាគខាងត្បូងនៃប្រទេសចិន បានមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយពិធីបូជាសព។ និយាយឱ្យខ្លី តាំងពីកើតរហូតដល់ស្លាប់ ភ្លេងមិនអាចផ្ដាច់ចេញពីសង្គមខ្មែរ ដែលនាជំនាន់នោះនៅមានលក្ខណៈជាកុលសម្ព័ន្ធនៅឡើយ។

ឧទាហរណ៍ជាក់ស្ដែងហើយសំខាន់បំផុត ដែលបង្ហាញថា ក្នុងវិស័យតូរ្យតន្ត្រីបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាលើសហគមន៍នាសម័យបុរេប្រវត្តិសាស្ត្រ វត្តមានរបស់ឧបករណ៍ភ្លេងគឺកណ្ដឹង និងជួងគ្រប់ប្រភេទ ក្នុងផ្នូរសព នៅស្ថានីយភូមិស្នាយ នៅភូមិបានឈៀង ឬក៏នៅតាមទីតាំងផ្សេងៗឯទៀត។ នេះសឱ្យឃើញនូវតួនាទីចម្បងរបស់វិស័យតូរ្យតន្ត្រីមួយយ៉ាងសំខាន់នៅក្នុងសង្គម។

ជាព័ត៌មានសូមជម្រាបថា ថ្មភ្លេងនាយុគថ្មរំលីង ក៏ត្រូវបានប្រើបន្តដល់សម័យនគរភ្នំ ដូចករណីថ្មភ្លេងមួយចំនួន ដែលគេបានរកឃើញនៅក្នុងអតីតទឹកដីខ្មែរនាសម័យបុរេអង្គរ ដូចជានៅទីក្រុងលពបុរី ឬស្រីទេព ក្នុងខេត្តពេជ្របុ័នប្រទេសថៃបច្ចុប្បន្នជាសក្ខីកម្ម។ នេះមិននិយាយដល់ថ្មគក់ទ្រូងនៅប្រាសាទអង្គរវត្តផងដែរ ដែលសុទ្ធសឹងតែជាកត្តាបង្ហាញអំពីលក្ខណៈពិសិដ្ឋនៃថ្មភ្លេងទាំងនោះ។

នៅមានហេតុផលមួយទៀត ដែលតម្រូវឱ្យមានការចាប់អារម្មណ៍ គឺលក្ខណៈពិសិដ្ឋរបស់ឧបករណ៍ភ្លេងទាំងនោះ។ ចំពោះចំណុចនេះ យើងមិនអាចរែកញែកនៅទីនេះបានទេ។ អ្វីដែលយើងអាចកត់សម្គាល់ គឺឧប-ករណ៍ទាំងនោះប្រកបដោយលក្ខណៈស័ក្តិ-សិទ្ធិជាទីបំផុត ដើម្បីបង្ហាញភាពអច្ឆរិយៈនៃឧបករណ៍ភ្លេងទាំងនោះ មនុស្សនាជំនាន់នោះបានឆ្លាក់ក្បាច់គួចខ្សែ រូបបុព្វការីជន ឬក៏រូបសត្វនៅលើឧបករណ៍ទាំងនេះ ហាក់បីដូចជាតំណាងឱ្យកម្លាំងធម្មជាតិ ឬទាក់ទាញកម្លាំងទាំងអស់ឱ្យបីបាច់ថែរក្សា ឬគាំពារពួកគេ។ ចំពោះបញ្ហានេះ គួរតែមានការរែកញែកបន្តទៅទៀត។

ទន្ទឹមនឹងនេះ ក៏មានការជួញដូរនូវឧបករណ៍ភ្លេងទាំងនោះដែរពីតំបន់មួយទៅតំបន់មួយទៀតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ ហើយចំពោះការជួញដូរ ឬដោះដូរទូលំទូលាយ ដែលគួសបញ្ជាក់តាមរយៈឯកភាពនៃក្បាច់ក្បូរ ឬរូបរាងនៃឧបករណ៍ភ្លេង ហើយស្ថានភាពបែបនេះគឺមានលក្ខណៈជាសកល។/

*(ម. ត្រាណោ)*



# អេបូឡា ( EBOLA ) ជំងឺដែលធ្វើឱ្យពិភពលោកព្រួយបារម្ភ



ជំងឺដ៏សាហាវឈ្មោះ **អេបូឡា** កំពុងរាតត្បាតនៅប្រទេស ហ្គីណេ លីបេរីយ៉ា នីហ្សេរីយ៉ា និងសេរ៉ាឡេអូន





ប៉ុន្មានខែកន្លងមកនេះ បណ្ដាប្រទេសនៅអាហ្វ្រិកខាងលិចកំពុងរងការប៉ះពាល់ដោយជំងឺដ៏សាហាវមួយឈ្មោះ **អេបូឡា** ។ កាលពីថ្ងៃទី ១ សីហា កន្លងមកនេះ អង្គការសុខភាពពិភពលោក បានបង្ហាញផែនការថ្មីមួយក្នុងប្រទេសហ្គីណេ ដើម្បីទប់ទល់នឹងជំងឺនេះ ដែលមានទឹកប្រាក់ ១០០ លានដុល្លារ ។ ផែនការនេះស្ថិតក្នុងក្របខណ្ឌនៃយុទ្ធនាការអន្តរជាតិតំបន់ និងជាតិ សំដៅទប់ស្កាត់ការឆ្លងរាលដាលវីរុស**អេបូឡា**ដ៏សាហាវដែលវាយប្រហារលើប្រទេសហ្គីណេ លីបេរី-យ៉ា និងស៊ីរ៉ាឡេអូន ។

អង្គការសុខភាពពិភពលោក បានគូសបញ្ជាក់ថា ឆ្លងតាមទំហំនៃការឆ្លងរាលដាលវីរុស**អេបូឡា** ទាម-ទារ ឱ្យអង្គការសុខភាពពិភពលោក ប្រទេសហ្គីណេ លីបេរីយ៉ា និងស៊ីរ៉ាឡេអូន ត្រូវទប់ទល់ឱ្យកាន់តែម៉ឺងម៉ាត់ថែមទៀត ហើយប្រការនេះនឹងទាមទារនូវធនធានច្រើននូវសមត្ថកិច្ច និងវេជ្ជសាស្ត្ររបស់បណ្ដាប្រទេស ព្រមទាំងការរៀបចំក្នុងកម្រិតតំបន់ ព្រមទាំងមានការសម្របសម្រួលគ្នាកាន់តែខ្លាំង ។

តាមផែនការនេះ អ្នកមានវិជ្ជាជីវៈពេទ្យជាច្រើនរយនាក់ ត្រូវបញ្ជូនទៅកាន់បណ្ដាប្រទេសមានជំងឺរាតត្បាតនោះ ដើម្បីជួយដល់បណ្ដាមន្ទីរពេទ្យដែលមានអ្នកជំងឺ ។ ពលករមនុស្សធម៌របស់ពិភពលោកជាច្រើនរយនាក់ ព្រមទាំងបុគ្គលិករបស់អង្គការសុខភាពពិភពលោកជាង ១២០ នាក់ បានចូលរួមក្នុងការប្រឹងប្រែងដើម្បីទប់ទល់នឹងវីរុស**អេបូឡា** ។

ផែនការថ្មី រួមមានជាពិសេសនូវយុទ្ធសាស្ត្រនានាដើម្បីលុបបំបាត់ការឆ្លងវីរុស**អេបូឡា**ក្នុងបណ្ដាប្រទេសរងការប៉ះពាល់ ហើយចៀសវាងកុំឱ្យវីរុសនោះឆ្លងចូលដល់បណ្ដាប្រទេសជិតខាង ។ ការឆ្លងរាលដាលនៃជំងឺ**អេបូឡា** មានទំហំធំពុំធ្លាប់មានពីមុន ។ ចាប់តាំងពីខែមីនា ឆ្នាំ២០១៤ មក ចំនួនមនុស្សដល់ទៅ ១ ៣២ ៣ នាក់ឆ្លងជំងឺនេះ ហើយមនុស្ស ៧២៩ នាក់ស្លាប់នៅហ្គីណា លីបេរីយ៉ា និង ស៊ីរ៉ាឡេអូន ។ វីរុស**អេបូឡា**អាចសម្លាប់មនុស្សឆ្លងរហូតដល់ ៩០% ហើយអត្រាស្លាប់នៃជំងឺនេះ បច្ចុប្បន្នមានប្រមាណជា ៦០% ។

ជំងឺនេះមានតាំងពី ៤០ ឆ្នាំមកហើយ តែវាពុំបានឆ្លងរាលដាលខ្លាំងដូចពេលនេះឡើយ ។

ជំងឺរាតត្បាត Ebola នៃប្រទេសអាហ្វ្រិកខាងលិចគឺជាព្រឹត្តិការណ៍ដ៏ពិសេសមួយ ហើយឥឡូវនេះទៀតគឺជាការធ្វើឱ្យមានការប្រជុំប្រថានជាអន្តរ-ជាតិផ្នែកសុខភាពហើយ ។ អង្គការ WHO ថា ការរីករាលដាលកំពុងតែវិវត្តយ៉ាងឆាប់រហ័ស លើសពីយើងអាចគ្រប់គ្រងវាទៅទៀត ។ សេចក្ដីប្រកាសនេះនឹងនាំឱ្យមានការយកចិត្តទុកដាក់ចំពោះថ្នាក់ដឹកនាំនៃគ្រប់ប្រទេសទាំងអស់ ដោយមិនអាចធ្វើឡើងត្រឹមតែថ្នាក់រដ្ឋមន្ត្រីសុខាភិបាលតែប៉ុណ្ណោះទេ ។

### ទ្វីបអាស៊ីដាក់ពង្រាយកាមេរ៉ា និងគ្រូពេទ្យនៅពេលអេបូឡាគំរាមពិភពលោក

បណ្ដាប្រជាជាតិនៅអាស៊ីកំពុងប្រើកាមេរ៉ា ចាប់រូបភាព និងស្កេនកម្ដៅ ព្រមទាំងដាក់គ្រូពេទ្យនៅតាមអាកាសយានដ្ឋានដើម្បីត្រួតពិនិត្យរកអ្នកដំណើរដែលមានជំងឺ នៅពេលអាជ្ញាធរសុខភាពនៅក្នុងប្រទេសនីមួយៗកំពុងដុតដៃដុតជើង បញ្ចៀសការផ្ទុះជំងឺ**អេបូឡា**ដែលបានឆក់យកជីវិតមនុស្ស អស់ជិត ១០០០ នាក់ នៅអាហ្វ្រិកខាងលិច ។

ប្រទេស ៤ រួមមាន ហ្គីណេ លីបេរីយ៉ា នីហ្សេរីយ៉ា និងសេរ៉ាឡេអូន កំពុងតស៊ូប្រយុទ្ធនឹងការផ្ទុះឡើងជំងឺ**អេបូឡា**ដ៏អាក្រក់បំផុត ដោយអត្រាសម្លាប់មនុស្សមានដល់ទៅ ៩០% និងមិនទាន់មានឱសថព្យាបាល និងវ៉ាក់សាំងសម្រាប់ការពារនៅឡើយ ។

គេនៅមិនទាន់មានការបញ្ជាក់អះអាងអំពីវត្តមានរបស់វីរុសនេះនៅអាស៊ីទេ តែអាជ្ញាធរសុខភាពបានប្រយុទ្ធនឹងវីរុសផ្ដាច់ជីវិតនានា ដូចជាផ្ដាសាយបក្សី និងសា នៅប៉ុន្មានឆ្នាំមុន ហើយកំពុងត្រៀមខ្លួនសម្រាប់ការផ្ទុះឡើងនៃការគំរាមថ្មីនេះ ។

វិធានការរួមមានការដាក់កាមេរ៉ាចាប់រូបភាព និងស្កេនកម្ដៅខ្លួនដែលប្រើពន្លឺ infra-red ដើម្បីពិនិត្យលើអ្នកដំណើរដែលមានអាការៈក្ដៅខ្លួន និងមានយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងសាធារណៈ ។ ប្រទេសភាគច្រើនបានអំពាវនាវប្រាប់ប្រជាពលរដ្ឋរបស់គេឱ្យពិចារណាពន្យារពេលធ្វើដំណើរ ទៅកាន់តំបន់ដែលកើតជំងឺនេះ ។

នៅប្រទេសថៃ មន្ត្រីសុខាភិបាលដែលទទួលបានអ្នកទេសចរ ២៦.៥ លាននាក់កាលពីឆ្នាំមុន បានកំពុងតាមដានត្រួតពិនិត្យភ្ញៀវមួយចំនួនមកពីសេរ៉ាឡេអូន លីបេរីយ៉ា និងហ្គីណេ តែមិនមានផែនការដាក់ពួកគេនៅឆ្ងាយដាច់ពីគេឯងទេ ។

វីរុស **អេបូឡា** ឆ្លងតាមរយៈការប៉ះពាល់ទឹករាវរបស់រាងកាយនរណាម្នាក់ដែលមានរោគសញ្ញា រួមមាន ឈឺសាច់ដុំ និងសន្លាក់ និងក្នុងករណីធ្ងន់ធ្ងរ អ្នកជំងឺក្អួត រាគ ចេញឈាម នៅដំណាក់កាលចុងក្រោយ ។

នៅប្រទេសចិន ទោះជាមិនមានរបាយការណ៍អំពីការមាន **អេបូឡា** តែមន្ទីរពេទ្យនានាត្រូវបានណែនាំឱ្យរាយការណ៍ករណីសង្ស័យណាមួយ ។ ជប៉ុន ក៏ត្រៀមបញ្ជូនជនណាដែលសង្ស័យថាកើត**អេបូឡា**ទៅកាន់មន្ទីរពេទ្យដាច់ពីគេជាពិសេស ។

ប្រទេសឥណ្ឌា ដែលមានពលរដ្ឋជិត ៤៥ ០០០ នាក់ រស់នៅបណ្ដាប្រទេសដែលមានកើតជំងឺនេះបាននិយាយថា ខ្លួននឹងត្រួតពិនិត្យមើលអ្នកដំណើរដែលវិលមកពីតំបន់រងគ្រោះ ។

ចំណែកអូស្ត្រាលីបាននិយាយថា ខ្លួនមិនមានចាត់





*អ្នកមានវិជ្ជាជីវៈពេទ្យជាច្រើនរយនាក់ត្រូវបញ្ជូនទៅកាន់បណ្តាប្រទេសមានជំងឺរាតត្បាតដ៏សាហាវឈ្មោះ **អេបូឡា** ដូចជាប្រទេស ហ្គីណេ លីបេរីយ៉ា នីហ្សេរីយ៉ា និងសេរ៉ាឡេអូន*

វិធានការពិសេសណាទេ តែបណ្តាអាកាសយានដ្ឋានត្រូវបានប្រាប់ឱ្យប្រុងប្រយ័ត្នខ្ពស់ចំពោះអ្នកដំណើរដែលឈឺ ។

## Ebola ជាវីរុសសាហាវបំផុតក្នុងលោក តើយើងស្គាល់ដោយរបៀបណា ?

អ្នកជំងឺរបកស្បែក ហើយឈាមចាប់ផ្តើមហូរ ដែលនេះជាការបង្ហាញថា ជំងឺចាប់ផ្តើមវាយលុកពេញទំហឹង អ្នកជំងឺគ្រុនក្តៅ ឈឺក្បាល និងឈឺបំពង់ក និងគ្មានចំណង់អាហារ គឺសញ្ញាដំបូងនៃវីរុស ។

ប៉ុន្តែវីរុស Ebola ដ៏កំណាចបានចាប់ផ្តើមវាយប្រហារប្រព័ន្ធភាពស៊ាំរបស់អ្នកជំងឺដោយមិនឱ្យដឹងខ្លួននោះទេ។

វីរុសនេះបំផ្លាញកោសិកាដូចគ្នាទៅនឹងកោសិកាដែលវាយប្រហារដោយវីរុសហ៊ីវដែរ ទោះយ៉ាងណាជំងឺEbola មានលក្ខណៈសាហាវជាង ដោយបំផ្លាញអស់នូវប្រព័ន្ធភាពស៊ាំរបស់រាងកាយ។ វីរុសនេះមានរយៈពេលបង្ករោគ គឺពេលវេលាពីការឆ្លងរហូតដល់ពេលដែលរោគមានសញ្ញាដំបូង បង្ហាញមុខឡើងពោលនៅចន្លោះ ២ ទៅ ២១ថ្ងៃ ដោយវាបង្កើនហានិភ័យនៃការឆ្លងរាតត្បាតជំងឺ បង្កដោយមេរោគយ៉ាងខ្ពស់បំផុត។ នៅពេលដែលជនរងគ្រោះចាប់ផ្តើមទទួលរងការវាយប្រហារភ្លាមៗពីជំងឺនេះ មានដូចជាគ្រុនក្តៅ ឈឺក្បាលស្ទើរបែក និងឈឺសាច់ដុំនោះ វីរុសបានឆ្លងចូលក្នុងខ្លួនរួចទៅហើយ ។

វីរុសនេះត្រូវបានចម្លងតាមរយៈ ការប៉ះពាល់ក្បៀកនឹងឈាម វត្ថុធាតុ (ដូចជា ទឹកភ្នែក ទឹកនោម ញើស ទឹករំលាយក្នុងក្រពះ ទឹកមាត់ ។ល។) សរីរាង្គ ឬទឹករងៃរបស់សត្វ ដែលឆ្លងវីរុសនេះ ។នៅពេលណាដែលមនុស្សឆ្លងវីរុសនេះ ជំងឺអាចរីករាលដាលយ៉ាងឆាប់រហ័សក្នុងសហគមន៍ដោយក្រុមបុគ្គលិកពេទ្យ និងសមាជិកគ្រួសារជនរងគ្រោះមានហានិភ័យខ្ពស់។ការផ្ទុះឡើងវីរុសបច្ចុប្បន្ន នេះនៅអាហ្វ្រិកខាង លិចបានចាប់ផ្តើមក្នុងភូមិតូចមួយក្នុងប្រទេសហ្គីណេ ហើយចាប់តាំងពីខែកុម្ភៈ មកវា បានឆក់យកជីវិតមនុស្ស ៦៧២ នាក់ ដោយបន្សល់ ទុកអ្នកឆ្លងវីរុសនេះចំនួន ១២០០ នាក់ ទៀត។ វាបានរាលដាលដល់ប្រទេសជិតខាងសេរ៉ាឡេអូន និង លីបេរីយ៉ា ។

ការពិតវីរុសនេះលាក់បាំងរោគសញ្ញាផ្តាសាយនៅដំណាក់កាលដំបូងមិនឱ្យដឹងគឺជាកត្តាធ្ងន់ធ្ងរបំផុតដែលធ្វើឱ្យជំងឺនេះ ពិបាកក្នុងការធ្វើរោគវិនិច្ឆ័យ។ រយៈពេលតែប៉ុន្មានថ្ងៃរោគសញ្ញាដំបូង នឹងចាប់ផ្តើមឈានទៅដំណាក់កាលបន្ទាប់នៃវីរុស ។ ដំណើរការមួយហៅថា DIC (Disseminated Intra-vascular Coagulation) បង្កឱ្យមានកំណកឈាម និងការធ្លាក់ឈាមនៅក្នុងថ្លើម ខួរក្បាល និងសរីរាង្គក្នុងដទៃទៀត។ វីរុសនេះ ជ្រាបចូលសរសៃឈាមធំ និងសរសៃឈាមតូច ដោយបង្ខំឱ្យសរសៃឈាមទាំងនេះហូរឈាមចូលទៅក្នុងជាលិកានៅជុំវិញ។អ្នកជំងឺនឹងរងការឈឺចាប់ពេញរាងកាយឈឺពោះរាំរ៉ៃ ក្អួតចង្អោរ និង រាគរូស។ បន្ទាប់មក កន្ទួលចាប់ផ្តើមបង្ហាញលើដងខ្លួនដោយរីករាលដាលយ៉ាងឆាប់រហ័សទៅអវៈយវៈ និងក្បាល ។ ក្នុងរយៈពេលតែប៉ុន្មានថ្ងៃ ជំងឺចាប់ផ្តើមឈានដល់ចំណុចកំពូល ខណៈពេលមួយដែលអ្នកជំងឺសំណាងល្អមួយចំនួននឹងធូរស្បើយឡើងវិញ ចំណែកអ្នកដទៃទៀតនឹងវិវត្តទៅរកដំណាក់កាលស្លាប់តែម្តងនោះ គឺការហូរឈាមឥតឈប់។

ប្រព័ន្ធភាពស៊ាំរបស់រាងកាយចាប់ផ្តើមបើកដោយខ្លួនឯង ។ សរសៃឈាមតូចៗផ្ទុះឡើង ដោយបង្កឱ្យអ្នកជំងឺហូរឈាមឥតឈប់ចេញពីភ្នែក មាត់ ត្រចៀក និងរន្ធ ឬប្រហោងដទៃទៀត។ការហូរឈាមខាងក្នុងរាងកាយ ទំនងកើតឡើងនៅក្នុងផ្លូវក្រពះ និងពោះវៀនតូច និងសរីរាង្គក្នុងដទៃទៀត។ ផ្នែកពណ៌សនៃភ្នែករបស់អ្នកជំងឺនឹងប្រែទៅជាពណ៌ក្រហម ហើយមានឈាមនៅក្នុងកម្អួត និងលាមករាគ ខណៈពងបែកក្នុងឈាមដ៏ធំវិវត្តនៅក្រោមស្បែក។

ចំពោះអ្នកដែលនៅរស់រានមានជីវិត ពួកគេត្រូវតែទទួលការធ្វើតេស្តឱ្យបានជាប្រចាំដើម្បីធានាថា វីរុសលែងមានវត្តមានក្នុងទឹករងៃលើរាងកាយរបស់ពួកគេមុនពេលចាកចេញពីមន្ទីរពេទ្យដោយសុវត្ថិភាព ។

វីរុសនេះក៏អាចចម្លងតាមការរួមភេទដែរ ក្នុងរយៈពេលរហូតដល់ទៅ ៤០ ថ្ងៃបន្ទាប់ពីមនុស្សបានស្រួលខ្លួនឡើងវិញ ។

ដោយឡែក នៅកម្ពុជាមិនទាន់មានអ្នកឆ្លងវីរុស **អេបូឡា**នោះទេ ក្រសួងសុខាភិបាលកម្ពុជា កាលពីថ្ងៃទី ១១ សីហា ឆ្នាំ ២០១៤ បានច្រានចោលនូវព័ត៌មានដែលថា ជំងឺ**អេបូឡា** ឬហៅម្យ៉ាងទៀតថាជំងឺគ្រុនឈាមនៅអាហ្វ្រិកនោះ បានឆ្លងចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ លោកវេជ្ជបណ្ឌិត *លី សុវណ្ណ* អនុប្រធាននាយកដ្ឋានតាមដាន ជំងឺឆ្លងនៃក្រសួងសុខាភិបាលបានឱ្យដឹងថា រហូតមកទល់ពេលនេះ ប្រជាជនកម្ពុជានៅមិនទាន់មានអ្នកឆ្លងជំងឺ **អេ-បូឡា**នេះនៅឡើយទេ។

លោកវេជ្ជបណ្ឌិតបានបន្តទៀតថា "ជំងឺនេះមានហានិភ័យទាបទេសម្រាប់ប្រទេសកម្ពុជា ដោយសារហេតុផលទីមួយ ទំនាក់ទំនងប្រទេសយើងជាមួយបណ្តាប្រទេសអាហ្វ្រិកខាងលិច គឺមានតិចតួចណាស់ ទី ២ ជំងឺនេះជាជំងឺមួយដែលប៉ះពាល់សាច់ផ្ទាល់ជា-មួយអ្នកជំងឺ ឬមួយក៏សត្វជ្រូង ឬស្វាឳ ដែលមានផ្ទុកនូវមេរោគក្នុងប្រទេសអាហ្វ្រិក" ។

លោកក៏បានបញ្ជាក់ទៀតថា "ជំងឺ**អេបូឡា** រហូតមកដល់ពេលនេះមិនទាន់មានវ៉ាក់សាំង ឬថ្នាំសម្រាប់ព្យាបាលជំងឺនៅឡើយនោះទេ តែយើងអាចព្យាបាលតាមរបៀបសង្គ្រោះ ព្យាបាលតាមរកសញ្ញាវិជ្ជាពេទ្យ បើសិនជាអ្នកជំងឺខ្វះជាតិទឹក យើងនឹងផ្តល់ទឹក ហើយបើខ្វះឈាម យើងនឹងផ្តល់ឈាមឱ្យផងដែរ" ។

សូមបញ្ជាក់ថា ជំងឺ**អេបូឡា**នេះ ជាជំងឺមួយប្រភេទដែលកើតនៅលើមនុស្ស និងសត្វ ដូចជា សត្វស្វាឳ និងសត្វជ្រូងជាដើម។ ជំងឺនេះចាប់ផ្តើមរាត-ត្បាតដំបូងនៅឆ្នាំ ១៩៧៦ នៅក្នុងភូមិមួយក្បែរទន្លេ **អេបូឡា** ប្រទេសកុងហ្គោ និងតំបន់ដាច់ស្រយាល ក្នុងប្រទេសស៊ូដង់។ ហើយជំងឺនេះ ឆ្លងមកមនុស្សតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយឈាមមនុស្ស ទឹកសរី-រាង្គ និងសរីរាង្គសត្វ ជាពិសេសតាមរយៈសត្វដែលស្លាប់ក្នុងព្រៃក្រាស់ ដែលផ្ទុកវីរុស**អេបូឡា**នេះ ។/

# ដុសធ្មេញជាប្រចាំ ធ្វើឱ្យថយចុះហានិភ័យលោកសន្លាក់

ពួកអ្នកវិទ្យាសាស្ត្រចាត់ទុកថាការដុសធ្មេញជាប្រចាំនឹងធ្វើឱ្យថយចុះហានិភ័យកើតជំងឺរលាកសន្លាក់។ មូលហេតុគឺដោយសារបាក់តេរីបង្កជំងឺអញ្ចាញធ្មេញ និងរលាកសន្លាក់មានទំនាក់ទំនងជាមួយគ្នា។

ពួកអ្នកស្រាវជ្រាវផ្នែកទន្តសាស្ត្រនៅសាកលវិទ្យាល័យ Louisville នៅ Kentucky ឱ្យដឹងថាប្រភេទបាក់តេរីបង្កជាជំងឺអញ្ចាញ ធ្មេញ និងជំងឺរលាកសន្លាក់សណ្ឋានទាបមានទំនាក់ទំនងជាមួយគ្នាដល់កម្រិតវាងាយស្រួលវិវត្តរីកចម្រើនលឿនជាងនិងកម្រិតធ្ងន់ធ្ងរជាង។

បាក់តេរីបង្កជំងឺអញ្ចាញធ្មេញរលាកអញ្ចាញធ្មេញ Porphyromonasgingivalis បង្កើតជាប្រភេទអង់ហ្ស៊ីមមួយមានឈ្មោះថា Deiminansepeptidylarginine(PAD) អាចប្រតិកម្មជាមួយបរិមាណប្រូតេអ៊ីនកំណត់មួយ ។

ពួកអ្នកវិទ្យាសាស្ត្រអង្កេតឃើញថាអង់ហ្ស៊ីម PAD ផ្លាស់ប្តូរបរិមាណលើសនៃប្រូតេអ៊ីនកំណត់ បង្កើតជាអាស៊ីតអាមីនមិនចាំ Citrulline ។ អាស៊ីតអាមីននេះនឹងនាំដល់ការវាយប្រហារប្រព័ន្ធអង្គបដិបក្ខក្នុងសរីរាង្គ។

ការស្រាវជ្រាវបង្ហាញថាអ្នកត្រូវរលាកអញ្ចាញនឹងមានហានិភ័យខ្ពស់កើតជំងឺរលាកសន្លាក់សណ្ឋានទាប។



# រៀនភាសាបរទេសជួយពន្យឺតភាពចំណាស់



*រៀនភាសាទី២ អាចជួយពន្យឺតភាពចំណាស់ខួរក្បាលហើយធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពអាន និងបញ្ញាឈ្លាសវៃ នេះបើតាមការស្រាវជ្រាវថ្មីៗនៅអង់គ្លេស ។ពួកអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យ Edinburgh (អង់គ្លេស) បានប្រើប្រាស់ទិន្នន័យពីលំហាត់ត្រួតពិនិត្យបញ្ញាឈ្លាសវៃរបស់មនុស្ស២៦២នាក់នៅអាយុ១១ឆ្នាំ ។បន្ទាប់ពីនោះគេបានពិនិត្យមើលការប្រែប្រួលសមត្ថភាពយល់ដឹងរបស់ពួកគេក្នុងលំហាត់ត្រួតពិនិត្យពេលមានអាយុ ៧០ ឆ្នាំ។*

*អ្នកចូលរួមទាំងអស់និយាយថាអាចទាក់ទងប្រាស្រ័យតិចបំផុតតាមរយៈភាសាមួយ ផ្សេងក្រៅពីភាសាអង់គ្លេសយ៉ាងតិចមួយភាសា ក្នុងនោះ ១៩៥ នាក់ រៀនភាសាទី ២ មុនអាយុ ១៨ ឆ្នាំ ។ លទ្ធផលពីលំហាត់ត្រួតពិនិត្យបង្ហាញថាអ្នកនិយាយ ២ ឬច្រើនភាសាជាងមានសមត្ថភាពយល់ដឹងល្អជាងយ៉ាងច្រើន។ ពិសេស សមត្ថភាពអានប្រាស្រ័យទាក់ទងក្បោះក្បាយ និងបញ្ញាឈ្លាសវៃនៃមនុស្សទាំងនេះត្រូវបានកែប្រែប្រសើរឡើងច្រើន ។*

*បណ្ឌិត Thomas Bak នៅសកលវិទ្យាល័យ Edinburgh បានឱ្យដឹងថា រៀនភាសា ២ សូម្បីតែពេលនៅអាយុពេញវ័យក៏នឹងនាំមកនូវផលប្រយោជន៍ប្រឆាំងភាពចំណាស់ខួរក្បាល ជួយឱ្យខួរក្បាលបានហ្វឹកហាត់រាល់ថ្ងៃ និងទប់ស្កាត់ការថមថយការចងចាំ ។*

# មើលកុនអាសអាភាសអន្តរាយដល់ខួរក្បាល

នេះជាការព្រមានរបស់អ្នកវិទ្យាសាស្ត្រអាល្លឺម៉ង់ដែលត្រូវបានប្រកាសជាសាធារណៈលើទស្សនាវដ្ដីចិត្តវិទ្យារបស់សមាគមវេជ្ជសាស្ត្រអាមេរិក ។ ក្រុមស្រាវជ្រាវបានធ្វើការស្កេនខួរក្បាល (MRI) លើបុរស ៦៤ នាក់មានអាយុពី ២១ ទៅ ៤៥ ឆ្នាំ ដែលនិយមមើលកុនអាសអាភាសលើគេហទំព័រសិច ។ នៅពេលថត MRI នោះ ពួកគេពុំទាន់បានដឹងពីបំណងនៃការស្រាវជ្រាវទេ តែបន្ទាប់មកទើបគេដឹងដោយសារត្រូវបានសំណូមពរឱ្យឆ្លើយនឹងសំណួរពីពេលវេលានៃការមើលកុនកូនជ្រូក ។ រយៈពេលជាមធ្យមនៃក្រុមមនុស្សនេះមើលភាពយន្តអាសអាភាសគឺ ៤ ម៉ោង ក្នុងមួយសប្តាហ៍ ។

ក្រុមស្រាវជ្រាវពិនិត្យឃើញថាបរិមាណសារធាតុប្រផេះក្នុងខួរក្បាលរបស់អ្នកមើលកុនប្រភេទនេះច្រើនមានចំនួនតិចជាងអ្នកដែលកម្រមើល ។ រីឯផ្នែកវិនិច្ឆ័យនៃសំណុំខួរក្បាលក៏អន់ជាងដែរ។ ក្រុមស្រាវជ្រាវនៅបន្តសួរខ្លួនឯងថាតើអ្នកដែលមានសារធាតុប្រផេះតិចជាងធម្មតា ធ្វើឱ្យគេរងឥទ្ធិពលនិយមភាពយន្តអាសអាភាស ឬភាពយន្តអាសអាភាសនាំឱ្យសារធាតុនេះថយចុះ ? ។ នេះជាសំណួរដែលក្រុមស្រាវជ្រាវបានចោទហើយបន្តសិក្សាបន្ថែមដើម្បីផ្តល់ចម្លើយ។





# បណ្ដាវិស័យជាសក្ដានុពលក្នុងការអភិវឌ្ឍខេត្តកំពង់ស្ពឺ

*ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ការអភិវឌ្ឍក្នុងទឹកដីខេត្តកំពង់ស្ពឺកាន់តែមានល្បឿនឆ្ពោះទៅមុខយ៉ាងខ្លាំងក្លា ។ យើងបានមើលឃើញថា វិស័យសេដ្ឋកិច្ច និងទេសចរណ៍មានសក្ដានុពលខ្លាំង ហើយនេះជាមោទនភាព និងគួរឱ្យកោតសរសើរដែលពីមួយឆ្នាំទៅមួយឆ្នាំខេត្តកំពង់ស្ពឺបានប្រែក្លាយទៅជាទឹកដីដ៏ស្រស់បំព្រង មានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដែលត្រូវបានកសាងតភ្ជាប់គ្នាពីតំបន់មួយទៅតំបន់មួយ ពិសេសពីតំបន់ដាច់ស្រយាលទៅទីប្រជុំជន ។ តើអ្វីទៅដែលជាមូលហេតុសំខាន់នាំឱ្យទឹកដីខេត្តកំពងស្ពឺមានការអភិវឌ្ឍយ៉ាងលឿនបែបនេះ ។ យើងរំឭកទៅដល់ប្រសាសន៍របស់សម្ដេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *ដែលតែងតែថ្លែងទៅកាន់ប្រជាជនជារឿយៗថា ប្រសិនបើគ្មានសុខសន្តិភាព គ្មានស្ថិរភាព សុវត្ថិភាពសង្គមទេនោះ គឺយើងមិនអាចធ្វើការអភិវឌ្ឍបានឡើយ ។ ការអភិវឌ្ឍត្រូវដើរទន្ទឹមគ្នានឹងសុខសន្តិភាព និងស្ថិរភាពនយោបាយ ។ ជាភ័ព្វសំណាងក្នុងពេលដែលប្រទេសមួយចំនួននៅលើពិភពលោក រាប់ទាំងប្រទេសជិតខាងយើងខ្លះ កំពុងជួបបញ្ហាលំបាកនោះ ប៉ុន្តែកម្ពុជាកំពុងតែខិតខំពង្រឹងខ្លួនលើកកម្ពស់ធ្លុងសាមគ្គីភាព ឯកភាពជាតិ ជាមហាគ្រួសារតែមួយ បង្កើតបានឱកាសអភិវឌ្ឍន៍ប្រទេសជាតិឱ្យបានរីកចម្រើនយ៉ាងឆាប់រហ័ស ។*



*ទេសភាពធម្មជាតិវាលស្រែក្នុងខេត្តកំពង់ស្ពឺ*



*តំបន់រមណីយដ្ឋានធម្មជាតិតេទឹកពុះក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ*

ពិនិត្យជាក់ស្ដែងអំពីស្ថានភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើងឃើញថាគ្រប់ខេត្តរាជធានី កំពុងតែសស្រោកសស្រាំក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការអភិវឌ្ឍទាំងនៅទីប្រជុំជន និងទាំងនៅមូលដ្ឋានជនបទ។ ដោយឡែក ខេត្តកំពង់ស្ពឺក៏កំពុងតែបំផុសចលនាមហាជនសកម្មចូលរួមការកសាងទឹកដីនៃខេត្តរបស់ខ្លួនផងដែរ។ ខេត្តកំពង់ស្ពឺគ្រប់ដណ្ដប់ដោយតំបន់ព្រៃប្រមាណ ៦០% ។ ខេត្តនេះមានផ្ទៃដីសរុប ៦៩៦ ៩៧១ គីឡូម៉ែត្រការ៉េ និងមានប្រជាជនសរុប ៧៤៦ ៩៨២ នាក់ ចែកចេញជា ១ ៨០៨ ភូមិ ៨២ ឃុំ ៥ សង្កាត់ ៨ ស្រុក-ក្រុង។ ប្រជាជនប្រកបរបរកសិកម្មមានប្រមាណ ៨៥% ។

និយាយអំពីខេត្តកំពង់ស្ពឺ គេបានផ្ដោតជាសំខាន់ហើយដែលគេស្គាល់បំផុតគឺការងារកសិកម្ម និងការធ្វើស្ករត្នោត ។ ខេត្តនេះមានចំណាត់ថ្នាក់ខ្ពស់ខាងដំណាំស្រូវ ។ខេត្តកំពង់ស្ពឺមានផ្ទៃដីបង្កបង្កើនផលស្រូវសរុប ១១០ ០០០ ហ.តដែលពីឆ្នាំកន្លងទៅបានផ្ដល់បរិមាណផលគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងខេត្ត និងមានសល់ស្បៀង គិតជាអង្ករចំនួន ៣៣ ០០០ តោន។





*ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទៅកម្សាន្តនៅតំបន់រមណីយដ្ឋានធម្មជាតិទឹកជ្រោះគីរីរម្យ ក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ*



*ប្រឡាយមេនាំទឹកនៅភូមិសារាម ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ*

បច្ចុប្បន្ន ប្រជាជននិយមធ្វើស្រូវផ្កាម្លិះជាស្រូវប្រភេទលេខ ១ និងជា ស្រូវមានតម្លៃខ្ពស់ក្នុងទីផ្សារ ។រោងម៉ាស៊ីនកិនស្រូវដែលបានចុះបញ្ជីការមាន ៤៨ កន្លែង ក្នុងនោះមាន ១៧ កន្លែង ជារោងម៉ាស៊ីនខ្នាតធំ ។ កសិដ្ឋានចិញ្ចឹមជ្រូកធំៗមានប្រមាណ ៥៦ កន្លែង ដែលបានផ្តល់ផលប្រយោជន៏ដល់កសិករ ក្នុងបរិមាណសរុបប្រហែល ១១០ ៤៧៩ ក្បាល/ឆ្នាំ។ សត្វជ្រូកដែលកសិករ និងកសិដ្ឋានចិញ្ចឹមជាប្រចាំថ្ងៃក្នុងខេត្តមានប្រមាណ ៣២ ៧១៩ ក្បាល តាមស្ថិតិនាឆ្នាំកន្លងទៅ ។ ក្រៅពីសមិទ្ធផលខាងលើ ខេត្តកំពង់ស្ពឺនៅមានឡផលិតឥដ្ឋ និងក្បឿង តម្បាញក្រមាជាលក្ខណៈគ្រួសារ ការដ្ឋានវាយថ្មរបស់ក្រុមហ៊ុន និងគ្រួសារកសិដ្ឋានចិញ្ចឹមមាន់ ទា។ ថ្មីៗនេះ នៅមានរោងចក្រផលិតស្ករអំពៅសម្រាប់នាំចេញទៅទីផ្សារអឺរ៉ុប រួមទាំងវិស័យកាត់ដេរ ដោយស្រូបទាញយកកម្លាំងពលកម្មបានរាប់ម៉ឺននាក់ ។ ដោយឡែកវិស័យស្ករត្នោតក៏ជាសក្តានុពលមួយដ៏សំខាន់ក្នុងការជំរុញល្បឿនអភិវឌ្ឍន៏ខាងសេដ្ឋកិច្ចរបស់ខេត្តកំពង់-ស្ពឺ ។ នៅក្នុងខេត្តនេះ ស្ទើរគ្រប់ស្រុកទាំងអស់ គឺស្រុកណាក៏មានដើមត្នោតដែរ ។ ក្នុងមួយឆ្នាំប្រជាកសិករប្រកបរបររកស៊ីឡើងត្នោត ផលិតស្ករត្នោតបាន ១២ ៤៤៥ តោន ។ ក្នុងរយៈពេលមួយឆ្នាំដូចគ្នា ត្នោតមួយដើមអាចផលិតបានស្ករប្រមាណពី ៣០-៤០ គីឡូក្រាម ។ តាមកំណត់ត្រារបស់មន្ទីរពាណិជ្ជកម្មខេត្តបានឱ្យដឹងថាដើមត្នោតសរុបទូទាំងខេត្តកំពង់ស្ពឺ មានប្រហែល ៥៥៨ ៧៨៩ ដើម ក្នុងនោះដើមត្នោតដែលបានផលជាទឹកត្នោត និងស្ករមានចំនួនប្រហែល ៣១១ ១៣២ ដើម ។

លោក *សម សារឿន* ប្រធានសហគមន៏លើកកម្ពស់ស្ករត្នោតកំពង់ស្ពឺ បានមានប្រសាសន៏ថា សហគមន៏របស់លោកមានសមាជិកជាង ២០០ គ្រួសារ ។ សហគមន៏ផលិតបានស្ករត្នោតក្នុងមួយឆ្នាំជាង ៤០០ តោន ។ស្ករត្នោតកំពង់ស្ពឺមានតម្លៃ ១០០០ ដុល្លារ ក្នុង ១ តោន ខណៈដែលស្ករត្នោតពីខេត្តដទៃទៀតលក់បានតម្លៃ ៨០០ ដុល្លារ ក្នុង ១ តោន ។ កាលពីឆ្នាំ ២០១១ ក្រុមហ៊ុន Confirel បានសហការជាមួយកសិករអ្នកផលិតស្ករត្នោតនៅក្នុងខេត្តកំពង់ស្ពឺចំនួន ៤០ គ្រួសារ ប្រមូលទិញស្ករត្នោតបាន ២៣ តោន សម្រាប់នាំចេញទៅលក់នៅលើទីផ្សារអន្តរ-ជាតិ ។ ការនាំស្ករត្នោតទៅលក់នៅក្រៅប្រទេសនាំឱ្យកសិករខ្មែរមានការងារធ្វើ កាន់តែច្រើន ប៉ុន្តែបញ្ហាប្រឈមគឺខ្វះស្ករត្នោតដើម្បីផ្គត់ផ្គង់តាមការបញ្ជាទិញ ដោយសារតែស្ករត្នោតត្រូវធ្វើឡើងទៅតាមរដូវកាល ។ ម្យ៉ាងទៀតកម្ពុជាយើងពុំទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការថែរក្សាស្ករត្នោត និងទឹកត្នោតឱ្យបានយូរឡើយ ហើយក៏ពុំមានរោងចក្រសម្រាប់ផលិតស្ករត្នោតនៅឡើយដែរ ។ការផលិតស្ករត្នោតត្រូវធ្វើឡើងដោយកសិករនៅតាមគ្រួសារនីមួយៗ ដែលមានទម្លាប់ផលិតស្ករត្នោតនេះពីដូនតារបស់ខ្លួន ។ បច្ចុប្បន្ន ចំនួនអ្នកផលិតមានការថយចុះដោយ-សារបរិមាណទឹកត្នោតតិច តែការចំណាយទុនច្រើនក្នុងការផលិត ។

យើងងាកមកមើលតំបន់ទេសចរណ៏ងណេះវិញឃើញថា ខេត្តកំពង់ស្ពឺក៏មិនចាញ់ខេត្តដទៃៗទៀតដែរ បើទោះជាខេត្តនេះមិនសម្បូរទៅដោយប្រាសាទបុរាណក៏ដោយ ។ ខេត្តកំពង់ស្ពឺសម្បូរតំបន់ទេសចរណ៏ធម្មជាតិ ដែលជាទីទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនគួរសមដែរ ។ ទីតាំងទេសចរណ៏នានា ត្រូវបានបើកឱ្យភ្ញៀវទៅទស្សនា ដែលតំបន់ទាំងនោះពីមុនមានស្ថានភាពលំបាកយ៉ាងក្រៃលែងទាំងផ្លូវធ្វើដំណើរ ទាំង បញ្ហាសន្តិសុខ ។ប៉ុន្តែបច្ចុប្បន្ននេះ តំបន់ទេសចរណ៏ធម្មជាតិយ៉ាងប្រណិតទាំងនោះ បានក្លាយទៅជាទីកន្លែងទាក់ទាញយ៉ាងសំខាន់ ។ តំបន់ទេសចរណ៏ដែលធ្វើឱ្យប្រជាជនចាប់អា-រម្មណ៏ខ្លាំងគឺតំបន់ភ្នំព្រះ ជាកន្លែងប្រមូលផ្តុំប្រជាពលរដ្ឋពីទីជិតឆ្ងាយមកគោរពបូជាបន់ស្រន់តាមជំនឿរបស់ខ្លួនរៀងៗខ្លួន ព្រោះទីនោះល្បីថាមានភាពអច្ឆរិយៈខ្លាំងខាងជំនឿ ។ ទីនោះជាកន្លែងបួងសួងពូកែស័ក្តិសិទ្ធិ ហើយនៅតាមជើងភ្នំ ព្រះមានសំណង់បែបសាសនាដែលសាងសង់ឡើងតាមរូបភាពខុសៗគ្នាជាច្រើន ។ ភ្នំព្រះមានរូងភ្នំ និងល្អាងភ្នំជាច្រើនមានលក្ខណៈធម្ម-ជាតិពិតៗ ។ ល្អាងភ្នំ និងរូងភ្នំទាំងនោះត្រូវបានគេរៀបចំជាកន្លែងគោរពបូជា ។ ដោយឡែករមណីយដ្ឋានវប្បធម៌ទេសចរណ៏ភ្នំចាស់ មានផ្ទៃដីសរុប ១០០ ហ.ត ស្ថិតនៅក្នុងស្រុកឱរ៉ាល់តាមផ្លូវទៅចម្ការអំពៅរបស់ឧកញ៉ា **លី យ៉ុង ផាត់** មានចម្ងាយជាង ៥០ គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ស្ពឺ គឺជារមណីយដ្ឋានប្រវត្តិសាស្ត្រ ដែលគេទើបរកឃើញក្នុងពេល ថ្មីៗនេះ ។ អ្នកទេសចរក៏កំពុងតែសំរុកទៅទស្សនាតំបន់រម-ណីយដ្ឋាននេះដែរ ។ នៅទីនោះ សម្បូរទៅដោយល្អាងភ្នំធំៗ ពិសេសអ្នកទៅកម្សាន្តទីនោះនឹងបានទស្សនារបាំ និងស្គាល់ពីទំនៀមទម្លាប់របស់បងប្អូនជនជាតិភាគតិចសួយ ។ នៅស្រុកឱរ៉ាល់នេះដែរមានតំបន់ទេសចរណ៏ធម្មជាតិពិសេសមួយដែលពុំមាននៅទីដទៃទៀត គឺ តំបន់តេទឹក

ពុះ ដែលមានទឹកក្តៅពីធម្មជាតិផុសចេញពីក្នុងដីមកមានប្រយោជន៍ដល់សុខភាព។រមណីយដ្ឋានមួយទៀតដែលល្បីល្បាញសុសសាយតាំងពីយូរយារណាស់មកហើយគឺគិរីរម្យ ។ រមណីយដ្ឋានគិរីរម្យមានលក្ខណៈពិសេសសម្រាប់ភ្ញៀវទេសចរទាំងឡាយ ដូចជាព្រៃដើមស្រល់យ៉ាងក្រាស់មានម្លប់ជាទីមនោរម្យ ព្រមទាំងមានខ្យល់អាកាសដ៏បរិសុទ្ធ ដែលធ្វើឱ្យអារម្មណ៍របស់យើងទាំងអស់គ្នាស្រស់ស្រាយយ៉ាងក្រៃលែង។ ឧទ្យានជាតិនេះស្ថិតនៅក្នុងភូមិដីរីផុង ឃុំគិរីរម្យ ស្រុកភ្នំស្រួច មានចម្ងាយ ១១៧ គីឡូម៉ែត្រ ពីភ្នំពេញ តាមផ្លូវជាតិលេខ ៤។ កំពូលភ្នំគិរីរម្យមានកម្ពស់ ៧០០ ម៉ែត្រ។ នៅទីនោះមិនត្រឹមតែជាទីទាក់ទាញអារម្មណ៍របស់ភ្ញៀវទេសចរជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទីកន្លែងទាក់ទាញភ្ញៀវទេសចរអន្តរជាតិដែរ ព្រោះនៅប្រទេសកម្ពុជាមានតែរមណីយដ្ឋានគិរីរម្យតែមួយប៉ុណ្ណោះ ដែលមានដុះដើមស្រល់រាប់ម៉ឺនដើមដូចបណ្តាប្រទេសអឺរ៉ុប។ រមណីយដ្ឋានមួយទៀតដែលមានលក្ខណៈសម្បត្តិពិសេសខាងធម្មជាតិដែរនោះគឺចំបក់។រមណីយដ្ឋានធម្មជាតិចំបក់ជាតំបន់ទេសចរណ៍ធម្មជាតិដ៏ស្រស់ស្អាតមួយដែលមានទឹកធ្លាក់ពីកំពូលភ្នំជា ៤ ដំណាក់ផ្សេងៗគ្នាជាទីកន្លែងកំពុងពេញ និយមរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ ទីនេះមានទឹកជ្រោះធ្លាក់ដ៏ស្រស់ត្រកាល មានដងអូរដ៏វែងអន្លាយ ទឹកហូរបត់បែនកាត់ផ្ទាំងថ្មដោយមានម្លប់ឈើ ពិសេសម្លប់ឫស្សីនៅអមសងខាងផ្លូវធ្វើដំណើរគួរឱ្យត្រជាក់ចិត្ត និងជាទីចាប់អារម្មណ៍យ៉ាងក្រៃលែង។ រមណីយដ្ឋានចំបក់មានចម្ងាយជាង ១ គីឡូម៉ែត្រ ខាងជើងរមណីយដ្ឋានគិរីរម្យ ស្ថិតនៅក្នុងឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ អំពែភ្នំក៏ជានិមិត្តរូបមួយនៃតំបន់រមណីយដ្ឋានរបស់ខេត្តកំពង់ស្ពឺផងដែរ។ បើគេនិយាយអំពីអំពែភ្នំ អ្នកណាក៏ដឹងថា វាជាទីកដីនៅក្នុងខេត្តកំពង់ស្ពឺ ប៉ុន្តែបើគេនិយាយអំពីខេត្តកំពង់ស្ពឺគឺគេនឹកភ្នកទៅដល់អំពែភ្នំភ្លាម។ អំពែភ្នំជារមណីយដ្ឋានវប្បធម៌ និងធម្មជាតិ មានទីតាំងស្ថិតនៅភូមិតាំងទន្លេ និងភូមិ អំពែភ្នំ សង្កាត់សុពណ៌ទេព និងសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន មានចម្ងាយ ៤៨ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ នៅជើងភ្នំអំពែភ្នំមានស្ពានយោលមួយឆ្លងកាត់ពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ដើម្បីតភ្ជាប់ពីភូមិតាំងទន្លេរបស់ឃុំសុពណ៌ទេពទៅភូមិអំពែភ្នំ ឃុំអំពែភ្នំ។ នៅត្រើយខាងត្បូងស្ទឹង យើងសង្កេតឃើញមានវត្តចាស់បុរាណមួយនៅលើកូនភ្នំ ដែលជាទីសក្ការៈរបស់ប្រជាជនទៅធ្វើបុណ្យទានតាមប្រពៃណីជាតិ ។ គួររំលឹកបន្តិចដែរថា កាលពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទីនេះគឺជាជំរុំឃុំឃាំង និងសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។ ក្នុងព្រះវិហារវត្តអំពែភ្នំគឺជាកន្លែងធ្វើទារុណកម្មមនុស្សដែលនៅនឹងជញ្ជាំងវិហារមានស្លាកស្នាមឈាមជនរងគ្រោះ មានដុំសក់ និងឧបករណ៍សម្រាប់ធ្វើទារុណកម្មយ៉ាងច្រើន។ មកដល់សព្វថ្ងៃថ្វីត្បិតតែរមណីយដ្ឋានអំពែភ្នំបានក្លាយទៅជាទីកន្លែងកម្សាន្តរបស់ភ្ញៀវទេសចរក៏ដោយ ប៉ុន្តែពេលទៅដល់ទីនោះម្នាក់ៗនៅតែរំឭកទៅដល់អតីតកាលដ៏ឈឺចាប់ទាំងនោះ ដែលមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានបង្កើតឡើង។

ជាការពិត ខេត្តកំពង់ស្ពឺមានសក្តានុពលធំធេងខាងសេដ្ឋកិច្ច និងទេសចរណ៍ ប៉ុន្តែការប្រើប្រាស់សក្តានុពលនេះដើម្បីអភិវឌ្ឍខេត្ត និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនមិនទាន់បានខ្លាំងក្លានៅឡើយទេ ដែលទាមទារការកសាងពង្រីកពង្រឹងហេដ្ឋារចនាសម្ព័ន្ធឱ្យបានរីកចម្រើនថែមទៀត ការពិនិត្យដើម្បីដាក់ចេញនូវគោលនយោបាយថ្មីៗទៀត និងការប្រឹងប្រែងទ្វេឡើងរបស់អាជ្ញាធរនៅគ្រប់ថ្នាក់។ ព្រមជាមួយនោះ ប្រជាជនកំពង់ស្ពឺគួរមានមោទនភាពចំពោះសក្តានុពលរបស់ខេត្ត ហើយបង្កើនការចូលរួមឱ្យកាន់តែច្រើនឡើងប្រកបដោយភាពម្ចាស់ការ និងការច្នៃប្រឌិតដើម្បីអភិវឌ្ឍខេត្តកំពង់ស្ពឺតទៅមុខទៀត។


មុខរបរផលិតស្ករត្នោតរបស់ប្រជាកសិករខេត្តកំពង់ស្ពឺ


ផលិតផលធ្វើអំពីស្ករត្នោតរបស់ប្រជាកសិករខេត្តកំពង់ស្ពឺ




រយៈពេលជាង ៣៥ ឆ្នាំកន្លងទៅ ហើយដែលប្រជាជនកម្ពុជាទូទាំងប្រទេស និយាយរួម និងនិយាយដោយឡែក ប្រជាជនខេត្តកំពង់ស្ពឺបានខិតខំអស់កម្លាំងកាយចិត្ត កម្លាំងបញ្ញាស្មារតីកសាងភូមិដ្ឋានរបស់ខ្លួនតាំងពីបាតដៃទទេរហូតមានការអភិវឌ្ឍដូចបច្ចុប្បន្ន។ការអភិវឌ្ឍនេះគឺពិតជាបានមកដោយសារប្រទេសយើងមានសុខសន្តិភាព។ សន្តិភាព និងការអភិវឌ្ឍមិនមែនកើតឡើងដោយចៃដន្យឡើយ គឺបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចទាំងបីជាប្រមុខដ៏ឈ្លាសវៃ ដែលទទួលបានការស្រឡាញ់ និងការគាំទ្រពីសំណាក់ប្រជាជននៅទូទាំងប្រទេស។/




# កង្កែបខែវស្សា

(បទពាក្យ៧)

- បងដាស់ដីស្រែក្បែរដំបូក
  បងចតគោយន្តក្បែរម្លប់ស្ដៅ
- កង្កែបលោតផ្លោតផ្លោះភ្លឺស្រែ
  លោតចូលស្រែស្រីស្រស់ចំណាប់
- បងអង្វរម៉ុមសុំមកវិញ
  ត្បិតបងខំដេញកាត់ស្រែបី
- ស្រីម៉ុមកាន់ជាប់កង្កែបអួក
  ស្រីម៉ុមសុំចិត្តចំពោះបង
- ត្បិតវាមានពងនៅពេញពោះ
  កត្តិកធ្លាក់ខ្យល់ដល់ស្រូវថ្មី
- នាងខំព្យាយាមពន្យល់បង
  ស្រីម៉ុមក្មេងពិតគំនិតចាស់
- ថាហើយស្រីម៉ុមនាំបងទៅ
  ទើបលែងកង្កែបពីហត្ថា
- បងក៏សន្យានឹងស្រីម៉ុម
  បងនឹងចូលស្ដីឥតភាន់ភាំង
- បងតែងបន់ផ្សងប៉ងសច្ចា
  ក្រោយប្រមូលផលដល់ឆ្នាំថ្មី

ឃើញកង្កែបអួកពួនគុម្ពស្មៅ
ហើយស្ទុះសំដៅសង្គ្រប់ចាប់ ។
កាត់គុម្ពស្រងែលឿនប្រញាប់
នាងម៉ុមស្ទាក់ចាប់ជាប់ក្នុងដៃ ។
មិនព្រមសុំទិញឱ្យពេញថ្លៃ
ប៉ងយកឆាខ្ទឹបានឆ្ងាញ់ម្ដង ។
ផ្អាកស្នូងឡើងគោកមកសាសង
កុំមានបំណងហូបវាអី ។
ទុកវាឱ្យរស់ញាស់កូនខ្ចី
នោះយើងអាចឆីបានច្រើនណាស់ ។
ស្ដាប់ពាក្យនួនល្អងបងគួរខ្មាស់
ឱ្យបងយល់ច្បាស់ជួយរក្សា ។
សំដៅត្រពាំងមានទឹកថ្លា
ជួបជុំមច្ឆាក្នុងត្រពាំង ។
ថាក្រោយបិណ្ឌភ្ជុំកុំភ្លេចភ្លាំង
សូមម៉ុមកុំឃាំងឃាត់បងអី ។
ចង់ផ្ទឹមរៀបការនឹងម៉ុមស្រី
បាយខុនចងដៃជូនពរយើង ។/

ដោយ : សុខ សុធន




## កុំជឿវា

ពេលសិស្សផ្លូយត្រឡប់ពីសាលារៀនចូលដល់ផ្ទះ ភ្លាមនាយផ្លុងជាឪពុកហៅសួរ

-ថ្ងៃនេះកូនឯងគេចសាលាទៅដើរលេងទីណាខ្លះ កូនផ្លួយ ?

-អត់ទេពុក ! ខ្ញុំមិនបានគេចសាលាទៅដើរលេងឯណាទេ !

-កុំកុហក !អាផ្លឹមនិយាយប្រាប់អញអស់ហើយ !

-កុំជឿវាពុក ! មកពីវាខឹងខ្ញុំ មិនឱ្យទៅដើរលេងជាមួយទើបវាទូលពិតពុកហ្នឹងណាំ ។

## ទាល់ណាស់

នាយ គ្រាក់ ជំពាក់ប្រាក់ដង្ហោស៊ុកយូរហើយមិនព្រមសង លើកណាក៏ដូចជាលើកណា ពេលដង្ហោស៊ុកមកទារប្រាក់នាយគ្រាក់តែងដោះសាថាខ្ញុំកំពុងទាល់ខ្លាំងណាស់ សូមបង្អង់មួយរយៈទៀតសិន។ ថៃដន្យថ្ងៃមួយដង្ហោស៊ុកមកទារប្រាក់ នាយ គ្រាក់កំពុងហូបបាយជាមួយមាន់ដុតមួយក្បាលខ្លាញ់រងើម ។ ឃើញដូច្នោះដង្ហោស៊ុកនិយាយ :

-អៃយ៉ា...គ្រាក់ឥឡូវធូរធារណាស់តើពេលបាយមានមាន់ដុតហូបយ៉ាងឆ្ងាញ់ ម៉េចល្មមសងប្រាក់បានហើយនៅ?

នាយគ្រាក់ ធ្វើមុខញញឹមៗតបវិញ :

- ខ្ញុំកំពុងទាល់ខ្លាំងណាស់ សុំជំពាក់មួយរយៈទៀតសិន លោកដង្ហៅ!

- ហ៊ឺស....បាយមួយពេលអស់មាន់ដុតមួយក្បាលនៅត្អូញតែថាទាល់យ៉ាងម៉េចទៀត ?

- ខ្ញុំពិតជាទាល់មែនណាំលោកដង្ហៅទាល់ដល់ថ្នាក់មានមាន់មួយក្បាលរកចំណីឱ្យវាស៊ីមិនបានត្រូវបង្ខំចិត្តចាប់វាធ្វើម្ហូបសម្រាប់ខ្លួនឯង។ សួរថាតើមានអ្នកណាទាល់ជាងហ្នឹងទៀត? ។

## ចម្ងល់កុមារ

ថ្ងៃមួយកុមារមោកសួរម៉ែ :

- ម៉ែ....ម៉ែ ! ម៉េចក៏អ្នកខ្លះសក់ខ្មៅ អ្នកខ្លះសក់សអញ្ចឹង ?

- នែ កូនម៉ែ សក់សគេហៅថាសក់ស្កូវអ្នកសក់ស្កូវគេហៅថាមនុស្សចាស់ ឯអ្នកសក់ខ្មៅគេហៅថាក្មេង។

- ម៉េចបានចាស់អញ្ចឹងម៉ែ?

-គឺមកពីកើតមុន។ អ្នកកើតមុនគេហៅថាចាស់ ឯអ្នកកើតក្រោយគេហៅថាក្មេង។

- ចុះខ្ញុំចាស់ជាងតា ម៉េចក៏សក់ខ្ញុំខ្មៅ ?

-មិនមែនទេតាចាស់ជាងកូនឯងមិនមែនកូនឯងចាស់ជាងតាទេ។

-បើខ្ញុំកើតក្រោយតាហេតុអីថ្ងៃខួបកំណើតខ្ញុំមុនថ្ងៃខួបកំណើតលោកតា ?។

## មើលទៅមុខ

នាយក្រឹមនិងនាយក្រិនបើកឡានលឿនដូចហោះព្រោះប្រញាប់ឱ្យទាន់ចូលរួមបុណ្យខួបកំណើតតាក្រាញ់ជាឪពុក។ ពេលទៅជិតដល់កន្លែងឆ្លងកាត់ផ្លូវរថភ្លើងនាយក្រិននិយាយ :

-យើងមកជិតដល់ផ្លូវដែកហើយបងក្រឹមឯងមើលខាងឆ្វេងខ្ញុំមើលខាងស្ដាំ។

ទាំងពីរនាក់ធ្វើដូច្នោះមែនម្នាក់មើលទៅខាងឆ្វេងម្នាក់មើលទៅខាងស្ដាំ។ មួយសន្ទុះស្រាប់ឮសូរផាំងស្មើរបែកក្រដាសត្រចៀករួចទាំងពីរនាក់ប្រវេប្រវាចេញពីរថយន្តក្រពិតក្រពៀវហើយនាយក្រឹមលាន់មាត់:

- ប្រសិនបើមានម្នាក់ទៀតសម្រាប់មើលទៅខាងមុខម្ល៉េះសមគ្មានបានបុកដងបារ៉ាស់អីចឹងទេ។/

បោះពុម្ពដោយ រោងពុម្ព អរិយធម៌ ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥៩

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ ..................... | ១០០ ដុល្លារ |
| ២- | ឯ.ឧ | មិន | ឃិន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** ..................... | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | ត្រាំ | អ៊ីវតឹក | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន ..................... | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ ..................... | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | ប្រាក់ | ចំរើន | សមាជិកព្រឹទ្ធសភា ..................... | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..... | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | លន់ | លឹមថៃ | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម..................... | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | ជៀង | អំ | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង ..................... | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | អូស្មាន | ហាសស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាម នៃគណបក្សប្រជាជនកម្ពុជា ..................... | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | សរ | ចរ៉ុង | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ ..................... | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | ជា | សុជាតិវង្ស | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ..................... | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | ឈិត | សុខុន | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ..................... | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | ម៉ម | ប៊ុននាង | សមាជិកព្រឹទ្ធសភា ..................... | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | ម៉ៅ | ធនិន | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ..................... | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | អ៊ឹន | វីរជាតិ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ..................... | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | យូ | តិរម្យ | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ ..................... | ១០០ ដុល្លារ |
| ១៧- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ..................... | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ..................... | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ..................... | ៥០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ..................... | ៥០ ដុល្លារ |
| ២១- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ..................... | ២០០.០០០ ៛ |
| ២២- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល ..................... | ៥០ ដុល្លារ |
| ២៣- | ឯ.ឧ | ជា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា ..................... | ២១៣.៤៧០៛ |
| ២៤- | ឯ.ឧ | ជូ | យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល ..................... | ៥០ ដុល្លារ |
| ២៥- | ឯ.ឧ | អ៊ុក | ប្រាថ្នា | រដ្ឋលេខាធិការក្រសួងព័ត៌មាន ..................... | ២០០.០០០ ៛ |
| ២៦- | ឯ.ឧ | ឃឹម | សារិទ្ធ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ..................... | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | ម៉ាវ | ហមផាន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ..................... | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | សូ | ជុងហួរ | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ ..................... | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | ចាយ | បូរិន | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម ..................... | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ..................... | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | ឃួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ..................... | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | ប៊ុន | លឹមហេង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ..................... | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | សេង | ទៀង | ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ..................... | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ..................... | ១០០.០០០៛ |
| ៣៥- | ឯ.ឧ | ម៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ ..................... | ១០០.០០០៛ |
| ៣៦- | លោកជំទាវ | ស៊ឹង | ស៊ុំយុត | ..................... | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | គឹម | ធា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង ..................... | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | ប៊ិច | សុវណ្ណ | ..................... | ១០០.០០០៛ |
| ៣៩- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ..................... | ១០០.០០០៛ |
| ៤០- | លោកជំទាវ | ទិត្យ | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..................... | ១០០.០០០៛ |
| ៤១- | ឯ.ឧ | ធា | ច័ន្ទលីដា | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ..................... | ១០០.០០០៛ |
| ៤២- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង ..................... | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | ជួន | ចេរ៉ាវ៉ាត | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន..................... | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | ម៉ៅ | ឡាំង | ទីប្រឹក្សាឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា ..................... | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | ឆាយ | ឫទ្ធិសែន | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ..................... | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | អ៊ឹន | ឆាលី | សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង ..................... | ១០០.០០០៛ |
| ៤៧- | លោក | អោម | ចន | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ ..................... | ១០០.០០០៛ |
| ៤៨- | លោក | សាំ | ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ..................... | ១០០.០០០៛ |
| ៤៩- | លោក | សុខ | វិសាលសម្បត្តិ | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំព្នៅ១ ស្រុកស៊ីធរកណ្តាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល ... | ១០០.០០០៛ |
| ៥០- | លោក | សារូ | រដ្ឋជាតិ | មន្ត្រីសាលាខេត្តប៉ៃលិន ..................... | ៧០.០០០៛ |
| ៥១- | លោកជំទាវ | ខេង | សំវ៉ាដា | រដ្ឋលេខាធិការក្រសួងកិច្ចការនារី ..................... | ៥០.០០០៛ |
| ៥២- | ឯ.ឧ | សាយ | បូរិន | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ..................... | ៥០.០០០៛ |
| ៥៣- | ឯ.ឧ | សេង | គឹមសាន | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ..................... | ៥០.០០០៛ |
| ៥៤- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម ..................... | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ ..................... | ៥០.០០០៛ |
| ៥៦- | លោក | ស៊ាង | ចាន់ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ ..................... | ៥០.០០០៛ |
| ៥៧- | លោក | ឃួន | សំបូរ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ ..................... | ៥០.០០០៛ |
| ៥៨- | លោកជំទាវ | សឿ | ច័ន្ទថា | ..................... | ៥០.០០០៛ |
| ៥៩- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ ..................... | ៥០.០០០៛ |
| ៦០- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ..................... | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៥៩

| | | | | | |
|---|---|---|---|---|---|
| ៦១- | កញ្ញា | ផាង | និតហ្វៃរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦២- | លោក | ទៅ | ម៉េងថ្រូន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៣- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៤- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៥- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៦- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៧- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៦៨- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៦៩- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧០- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧១- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៧២- | ឯ.ឧ | ស៊ិន | ឧទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៣- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៤- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៥- | លោក | ចាន់ | ស៊ុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៦- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៧- | លោក | នេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៧៨- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៩- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨២- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៨៣- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៤- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៥- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៦- | លោក | នូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៧- | លោក | ហួង | ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៨៨- | លោក | ម៉ី | វុឌ្ឍា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨៩- | លោក | អ៊ុក | គឹមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៩០- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩១- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩២- | លោក | អ៊ុច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៣- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៤- | ឯ.ឧ | ប៉ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៥- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ៩៦- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៧- | លោក | មឹម | ប្រុស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៩- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០០- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០១- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០២- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៣- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៤- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៥- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៦- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៧- | លោក | ស៊ូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៨- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៩- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១០- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១១- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១២- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៣- | លោក | នូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៤- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៥- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៦- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៧- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៨- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៩- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |





មហាសន្និបាតអាណត្តិទី ៦
របស់កាកបាទក្រហមកម្ពុជា

៥



* ទិសដៅ ៤ ចំណុច ដើម្បីអភិវឌ្ឍយុវជន
* សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ............

៨




សម្តេចចក្រី **ហេង សំរិន**
បំពេញទស្សនកិច្ចជាផ្លូវការ
នៅសាធារណរដ្ឋសង្គម
និយមវៀតណាម

១២

## ក្របមុខ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រគល់សញ្ញាប័ត្រជូនដល់និស្សិតជ័យលាភីថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យន័រតុន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ (១១.០៨.២០១៤)

# មាតិកា
# Contents


*វិចារណកថា :* ការគោរព និងការពាររដ្ឋធម្មនុញ្ញគឺជាកាតព្វកិច្ចចម្បងរបស់ពលរដ្ឋគ្រប់រូប និងគ្រប់កម្លាំង នយោបាយក្នុងសង្គម.......... ១

*Editorial : Respect and Defend Constitution – Chief Obligation of Every Citizen and Political Forces..........*

⇨ វិវត្តន៍ជាវិជ្ជមាននៃសភាពការណ៍នយោបាយកំពុងផ្តល់ភាពអនុគ្រោះដល់ជាតិ និងប្រជាជន ...... ៣

⇨ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស .......... ១៣
⇨ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.......... ១៥
⇨ កម្ពុជា និងការអភិវឌ្ឍដំណាំកៅស៊ូ.......... ១៦
⇨ អនុត្តរភាពទឹក : ការដ្ឋានចំនួន ២៦ បាននិងកំពុងដំណើរការ.......... ១៨
⇨ ចាត់គ្រប់វិធានការ និងប្រើគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់ការខាតបង់ ធ្ងន់ធ្ងរដោយគ្រោះទឹកជំនន់នៅឆ្នាំ ២០១៤ នេះ.......... ២១
⇨ វប្បធម៌ : ឈ្វេងយល់អំពីវិស័យតូរ្យតន្ត្រីខ្មែរ នាសម័យបុរេប្រវត្តិសាស្ត្រ.......... ២៣
⇨ ចំណេះដឹងទូទៅ : អេបូឡាជំងឺដែលធ្វើឱ្យពិភពលោកព្រួយបារម្ភ.......... ២៥
⇨ វិទ្យាសាស្ត្រសុខភាព : ដុសធ្មេញជាប្រចាំធ្វើឱ្យថយចុះហានិភ័យរលាកសន្លាក់.......... ២៧
⇨ ទឹកដីមាតុភូមិ : បណ្តាវិស័យជាសក្តានុពលក្នុងការអភិវឌ្ឍខេត្តកំពង់ស្ពឺ.......... ២៨
⇨ កំណាព្យ : កង្កែបខែវស្សា.......... សំណើច ..........៣១



**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ុំ សុន្ទរៈ
៣. លោក វង្ស សាវុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន

**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី

**វិចិត្រករ**
១. លោក ធា សាវុធ

អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

# ទស្សនាវដ្តី ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី១៤ លេខ ១៨៩ ខែសីហា ឆ្នាំ ២០១៤





ភ្ញៀវទេសចរជាតិ
និងអន្តរជាតិ
ទស្សនាកម្សាន្ត
តាមរមណីយដ្ឋាន
ប្រវត្តិសាស្ត្រ
និងធម្មជាតិ
មានកំណើន
ជារៀងរាល់ឆ្នាំ